# កម្ពុជា

KAMBUJA

លេខ២៣២ ខែ មិថុនា ២០២២
























**ក្រុមអ្នកសង្កេតការណ៍អន្តរជាតិបានវាយតម្លៃថា ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅកម្ពុជា កាលពីថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ គឺជាការបោះឆ្នោតមួយដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព មានភាពស្ងប់ស្ងាត់ សន្តិភាព និងអហិង្សា**






រូបថត : ស្រី សាម៉ាន

**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្តម **ខៀវ កាញារីទ្ធ**
រដ្ឋមន្ត្រី
ក្រសួងពតិមាន

ឯកឧត្តមជាទីរាប់អាន

ខ្ញុំ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលិខិតថ្វាយព្រះពររបស់ឯកឧត្តម នៅក្នុងឱកាសបុណ្យចម្រើនជន្មាយុ ខ្ញុំ គម្រប់៨៦ យាងចូល៨៧ ព្រះវស្សា។

សូមជូនពរឯកឧត្តម លោកជំទាវភរិយា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងពតិមានទាំងអស់ បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម និងលោកជំទាវភរិយាទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ។

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២២

# កម្ពុជា

លេខ ២៣២
ខែមិថុនា ២០២២

KAMBUJA


## មាតិកា


- សម្តេចម៉ែ សព្វព្រះរាជហឫទ័យចំពោះលទ្ធផលសំខាន់ៗ ដែលសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍក្រសួងព័ត៌មានសម្រេចបានកន្លងមក ........ ៣
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ មានគណបក្សនយោបាយចំនួន៩ ទទួលបានអាសនៈ ក្នុងនោះគណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈ ៨០,៦៧ភាគរយ........ ៧
- វិភាគ៖ ការបោះឆ្នោតជាមួយនឹងគុណតម្លៃ និងការរក្សាមូលដ្ឋានអភិវឌ្ឍន៍ជាតិផ្តើមចេញពីទឹកចិត្តរបស់ប្រជាពលរដ្ឋ... ១២
- សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារត្រូវបានព្រឹទ្ធសភាឯកភាពទាំងស្រុង ........ ១៦
- កម្ពុជា-វៀតណាម ជួបជុំគ្នារំលឹកខួបលើកទី៤៥ នៃទិវាការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត(២០ មិថុនា ១៩៧៧ – ២០ មិថុនា ២០២២) ........ ១៩
- ប្រធានរដ្ឋសភាកម្ពុជា-ឥណ្ឌា ប្តេជ្ញារួមគ្នាពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ........ ២៦
- សម្តេចតេជោ ហ៊ុន សែន៖ អាស៊ាន មិនត្រូវការជ្រើសរើសមហាអំណាចណាមួយនោះឡើយ ........ ២៨
- ការទទួលរៀបចំធ្វើម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ជាប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ........ ៣១
- សម្តេចពិជ័យសេនា ទៀ បាញ់ អញ្ជើញបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់រោងជាងជួសជុលនាវា ផែសំចត និងស្តារឃ្លង នៅមូលដ្ឋានសមុទ្រ ........ ៣៥
- ព្រឹទ្ធសភាទទួលជំនួយសម្ភារៈពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ........ ៣៩
- អាល្លឺម៉ង់ សន្យាផ្តល់ឥណទានសម្បទានមួយថ្មីទៀត ចំនួន ៣០លានអឺរ៉ូ សម្រាប់គម្រោងប្រសិទ្ធភាពថាមពល សម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ॥ ........ ៤២
- គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ សម្រេចបានជាង ៩០ភាគរយ ហើយគ្រោងដាក់ឱ្យប្រើប្រាស់សាកល្បង នៅខែកក្កដានេះ ........ ៤៦
- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន អញ្ជើញចូលរួមក្នុងពិធីដាំដើមឈើនៅក្នុងបរិវេណ នៃមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជាខេត្តកំពង់ស្ពឺ ........ ៥១
- ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ជំរុញឱ្យអាជ្ញាធរស្រុក ឃុំត្រូវផ្តល់ទំនុកចិត្ត និងបម្រើសេវាឱ្យបានល្អជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ........ ៥៥
- ឯកឧត្តម សុខ ប្រសិទ្ធិ និងឯកឧត្តម សាម៉ន បណ្ឌិត្យ រដ្ឋលេខាធិការក្រសួងព័ត៌មាន ប្រគល់ថវិកាចូលរួមចំណែកការងារមនុស្សធម៌ជាមួយឯកឧត្តម ខៀវ កាញារីទ្ធ ........ ៥៨
- ឯកឧត្តម លឹម គានហោះ ប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអនក្នុងខេត្តបាត់ដំបងសម្រេចការសាងសង់បានប្រមាណ ៩៧ភាគរយ ........ ៦០
- ឯកឧត្តម ជា ច័ន្ទបរិបូរណ៍៖ គណបក្សប្រជាជនកម្ពុជា បម្រើប្រជាជន ដើម្បីប្រជាជន និងនាំមកនូវការអភិវឌ្ឍ ........ ៦៤
- អគ្គនាយករដ្ឋាករទឹក៖ ផែនការមេផ្គត់ផ្គង់ទឹកស្អាតគ្រប់ដណ្តប់លើផ្ទៃដី ៦៧០គីឡូម៉ែត្រការ៉េ ដោយបូកបញ្ចូល

តំបន់ព្រលានយន្តហោះថ្មី និងតំបន់អរិយក្សត្រ ........ ៦៦
- ផ្លូវក្រវាត់ក្រុងទី៣ គ្រោងនឹងបញ្ចប់ការងារស្ថាបនាជាស្ថាពរនាខែកញ្ញា ឆ្នាំ២០២៣ ........ ៦៩
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣ មានសមត្ថភាពចម្រោះទឹកកខ្វក់បាន ២ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ........ ៧២
- ឯកឧត្តម ឡុង សេង និងលោកជំទាវ ចែកអំណោយជូនប្រជាពលរដ្ឋជាង ១០០គ្រួសារ នៅក្នុង ភូមិពោធិ៍តាប៉ាង និងភូមិ ព្រៃកតាសៅ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ........ ៧៤
- កម្ពុជារៀបចំព្រឹត្តិការណ៍មហោស្រពភាពយន្តអន្តរជាតិលើកទី១១ ដោយមានចាក់បញ្ចាំងខ្សែភាពយន្តចំនួន ១៤៤ចំណងជើង មកពី ២៦ប្រទេស ........ ៧៦
- រយៈពេល៤ខែដើមឆ្នាំ២០២២ កម្ពុជានាំចេញអង្ករ និងស្រូវ គិតជាទឹកប្រាក់ជាង ៥០០លានដុល្លារ ........ ៨០
- កីឡាជិះសេះកម្ពុជា ត្រៀមខ្លួនដើម្បីសម្រេចគោលដៅឆ្ពោះទៅធ្វើម្ចាស់ផ្ទះ ស៊ីហ្គេម ២០២៣ ........ ៨២
- ភ្នំណាមលៀរ ជាជម្រកដ៏សំខាន់សម្រាប់សត្វនិងរុក្ខជាតិគ្រប់ប្រភេទ ........ ៨៦
- ទទួលទានអាហារ ៥មុខនេះ នឹងផ្តល់ឱ្យស្បែកមានសុខភាពល្អនិងរក្សាតុល្យភាពនៃអ័រម៉ូន ........ ៨៨
- ព្រះរាជសារ ព្រះករុណា ព្រះមហាក្សត្រប្រទានជូនសម្តេចតេជោ ហ៊ុន សែន ស្តីពីការកែសម្រួល ថ្ងៃខែឆ្នាំកំណើតរបស់សម្តេច ........ ៩០
- សារលិខិតឯកឧត្តម ខៀវ កាញារីទ្ធ ថ្វាយព្រះពរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ក្នុងឱកាស ព្រះរាជពិធីចម្រើនព្រះជន្ម ........ ៩១
- សារលិខិតសម្តេចវិបុលសេនាភក្តី សាយ ឈុំ ថ្វាយព្រះពរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ........ ៩២
- សេចក្តីជូនដំណឹង ស្តីពីការព្យាករកម្ពស់ទឹកទន្លេមេគង្គ ........ ៩៣
- គ្រួសារក្រសួងព័ត៌មាន ចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំចំពោះមរណភាពរបស់ ធម្មាចារ្យ សីលវតី ហង្ស ឡុង ត្រូវជាម្តាយ ឯកឧត្តម ផុស សុវណ្ណ ........ ៩៥

ចេញផ្សាយដោយ
អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP
បោះពុម្ពដោយ រោងពុម្ពក្រសួងព័ត៌មាន
ទូរស័ព្ទ : ០១២ ៨២៨ ៤០៥
E-mail : Sath.Sophal@gmail.com

# សម្តេចម៉ែ សព្វព្រះរាជហឫទ័យចំពោះលទ្ធផលសំខាន់ៗ ដែលសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍក្រសួងព័ត៌មាន សម្រេចបានកន្លងមក

*អត្ថបទ ៖ ផែន រតនៈ , រូបថត ៖ ព្រះបរមរាជវាំង*



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ រាជានុញ្ញាឱ្យលោកជំទាវ ទេព រង្សី ខៀវកាញ្ញារីទ្ធ ដឹកនាំប្រតិភូ ចូលក្រាបថ្វាយបង្គំគាល់ថ្វាយព្រះពរ និងរាយការណ៍សកម្មភាពរបស់សាខាសមាគមនារីក្រសួងព័ត៌មាននៅព្រះបរមរាជវាំង



**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបានសព្វព្រះរាជហឫទ័យស្វាគមន៍ចំពោះលទ្ធផល ដ៏ប្រសើរនៃសកម្មភាពសំខាន់ៗជាច្រើន ក្រោមការដឹកនាំរបស់ លោកជំទាវ **ទេព រង្សី ខៀវកាញ្ញារីទ្ធ** ប្រធានកិត្តិយសសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ក្រសួងព័ត៌មាន ដែលបានបង្ហាញពីការខិតខំប្រឹងប្រែងក្នុងមនសិកាស្នេហាជាតិរបស់លោកជំទាវ ព្រមទាំងលោកជំទាវ និងលោកស្រី ជាសមាជិកាសមាគមអនុវត្តបានក្នុងពេលកន្លងមក។

សម្តេចម៉ែ មានព្រះរាជបន្ទូលដូច្នេះ ក្នុងឱកាសព្រះបរមរាជានុញ្ញាតឱ្យលោកជំទាវ **ទេព រង្សី ខៀវកាញ្ញារីទ្ធ** ប្រធានកិត្តិយសសមាគម ដឹកនាំសមាជិកា ចំនួន២០រូប ចូលក្រាបថ្វាយបង្គំគាល់ ថ្វាយព្រះពរ និងរាយការណ៍អំពីសកម្មភាពរបស់សមាគមនាពេលកន្លងមក នៅព្រះរាជដំណាក់ជ័យមង្គល ព្រះបរមរាជវាំង កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។



លោកជំទាវ ទេព រង្សី ខៀវកាញារីទ្ធ ដឹកនាំប្រតិភូសាខាសមាគមនារីក្រសួងព័ត៌មាន ចូលក្រាបថ្វាយបង្គំគាល់ថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ នៅព្រះបរមរាជវាំង







លោកជំទាវ ទេព រង្សី ខៀវកាញារីទ្ធ រាយការណ៍ថ្វាយសម្តេចម៉ែ ស្តីពីសកម្មភាពរបស់សាខាសមាគមនារីក្រសួងព័ត៌មាន

ក្នុងឱកាសនោះផងដែរ សម្តេចម៉ែ មានព្រះរាជសវនីយ៍ ប្រោសព្រះរាជទាននូវការសំណេះសំណាលដ៏កក់ក្តៅ ព្រមទាំងស្វាគមន៍យ៉ាងរាក់ទាក់ស្និទ្ធស្នាល និងបានអរគុណចំពោះលោកជំទាវ លោកស្រី ក្នុងគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃក្រសួងព័ត៌មាន ដែលបានអញ្ជើញចូលក្រាបថ្វាយបង្គំគាល់ ទូលសាកសួរអំពីព្រះរាជសុខភាព និងបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងយ៉ាងសកម្មមោះមុតរបស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ក្នុងការដឹកនាំធ្វើឱ្យគ្រប់ផ្នែកនៃវិស័យព័ត៌មានការរីកចម្រើនជាបន្តបន្ទាប់ ថែមទាំងបានខិតខំយកអស់ពីកម្លាំងកាយចិត្ត និងបរិច្ចាគនូវធនធានចូលរួមចំណែកជាមួយនឹងសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងការអភិវឌ្ឍន៍នៃក្រសួងព័ត៌មាន ក្នុងការជួយទុក្ខធុរៈ ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងព័ត៌មាន ការចូលរួមចំណែកក្នុងកិច្ចការសង្គម កិច្ចការមនុស្សធម៌ និងការជួយលើកតម្កើងវិស័យព្រះពុទ្ធសាសនាជាដើម ដោយមានកិច្ច



សម្តេចម៉ែ រាជានុញ្ញាតផ្តល់កិត្តិយសថតរូបអនុស្សាវរីយ៍



ដំណើរការយ៉ាងល្អប្រសើរ ដើម្បីនាំមកនូវភាពរីកចម្រើនដល់សង្គមជាតិ។

ជាមួយគ្នានេះ សម្តេចម៉ែ ព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន លោកជំទាវ **ទេព រង្សី ខៀវភាញារិទ្ធ** ដឹកនាំគណៈប្រតិភូសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍នៃក្រសួងព័ត៌មាន ចូលក្រាបថ្វាយបង្គំ និងថ្វាយគ្រឿងសក្ការៈបូជា ព្រះបរមរូប ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គង់នៅខាងមុខឈាងឥសាន្ត នៃព្រះរាជដំណាក់គន្ធបុប្ផា ក្នុងព្រះបរមរាជវាំងផងដែរ។ ការថ្វាយគ្រឿងសក្ការបូជាគោរពចំពោះព្រះបរមរូប ព្រះបរមរតនកោដ្ឋ នាឱកាសនោះ គឺជាការសម្តែងនូវសេចក្តីចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ថ្វាយចំពោះព្រះមហាករុណាទិគុណដ៏ធំធេង មិនអាចកាត់ថ្លៃបាន របស់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គបានបំពេញព្រះរាជបេសកកម្ម បម្រើមាតុភូមិ និងប្រជារាស្ត្រកម្ពុជា ទទួលបាននូវឯករាជ្យបូរណភាពទឹកដី ប្រកបដោយសេចក្តីសុខសន្តិភាព ឯកភាពជាតិ ត្រជាក់ត្រជុំ និងមានការរីកចម្រើនរុងរឿងលើគ្រប់វិស័យ តាំងពីសម័យសង្គមរាស្ត្រនិយមរហូតដល់ពេលបច្ចុប្បន្ន។

ក្នុងឱកាសដ៏ល្អប្រសើរនោះ លោកជំទាវ **ទេព រង្សី ខៀវភាញារិទ្ធ** និងគណៈប្រតិភូបានថ្វាយកន្ត្រកផ្កាដ៏ស្រស់ល្អ ដែលបង្ហាញពីមនោសញ្ចេតនា ប្រកបដោយការគោរព និងអំណរព្រះរាជគុណដ៏ជ្រាលជ្រៅជាទីបំផុត និងជានិមិត្តរូបនៃការចម្រើននូវសិរីសួស្តី ជ័យមង្គល ព្រះបរមសុខ ព្រះជន្មវស្សាយឺនយូរ ថ្វាយអង្គសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ជាមួយគ្នានេះ លោកជំទាវ **ទេព រង្សី ខៀវភាញារិទ្ធ** បានថ្វាយដង្វាយវត្ថុអនុស្សាវរីយ៍ មានជាក្រណាត់ សំពត់ហូល និងកន្សែងបង់ក ព្រមទាំងថវិកាចំនួន ១០ ០០០ ដុល្លារសហរដ្ឋអាមេរិក ថ្វាយសម្តេចម៉ែ ដើម្បីចូលរួមដង្ហែតាមព្រះរាជសកម្មភាពសង្គមកិច្ចមនុស្សធម៌ដ៏ឧត្តុង្គឧត្តមរបស់សម្តេចម៉ែ ឱ្យសម្រេច



លោកជំទាវ ទេព រង្សី ខៀវកាញ្ញារីទ្ធ និងប្រតិភូអមដំណើរ អញ្ជើញក្រាបថ្វាយបង្គំ
និងថ្វាយគ្រឿងសក្ការៈបូជាព្រះបរមរូបព្រះករុណាព្រះមហាវីរក្សត្រព្រះវររាជ បិតាជាតិខ្មែរ





ទទួលបានមហាជោគជ័យដ៏ត្រចះត្រចង់ បន្ថែមទៀត។

លោកជំទាវ **ទេព រង្សី ខៀវកាញ្ញារីទ្ធ** ក៏បានក្រាបបង្គំថ្លែងអំណរព្រះរាជគុណ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គ សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជទ្រព្យចំនួន ១០ 000 ដុល្លារសហរដ្ឋអាមេរិក ដែលជាព្រះរាជូបត្ថម្ភថ្មីដ៏ថ្លៃថ្លា សម្រាប់ជួយទ្រទ្រង់សកម្មភាព បម្រើប្រទេសជាតិរបស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃក្រសួងព័ត៌មាន។

បន្ថែមពីលើនេះ លោកជំទាវ **ទេព រង្សី ខៀវកាញ្ញារីទ្ធ** បានទូលថ្វាយសារលិខិតថ្វាយព្រះពរ និងឡើងអានរបាយការណ៍ស្តីអំពី សកម្មភាព និងលទ្ធផលសំខាន់ៗរបស់សាខាសមាគមដែលសម្រេចបាននាពេលកន្លងមក ថ្វាយជូនសម្តេចព្រះមហាក្សត្រី ផងដែរ។

មុននឹងបញ្ចប់ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ ជូនឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញ្ញារីទ្ធ** លោកជំទាវ **ទេព រង្សី ខៀវកាញ្ញារីទ្ធ** ព្រមទាំង លោកជំទាវ លោកស្រី គ្រប់រូបក្នុងសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃក្រសួងព័ត៌មាន សូមបានប្រកបនូវសុខភាពល្អ អាយុយឺនយូរ និងទទួលបានជោគជ័យថ្មីៗថែមទៀត ក្នុងភារកិច្ចបម្រើប្រទេសជាតិ៕

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ មានគណបក្សនយោបាយ ចំនួន៩ ទទួលបានអាសនៈ ក្នុងនោះគណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈ ៨០,៦៧ភាគរយ

*អត្ថបទ៖ កែ ផុស , រូបថត៖ AKP-សៅ សុវណ្ណ-ស្រី សាម៉ាន*



សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅសាលាគរុកោសល្យ និងវិក្រិត្យការក្រុងតាខ្មៅ







គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានប្រកាសលទ្ធផលផ្លូវការនៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ មានប្រជាពលរដ្ឋ ៨០,៣២ភាគរយ ស្មើនឹងជាង ៧,៣ លាននាក់ក្នុងចំណោមអ្នកដែលមានឈ្មោះ ក្នុងបញ្ជីឈ្មោះបោះឆ្នោតជាង ៩,២លាននាក់ បានមកចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះ ។






សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងលោកជំទាវ
អញ្ជើញទៅបោះឆ្នោតនៅវិទ្យាល័យវត្តកោះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ




សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និងលោកជំទាវ
អញ្ជើញទៅបោះឆ្នោតនៅវិទ្យាល័យអន្លង់ជ្រៃ ខេត្តត្បូងឃ្មុំ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឱ្យដឹងថា ប្រជាពលរដ្ឋដែលបានអញ្ជើញទៅបោះ ឆ្នោតមានចំនួន ៧ ៣៤៩ ៤២៧នាក់ ស្មើនឹង ៨០,៣២ភាគរយ នៃចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុប ៩ ២០៥ ៦៨១នាក់។ ចំណែកឯសន្លឹកឆ្នោតបានការ គឺមានចំនួន ៧ ២៣៧ ០៣៧ សន្លឹក ហើយសន្លឹកឆ្នោតមិនបានការ មានចំនួន ១៥៧ ៣៩០ សន្លឹក សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ បានប្រព្រឹត្តទៅកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ មានគណបក្សនយោបាយចំនួន ១៧ចូលរួមប្រកួតប្រជែង។ ប៉ុន្តែមានគណបក្សនយោបាយចំនួន៩ បានទទួលអាសនៈដូចតទៅ៖ **១.គណបក្សប្រជាជនកម្ពុជា** ៩ ៣៧៦អាសនៈ។ **២.គណបក្សភ្លើងទៀន** ២ ១៩៨អាសនៈ។ **៣.គណបក្សហ្វ៊ុនស៊ិនប៉ិច** ទទួលបាន ១៩អាសនៈ។ **៤.គណបក្សខ្មែររួបរួមជាតិ** ទទួលបាន ១៣អាសនៈ។ **៥.គណបក្សប្រជាធិបតេយ្យមូលដ្ឋាន** ទទួលបាន ៦អាសនៈ។



អស់ លោក លោកស្រី ចូលរួមសង្កេតការណ៍អញ្ជើញមកពីបណ្តាអង្គការនានា និងស្ថាប័នឯករាជ្យអន្តរជាតិ



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា អញ្ជើញទៅបោះឆ្នោត នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ

៦.គណបក្សខ្មែរស្រឡាញ់ជាតិ ទទួលបាន ៥អាសនៈ។ ៧.គណបក្សយុវជនកម្ពុជា ទទួលបាន ៣អាសនៈ។ ៨.គណបក្សកម្ពុជានិយម ទទួលបាន ១អាសនៈ និងទី៩.គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ទទួលបាន ១អាសនៈ។



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី អញ្ជើញទៅបោះឆ្នោត ក្នុងក្រុងកំពង់ចាម

តាមការប្រកាសព័ត៌មានរបស់ គ.ជ.ប នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ (គ.ជ.ប) បានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ស្របតាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ផែនការមេ និងប្រតិទិនការងាររបស់ខ្លួន។

គ.ជ.ប បានបង្ហាញថា ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ ត្រូវបានបែងចែកជា ៥ក្រុម ដោយក្រុមនីមួយៗ ទទួលបន្ទុកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមឃុំ សង្កាត់ នៃខេត្តចំនួន ៥ លើកលែងតែក្រុមទី៣ ទទួលបន្ទុកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមឃុំ សង្កាត់ នៃខេត្តចំនួន៤ និងសង្កាត់ទាំងអស់ នៃរាជធានីភ្នំពេញ។ ប្រភពដដែលបញ្ជាក់ថា ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលបានចំណាយពេល២ថ្ងៃ គឺនៅថ្ងៃទី១៣ និងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ហើយក្រុមនីមួយៗបានអនុវត្តការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់របស់ខ្លួននៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន នៅទីស្តីការ គ.ជ.ប។


លោកជំទាវកិត្តិសង្គបណ្ឌិត ម៉ែន សំអន អញ្ជើញទៅបោះឆ្នោត នៅសាលាបឋមសិក្សាព្រះសីហនុ ខេត្តស្វាយរៀង





ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ អញ្ជើញទៅបោះឆ្នោត នៅសាលាបឋមសិក្សាទួលគោក ខណ្ឌទួលគោក រាជធានីភ្នំពេញ



ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត និងលោកជំទាវ អញ្ជើញទៅបោះឆ្នោត នៅមណ្ឌលសាលាបឋមសិក្សាទួលគោក ខណ្ឌទួលគោក រាជធានីភ្នំពេញ




ជាលទ្ធផល ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ មិនបានរកឃើញកំហុសណាមួយពាក់ព័ន្ធការគណនាតួលេខលទ្ធផលសម្លេងឆ្នោតគាំទ្រ គណបក្សនយោបាយនីមួយៗ ដែលគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត (គធ.ខប) បានបញ្ជាក់ក្នុងក្រដាសលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥ធខ) តារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត (ទ.១១១០) និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត (ទ.១១១១) ឡើយ។ ភាគីដែលចូលរួមជាសាក្សីទាំងអស់បានឯកភាព និងពុំមានការតវ៉ា ឬជំទាស់អ្វីនោះទេ។

ចំណែកការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតកាលពីថ្ងៃទី៥ និងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះ គ.ជ.ប បានធ្វើឡើងដោយផ្អែកលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត បានបញ្ជូនមក ហើយទម្រង់នេះ ត្រូវបានបង្ហោះនៅលើគេហទំព័រ គ.ជ.ប *electresult.nec.gov.kh*។

លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជា ទទួលបានសម្លេងគាំទ្រ និងទទួលបានអាសនៈក្រុមប្រឹក្សាឃុំសង្កាត់យ៉ាងច្រើនលើសលប់នៅតាមបណ្ដារាជធានី ខេត្តទាំង២៥។ សម្លេងដែលគណបក្សប្រជាជនកម្ពុជា ទទួលបាន



ប្រជាពលរដ្ឋ ព្រះសង្ឃនិមន្តអញ្ជើញទៅបោះឆ្នោត



គឺនាំមុខគណបក្សនយោបាយចំនួន១៦ផ្សេងទៀត ដែលបានចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ៕

# វិភាគ ៖ ការបោះឆ្នោតជាមួយនឹងគុណតម្លៃ និងការរក្សាមូលដ្ឋានអភិវឌ្ឍន៍ជាតិផ្តើមចេញពី ទឹកចិត្តរបស់ប្រជាពលរដ្ឋ

*អត្ថបទ ៖ យិន លាងគង់ សហស្ថាបនិក និងអគ្គនាយកគេហទំព័រ Propertyarea. asia*




សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញបោះឆ្នោត

ប្រជាពលរដ្ឋកម្ពុជា បានធ្វើដំណើរទៅកាន់ការិយាល័យបោះឆ្នោតដោយក្តីសង្ឃឹម និងស្នាមញញឹមដែលពួកគេចង់បានការអភិវឌ្ឍមូលដ្ឋានរបស់ពួកគេរីកចម្រើនបន្តទៀត។

មូលដ្ឋានសុខសន្តិភាព នាំមកនូវស្នាមញញឹម និងការអភិវឌ្ឍ ដែលជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវចូលរួមក្នុងការកសាងជាតិរបស់ពួកគេដើម្បីសម្រេចបានវិបុលភាពបន្ថែមទៀត ហើយពួកគេបានមើលឃើញយ៉ាងប្រត្យក្សនូវ "ការអភិវឌ្ឍជាតិមួយ" ដែលធ្លាប់បានរងភាពខ្ទេចខ្ទាំដោយសារសង្គ្រាមរាប់រយឆ្នាំកន្លងមក។

## ✪អរគុណ និងតម្លៃសន្តិភាព

ពាក្យអរគុណសន្តិភាព និងតម្លៃនៃសន្តិភាព មានតម្លៃ "មិនអាចកាត់ថ្លៃបាន" ក្នុងសន្តានចិត្តរបស់ប្រជាពលរដ្ឋខ្មែរ ដែលពួកគេធ្លាប់ឆ្លងកាត់នូវសោកនាដកម្មរាប់មិនអស់ទឹកភ្នែកឈាមក្លាយជាស្ទឹងកាលពីជាង ៤០ឆ្នាំមុន។

បើទោះមានការអំពាវនាវ និងលើកឡើងពីភាពអវិជ្ជមានរបស់មនុស្សមួយក្រុមទាក់ទងនឹងការបោះឆ្នោតនេះក្តី ក៏ប្រជាពលរដ្ឋខ្មែរប្រមាណ ៨០ភាគរយបានចេញទៅបោះឆ្នោតនៅតាមមូលដ្ឋានរបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ដែលមូលដ្ឋានៃទិន្នន័យនេះបានសបញ្ជាក់ឱ្យឃើញច្បាស់ថា "ប្រជាពលរដ្ឋបានផាត់ក្រុមប្រឆាំងចេញពីចិត្តរបស់ពួកគេ" រួចទៅហើយ ដោយសារ ទី១ ពួកគេមិនមើលឃើញអ្វីដែលមានសារប្រយោជន៍ ដែលក្រុមប្រឆាំងផ្តល់ឱ្យពួកគេ ទី២ ពួកគេបានស្គាល់ពីចរិត និង






ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ អញ្ជើញបោះឆ្នោត

សន្តានរបស់ក្រុមប្រឆាំងច្បាស់ដោយខ្លួនឯង ទី៣ ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការចេះដឹងនិងមានភាពចាស់ទុំខាងនយោបាយជាងមុន ក្នុងការវិនិច្ឆ័យនយោបាយរបស់ពួកគេ ទី៤ ពួកគេចូលចិត្តបំពុល និងបង្កភាពរីករវដល់ប្រទេសជាតិ និងតែងតែរិះគន់លើគណបក្សកាន់អំណាចដោយកំហឹង ជាជាងឈរលើមូលដ្ឋានក្រមសីលធម៌ និងផលប្រយោជន៍សម្រាប់ជាតិ។

### ✪ការជូនសម្រាប់សម្ដេចតេជោ ហ៊ុន សែន

លទ្ធផលនៃការបោះឆ្នោត ដែលនាំមុខដោយគណបក្សប្រជាជននៅទូទាំង២៥រាជធានី ខេត្ត ដែលគណបក្សប្រជាជនកម្ពុជាបាននាំមុខ និងដណ្ដើមបានស្ទើរ ១០០ភាគរយ នៃអាសនៈមេឃុំ ចៅសង្កាត់ ជាលទ្ធផលបង្ហាញនូវការប្ដេជ្ញាចិត្ត ការកសាងនូវមូលដ្ឋានគុណតម្លៃ និងការស្រឡាញ់សន្តិភាពរបស់ពលរដ្ឋខ្មែរក្រោមការដឹកនាំរបស់សម្ដេចតេជោ **ហ៊ុន សែន** ដែលពួកគេមើលឃើញប្រទេសរបស់ខ្លួនមានភាពរីកចម្រើនគ្រប់វិស័យ។

ការដាក់ចេញនូវនយោបាយ ទឹក ភ្លើង ផ្លូវ មនុស្ស របស់សម្ដេចតេជោ តាំងពីទសវត្សរ៍៩០ នៅតែជាមូលដ្ឋានត្រឹមត្រូវសម្រាប់បំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ និងប្រទេស






ប្រជាពលរដ្ឋអញ្ជើញបោះឆ្នោតយ៉ាងស្ងៀមស្ងាត់ និងមានសណ្ដាប់ធ្នាប់



ក្រុមអ្នកសង្កេតការណ៍ និងភាគីពាក់ព័ន្ធពិនិត្យហីបឆ្នោត



ការចាក់សន្លឹកឆ្នោតពីហីបឆ្នោតដើម្បីរាប់សន្លឹកឆ្នោត

ជាតិ។

លទ្ធផលនៃសន្លឹកឆ្នោតដែលគូសដោយប៊ិច អមជាមួយបេះដូងស្រឡាញ់ជាតិ មាតុភូមិ ពិតជាមានតម្លៃមហាសាលដែលមាននៅក្នុងសន្តានចិត្តប្រជាពលរដ្ឋខ្មែរស្ទើរគ្រប់រូប។

សន្លឹកឆ្នោតសន្តិភាព និងការអភិវឌ្ឍ និងសេចក្តីស្រេកឃ្លាននូវការអភិវឌ្ឍជាតិ ។

## ✪មូលដ្ឋាននៃការឈ្នះដ៏រឹងមាំ

គ្មានសមិទ្ធផលណា ទទួលបានមកដោយចៃដន្យឡើយ គ្មានទំនុកចិត្តណាដែលបង្កើតបានដោយភាគីនោះមិនបានធ្វើសកម្មភាព និងសម្បទាន ដោយសន្តានចិត្តស្មោះស បរិសុទ្ធនោះទេ។

ជ័យជម្នះភ្លូកទឹកភ្លូកដីរបស់គណបក្សប្រជាជនកម្ពុជា បានមកពីកត្តាជាច្រើនដូចជា ទី១ ការបញ្ចប់របបអាវខ្មៅអំពើប្រល័យពូជសាសន៍នៅកម្ពុជា ទី២ ការបង្កើតបាននូវសមិទ្ធផលដ៏ធំធេងសម្រាប់ជាតិ តាមរយៈគោលនយោបាយឈ្នះ ឈ្នះដែលបានបញ្ចប់សង្គ្រាមផ្ទៃក្នុង និងរ៉ាំរ៉ៃនៅកម្ពុជា ទី៣ ការសម្រេចបាននូវកំណើនសេដ្ឋកិច្ច ដែលសម្រេចបាននូវការរីកចម្រើនលើសពី ៧ភាគរយ ក្នុងរយៈពេល ២០ឆ្នាំ ដោយធ្វើឱ្យមុខមាត់រាជធានីភ្នំពេញ ផ្លាស់ប្តូរ១៨០ដឺក្រេ និងក្លាយជាប្រទេសខ្លាសេដ្ឋកិច្ចមួយ(ចំណាត់ថ្នាក់ផ្តល់ឱ្យពីធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៦) ទី៤ ការកសាងហេដ្ឋារចនាសម្ព័ន្ធខ្វាត់ខ្វែងគ្រប់ទីកន្លែង ទាំងផ្លូវជាតិ ស្ពានរាប់រយ និងសមិទ្ធផលដ៏អស្ចារ្យដទៃទៀត ពិតជាបានជ្រាប និងដក់ជាប់ក្នុងសន្តានចិត្តខេមរជនគ្រប់ៗរូប ហើយទាំងអស់គ្នាទទួលបានផលប្រយោជន៍ មិនថាអ្នកគាំទ្រ ឬមិនគាំទ្រគណបក្សប្រជាជនកម្ពុជានោះទេ។

បន្ថែមពីលើនេះ គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** បានធ្វើឱ្យមុខមាត់កម្ពុជាលេចត្រដែតលើឆាកអន្តរជាតិ ពិភពលោកស្គាល់កម្ពុជា ជាដែនដីនៃការវិនិយោគ មិនមែនដែនដីនៃទុក្ខសោកនោះទៀតឡើយ។

## ✪ការវាយតម្លៃ និងទទួលស្គាល់ពីក្រុមអ្នកសង្កេតការណ៍អន្តរជាតិ

ជាមួយនឹងបរិយាកាសស្ងប់ស្ងាត់ គ្មានអំពើហិង្សា ជាការបោះឆ្នោតដោយមានការចូលរួម ពីគណបក្សនយោបាយរហូតដល់១៧ បានធ្វើឱ្យអ្នកសង្កេតការណ៍អន្តរជាតិ មកពីស្ថាប័នជាតិចំនួន៧២ និងសហគមន៍អន្តរជាតិចំនួន១៩ បានវាយតម្លៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅកម្ពុជាបានដំណើរការយ៉ាងល្អត្រឹមត្រូវ សេរី មានតម្លាភាព និងយុត្តិធម៌។ ការអះអាងនេះបានធ្វើឡើង នៅក្នុងសន្និសីទសារព័ត៌មានមួយនៅសណ្ឋាគារហៃយ៉ាត់ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២។

ជាមួយគ្នានេះ អង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអាស៊ីប៉ាស៊ីហ្វិកអន្តរជាតិ (CAPDI) ដែលបានបញ្ជូនគណៈប្រតិភូមួយក្រុមចូលរួមជាអ្នកសង្កេតការណ៍អន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ នៅកម្ពុជា នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយវាយតម្លៃថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ នៅកម្ពុជា មានភាពស្ងប់ស្ងាត់សន្តិភាពនិងអហិង្សា។

ចំណែកក្រុមអ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យ ដែលបានចូលរួមជាអ្នកសង្កេតការណ៍អន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ នៅកម្ពុជា កាល




ក្រុមអ្នកសង្កេតការណ៍អន្តរជាតិជាច្រើនស្ថាប័នធ្វើសន្និសីទកាសែតវាយតម្លៃការបោះឆ្នោត
ឃុំ-សង្កាត់នៅកម្ពុជា សម្រាប់អាណត្តិទី៥

ពីថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២នោះ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយវាយតម្លៃថា ការបោះឆ្នោតនេះ បានប្រព្រឹត្តិទៅប្រកបដោយសមធម៌ ទៅតាមក្បួនច្បាប់អន្តរជាតិ។ សេចក្តីប្រកាសរបស់ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យ បានបញ្ជាក់ថា "ក្រុមអ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យ សូមធ្វើការសន្និដ្ឋានដោយបញ្ជាក់ថា ការបោះឆ្នោតនេះបានប្រព្រឹត្តិទៅប្រកបដោយសមធម៌ទៅតាមក្បួនច្បាប់អន្តរជាតិ។ យើងខ្ញុំសូមសម្តែងការកោតសរសើរដល់អ្នកទាំងឡាយណាដែលបានជួយឱ្យការបោះឆ្នោតនេះទទួលបានជោគជ័យ កោតសរសើរទ្វេរដង ជាពិសេស បន្ទាប់ពីគ្រាដ៏លំបាកដែលប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់កន្លងមក"។

ចំណែកអ្នកសង្កេតការណ៍មកពីប្រទេសកូរ៉េ បានមានប្រសាសន៍ឱ្យដឹង ក្រោយបានចូលរួមសង្កេតការណ៍ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥របស់កម្ពុជារួចមក លោក **យុន យ៉ុង ហូ** (Yun Young Ho) អគ្គនាយកនៃអង្គការសហព័ន្ធសន្តិភាពពិភពលោក (UPF) ដែលជាជនជាតិកូរ៉េខាងត្បូង បាននិយាយថា តាមរយៈការបោះឆ្នោត គឺប្រជាធិបតេយ្យរបស់កូរ៉េខាងត្បូង និងកម្ពុជា មានលក្ខណៈស្រដៀងគ្នា។

លោក **យុន យ៉ុង ហូ** បានឱ្យដឹងបែបនេះ ក្នុងសន្និសីទនាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ដើម្បីបង្ហាញពីលទ្ធផលនៃការសង្កេតការណ៍របស់ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ដែលបានចូលរួមសង្កេតការណ៍នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ។

រីឯប្រធានប្រតិភូក្រុមអ្នកសង្កេតការណ៍ជនជាតិចិន បានលើកឡើងថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ បានឆ្លុះបញ្ចាំងពីឆន្ទៈរបស់ពលរដ្ឋកម្ពុជា និងឆ្លុះបញ្ចាំងពីវឌ្ឍនភាពលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាផងដែរ។

លោកបានឱ្យដឹងបែបនេះ ក្នុងសន្និសីទនាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ដើម្បីបង្ហាញពីលទ្ធផលនៃការសង្កេតការណ៍របស់ក្រុមអ្នកសង្កេតការណ៍អន្តរជាតិដែលបានចូលរួមសង្កេតការណ៍នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥។

ប្រធានប្រតិភូក្រុមអ្នកសង្កេតការណ៍ជនជាតិចិន បានបញ្ជាក់យ៉ាងដូច្នេះថា "ថ្ងៃម្សិលមិញ គឺខ្ញុំនិងសហការី បានទៅសង្កេតការណ៍បោះឆ្នោត នៅមណ្ឌលបោះឆ្នោតមួយចំនួននៅក្រុងតាខ្មៅ ខេត្តកណ្តាល និងរាជធានីភ្នំពេញ"។ លោកបន្តថា "យើងសង្កេតឃើញមណ្ឌលបោះឆ្នោតទាំងនោះ មានភាពសណ្តាប់ធ្នាប់ល្អប្រសើរ ប្រជាជនទៅបោះឆ្នោតយ៉ាងរួសរាយ។ អ្វីដែលខ្ញុំនិយាយ គឺខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ដូច្នេះខ្ញុំយល់ថា ការបោះឆ្នោតឃុំ សង្កាត់លើកនេះ គឺជាការបោះឆ្នោតមួយដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព"៕

# សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ត្រូវបានព្រឹទ្ធសភាអនុម័តឯកភាពទាំងស្រុង

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ ព្រឹទ្ធសភា*




ទិដ្ឋភាពរួមនៃសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៤




សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញជាគណៈអធិបតីក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៤

ព្រឹទ្ធសភាបានអនុម័តឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ដើម្បីទប់ស្កាត់ចំណីអាហារដែលគ្មានគុណភាព និងចូលរួមលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

ក្រោយពីបានបញ្ចប់សម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **ម៉ម ប៊ុននាង** អ្នកនាំពាក្យព្រឹទ្ធសភាបានមានប្រសាសន៍ឱ្យដឹងថា អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យឱ្យយោបល់ឯកភាពទាំងស្រុងដោយឥតកែប្រែ ចំនួន ៥៩សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នៃសេចក្តីព្រាងច្បាប់ខាងលើ។

ឯកឧត្តមបានបន្តថា សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារនេះ និងផ្តល់សារៈសំខាន់ក្នុងការកំណត់គោលការណ៍ជាមូលដ្ឋាន ដើម្បីជំរុញឱ្យផលិតផលម្ហូបអាហារមានសុវត្ថិភាព និងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានជាតិ



ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញឡើងរាយការណ៍ ពីវត្តមានចំនួនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួម



សមាជិកព្រឹទ្ធសភា អញ្ជើញឡើងមានមតិយោបល់



ជាធរមាន សំដៅលើកកម្ពស់សុខុមាលភាព និងប្រសិទ្ធភាព នៃការការពារផលប្រយោជន៍អ្នកប្រើប្រាស់ រួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ប្រមុខរាជរដ្ឋាភិបាលធ្លាប់បានគិតគូរសុខុមាលភាពសាធារណៈរបស់ប្រជាពលរដ្ឋយើង ហើយប្រសិនជាយើងឥតមានច្បាប់នេះ យើងឃើញថា អ្នកជួញដូរនូវមុខទំនិញ ឬក៏ម្ហូបអាហារ ឬការនាំចូលជាវត្ថុធាតុដើមក្តី ជាថ្នាំសង្កូវក្តី វាបណ្តាលឱ្យមានការប៉ះពាល់សុខភាពសាធារណៈ ។

សូមបញ្ជាក់ថា: សេចក្តីព្រាងច្បាប់នេះមាន ១១ជំពូក និង ៤៣មាត្រា ត្រូវបានរដ្ឋសភាអនុម័តយល់ព្រមជាលើកដំបូងចំនួន ១០២សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ក្នុងសម័យប្រជុំលើកទី៧ នីតិកាលទី៦ ។

ឯកឧត្តម **អង្គ វង្សវឌ្ឍានា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អមដោយថ្នាក់ដឹកនាំមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម បានឡើងការពារសេចក្តីព្រាងច្បាប់នេះ ដោយបានលើកឡើងថា សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារនេះ និងបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារ



ឯកឧត្តម អង្គ វង្សវឌ្ឍានា អញ្ជើញឡើងការពារសេចក្តីព្រាងច្បាប់

ដោយផ្អែកតាមមូលដ្ឋានវិទ្យាសាស្ត្រ និងការវិភាគរកហានិភ័យ ព្រមទាំងកសាងបាននូវចំណុចអាទិភាព និងការត្រួតពិនិត្យបំពេញបន្ថែមឱ្យគ្នាប្រកបដោយប្រសិទ្ធភាព ។ ឯកឧត្តមបន្តថា ការអនុវត្តដោយពេញលេញនូវច្បាប់នេះ នឹងបង្កើតឱ្យមានលំហូរសេរីនៃទំនិញសេវាកម្ម និងការវិនិយោគ ដើម្បីស្រូបយកអាជីវកម្មអ្នកជំនាញទេពកោសល្យ និងលំហូរនៃដើមទុនដោយសេរី ។

ទន្ទឹមនេះដែរព្រឹទ្ធសភាក៏បានឯកភាពទាំងស្រុងផងដែរ លើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដើម្បីបង្កើនធនធានមនុស្សក្នុងជួរគណៈអភិបាល ដែលជាអង្គប្រតិបត្តិឱ្យមានចំនួនសមស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច កំណើនប្រជាពលរដ្ឋ និងភូមិសាស្ត្រនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

សេចក្តីព្រាងច្បាប់នេះមាន ២មាត្រា ត្រូវបានរដ្ឋសភាអនុម័តយល់ព្រមជាលើកដំបូងចំនួន ១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០២២



សមាជិកព្រឹទ្ធសភា អញ្ជើញឡើងមានមតិយោបល់

ក្នុងសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ។

សូមបញ្ជាក់ថា សេចក្តីព្រាងច្បាប់ចំនួន២ខាងលើ ត្រូវបានព្រឹទ្ធសភាលើកយកមកពិនិត្យពិភាក្សាក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៤ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ហើយក៏បានឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន ៥៩សំឡេង នៃចំនួនសមាជិកសភាទាំងមូល ៕





អង្គប្រជុំព្រឹទ្ធសភា បានឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល



# កម្ពុជា-វៀតណាម ជួបជុំគ្នារំលឹកខួបលើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ១៩៧៧ – ២០ មិថុនា ២០២២)

*អត្ថបទ៖ សាត សុផល, រូបថត៖ ហ៊ុន យុទ្ធគុណ*



សម្តេចតេជោនាយករដ្ឋមន្ត្រី ជួបស្វាគមន៍រាក់ទាក់ជាមួយ ឯកឧត្តម ផាន មិញជីញ នាយករដ្ឋមន្ត្រីវៀតណាម

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **ផាម មិញ ជីញ** នាយករដ្ឋមន្ត្រីវៀតណាម រួមជាមួយថ្នាក់ដឹកនាំ និងអ្នកតស៊ូ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋនៃភាគី កម្ពុជា-វៀតណាម បានណាត់ជួបជុំគ្នានៅតំបន់ព្រំដែនកោះថ្ម X16 ដើម្បីរំលឹកខួបលើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅ ការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត(២០ មិថុនា ១៩៧៧ – ២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានា នៅតំបន់ ប្រវត្តិសាស្រ្ត យោធា តេជោកោះថ្ម X16 ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២។

នៅក្នុងឱកាសជាប្រវត្តិសាស្រ្តនោះ សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា ជោគជ័យលើការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាការផ្តល់យុត្តិធម៌ដល់កម្លាំងតស៊ូរបស់





សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តម ផាម មិញជីញ អញ្ជើញក្នុងពិធីទិវានៃការចងចាំដំណើរឆ្ពោះទៅ
ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត

កម្ពុជាដោយមានការគាំទ្រពីកងទ័ពស្ម័គ្រចិត្តរបស់វៀតណាម។ សម្តេចបានថ្លែងថា កម្ពុជាទទួលរង នូវភាពអយុត្តិធម៌អស់រយៈពេលដ៏យូរ គឺក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ទទួលទណ្ឌកម្ម ដោយអង្គការសហប្រជាជាតិមិនទទួលស្គាល់ ហើយបែរជាទទួលស្គាល់ក្រុមខ្មែរក្រហមឱ្យអង្គុយនៅអង្គការសហប្រជាជាតិទៅវិញ។ ជាមួយគ្នានេះ ប្រទេសវៀតណាម ក៏ត្រូវបានទទួល ទណ្ឌកម្មដោយមានឈ្មោះថា ជាអ្នកឈ្លានពានកម្ពុជា។

សម្តេចតេជោ **ហ៊ុន សែន** បានបន្តថា៖ " ប្រវត្តិសាស្ត្រក៏បានកត់ត្រាទុកចំពោះការស្ម័គ្រចិត្តជួយរបស់កងទ័ពវៀតណាម





ឯកឧត្តម ផាម មីញជីញ នាយករដ្ឋមន្ត្រីវៀតណាម



សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

ចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយបើចង់ដឹងថា កងទ័ពវៀតណាមធ្វើអន្តរាគមន៍សង្គ្រោះប្រជាជនកម្ពុជាខុស ឬត្រូវ ? ត្រូវតែសួរតុលាកាកូនកាត់អង្គការសហប្រជាជាតិ និង កម្ពុជា តើសាលក្រមតុលាការកាត់ទោសខ្មែរក្រហមយ៉ាងដូចម្តេច នេះជាការទទួលស្គាល់របស់អង្គការសហប្រជាជាតិតែម្តង។ ចង់ដឹងទង្វើរបស់វៀតណាមត្រឹមត្រូវ ឬវៀតណាមមិនត្រឹមត្រូវ តើហេតុអ្វីត្រូវកាត់ទោសពួកខ្មែរក្រហមធ្វើអ្វី ? មនុស្សមួយចំនួន ចោទថា ខ្ញុំជាអ្នកដឹកដៃកងទ័ពវៀតណាមឱ្យមកសម្លាប់ប្រជាជន កម្ពុជា តើមានមនុស្សប៉ុន្មាននាក់ដែលស្លាប់ដោយកងទ័ពវៀត ណាម ឬក៏ចាប់ផ្តើមពីប្រជាជនប្រមាណ ៥លាននាក់ឥឡូវប្រជា ជនកម្ពុជាមានទៅដល់ ១៧លាននាក់ ប្រៀបធៀបរយៈពេល ៤៣ ឆ្នាំនៃការរំដោះប្រជាជនកម្ពុជាបានកើតឡើង ១២ លាន នាក់។ អ្នកខ្លះចោទប្រកាន់ខ្ញុំថា **ហ៊ុន សែន** មានទោសឧក្រិដ្ឋ ដែលបាននាំកងទ័ពវៀតណាមមកសម្លាប់ប្រជាជនកម្ពុជា”។

សម្តេចបានស្នើឱ្យអ្នកទាំងនោះទៅសួរអង្គការសហប្រជា ជាតិតែម្តង ហេតុអ្វីចាំបាច់កាត់ទោសមេដឹកនាំខ្មែរក្រហមហើយ តុលាកាកូនកាត់មិនមែនបង្កើតឡើងដោយប្រទេសណាមួយ នោះទេ គឺក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិតែម្តង។ សម្តេចបន្តថា ការកាត់ក្តីទៅលើសំណុំរឿងមួយនេះ ម៉េចកាត់ ទោសឱ្យពួកខ្មែរក្រហម ពីបទឧក្រិដ្ឋកម្មមនុស្សជាតិ និងប្រល័យ ពូជសាសន៍។

សម្តេចតេជោបានបញ្ជាក់ថា ខ្លួនសម្តេចផ្ទាល់បានគិតគូរ













កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទចូលរួមទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ក្រោមធិបតីភាពសម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ផាម មិញជីញ

ទៅលើជម្រើសដល់ពីរលទ្ធភាពវានឹងកើតមាន លទ្ធភាពទី១ គឺលទ្ធភាពប្រើប្រាស់កម្លាំងផ្ទាល់ខ្លួន គិតថា កម្ពុជាប្រើប្រាស់រយៈពេល ៤ទៅ ៥ ឆ្នាំ ទើបអាចរំដោះប្រទេសបានដោយរើយកត្រើយខាងកើតហើយទើបឈានឆ្ពោះទៅទិសខាងលិច ក្នុងករណី ដែល គ្មាន អន្តរាគមន៍ពី កងទ័ពវៀតណាម ប៉ុន្តែ ដោយសារសភាពការណ៍គ្រោះថ្នាក់ ថ្នាក់ដឹកនាំវៀតណាមបានមើលឃើញ ក៏សម្រេចចិត្តអន្តរាគមន៍ដើម្បីសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា ទោះបីថា យើងរងនូវសភាពអយុត្តិធម៌អស់រយៈពេលយូរ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង



ឯកឧត្តម ឧត្តមសេនីយ៍ឯក យី អគ្គមុនី



សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ផាម មិញជីញ អញ្ជើញកាត់ខ្សែបូ
សម្ពោធសមិទ្ធផលនានានៅតំបន់កោះថ្ម x16



ស្តូបតម្កល់រូបសំណាកព្រះអង្គគោកធ្លក



ការដាំដើមឈើក្នុងសួនមិត្តភាព កម្ពុជា-វៀតណាម





រដ្ឋកម្ពុជា ដោយសារអង្គការសហប្រជាជាតិមិនទទួលស្គាល់ ហើយបែរជាទទួលស្គាល់ពួក ប៉ុល ពត ឱ្យអង្គុយនៅអង្គការសហប្រជាជាតិ។ វៀតណាមក៏ត្រូវទទួលទណ្ឌកម្មដោយមានឈ្មោះថា ជាអ្នកឈ្លានពានកម្ពុជា។ ប៉ុន្តែឥឡូវវៀតណាមបានទទួលនូវយុត្តិធម៌ដូចគណបក្សប្រជាជនកម្ពុជា។

សម្តេចតេជោថ្លែងថាជោគជ័យនៃការកាត់ទោសខ្មែរក្រហម




សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ផាន មិញជីញ សម្ពោធផ្ទាំងសិលានៃការដាំឈើធ្នង់មិត្តភាពកម្ពុជា-វៀតណាម

គឺជាការផ្តល់យុត្តិធម៌ដល់កម្លាំង តស៊ូរបស់កម្ពុជាអំពីការគាំទ្រពីកងទ័ពស្ម័គ្រចិត្តវៀតណាម នេះវាចង្អុលបង្ហាញយ៉ាងដូច្នេះ។ សម្តេចក៏បានបញ្ជាក់ដើម្បីឱ្យភ្លឺភ្នែកទាំងអស់គ្នាថា វៀតណាមមិនមែនដកកងទ័ពក្រោយកិច្ចព្រមព្រៀងប៉ារីសទេ វៀតណាមបានដកចេញទាំងស្រុងពីកម្ពុជានៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៨៩ គឺជាង ២ឆ្នាំមុន នៃកិច្ចព្រមព្រៀងប៉ារីស សូមឱ្យភ្លឺភ្នែកទាំងអស់គ្នា។ ពេលនោះជាពេលវេលាដែលយើងបានប្រឹងប្រែងកសាងកម្លាំងដោយខ្លួនឯង បើទោះបីជាក្រោយការដកកងទ័ពវៀតណាមភូមិសាស្ត្រមួយចំនួនត្រូវបាត់បង់ ដូចជា ប៉ៃលិន តំបន់ខ្លះអន្លង់វែង និងតំបន់ខ្លះក៏ដោយចុះ ក៏ប៉ុន្តែយើងទប់ទល់បានសភាពការណ៍ ហើយទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជាក៏ត្រូវបានបញ្ចប់ ព្រោះដំណោះស្រាយនយោបាយសម្រាប់បញ្ហាកម្ពុជា គឺមានទិដ្ឋភាពពីរ ទិដ្ឋភាពផ្ទៃក្នុង និងទិដ្ឋភាពអន្តរជាតិ  អញ្ចឹងពេលដែលកងទ័ពវៀតណាមដកចេញពីកម្ពុជា ទិដ្ឋភាពអន្តរជាតិត្រូវបានបញ្ចប់ នៅសល់តែទិដ្ឋភាពផ្ទៃក្នុង តែប៉ុណ្ណោះ ហើយដែលជាការផ្តល់ឱកាសឱ្យកម្ពុជាសម្របសម្រួលគ្នាតាមរយៈនៃការចូលរួមពីភាគីពាក់ព័ន្ធរាប់ទាំងសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស នោះហើយជាចំណុចប្រវត្តិសាស្ត្រដែលយើងគួររំលឹក  ដែលមានអ្នកខ្លះលើកថា ដោយស្មាតីកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានជាវៀតណាមដកទ័ពនោះជាការផ្ទុយស្រឡះជាមួយនឹងសភាពការណ៍ជាក់ស្តែងដែលបានកើតនៅក្នុងទឹកដីកម្ពុជា។ សូម្បីកងទ័ពវៀតណាមក៏គ្មានទេ ហើយខ្ញុំសូមបញ្ជាក់ដែរ បើនិយាយពីជំនាញការវៀតណាមវិញមាន ក៏ប៉ុន្តែជំនាញការវៀតណាមបានដកនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៨៨ មុនកងទ័ពវៀតណាមដកចេញ។

ដោយឡែក ឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីវៀតណាមបានរំលឹកដែរថា ការដែលវៀតណាមបញ្ជូនកងទ័ពមកជួយកម្ពុជាដើម្បីរំដោះខ្លួនចេញពីរបបប្រល័យពូជសាសន៍ប៉ុល ពត គឺផ្តើមចេញពីប្រពៃណីសាមគ្គី និងការជួយគ្នាទៅវិញទៅមក។ ឯកឧត្តមបានឱ្យដឹងថា ចាប់តាំងពីឆ្នាំ១៩៤៥អង្គភាពវៀតណាមជាច្រើនបានមកកម្ពុជាដើម្បីជួយកសាងកងទ័ពដែលជាកម្លាំងដើមនៃបដិវត្តន៍កម្ពុជាដើម្បីដណ្តើមឯករាជ្យជាតិ ហើយនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ បានរំដោះរាជធានី





អាងទឹកនៅតំបន់ប្រវត្តិសាស្ត្រកោះថ្ម x16

ភ្នំពេញ។ ប៉ុន្តែនៅពេលនោះ កម្ពុជាមិនទទួលបានសុខសន្តិភាព ទេ ហើយបានធ្លាក់ចូលទៅក្នុងសោកនាដកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលជាឧក្រិដ្ឋកម្មមិនអាចអត់ឱនឱ្យបាន ដែល ៤ទសវត្សរ៍ក្រោយមកតុលាការពិសេសកម្ពុជាបានប្រកាសផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរចំពោះអំពើនេះ។

នាយករដ្ឋមន្ត្រីវៀតណាម បានលើកឡើងថា ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ពួកខ្មែរក្រហមបានជាន់ឈ្លីតម្លៃមិត្តភាព សាមគ្គីភាព ដ៏ល្អរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ផងដែរ។ឯកឧត្តមនាយករដ្ឋមន្ត្រីបានបន្តថា ជាការពិត នៅកម្ពុជាមានការបះបោរពីកម្លាំងតស៊ូ ពីប្រជាពលរដ្ឋ នៅក្នុងតំបន់ភូមិភាគបញ្ចឹម ភូមិភាគឦសាន ភូមិភាគ៣០២ ជាដើម ហើយក្នុងគ្រាដ៏លំបាកលំបិននោះ សម្តេចតេជោ **ហ៊ុន សែន** ដែលជាមេបញ្ជាការកងវរៈសេនាធំ រួមជាមួយកម្មាភិបាលស្នេហាជាតិមួយចំនួន បានសម្រេចចិត្តទៅវៀតណាមដើម្បីទទួលបានការគាំទ្រ។ ពីព្រោះនៅពេលនោះ សម្តេចតេជោបញ្ជាក់ហើយថា គ្មានប្រទេសណា អាចជួយក្រៅពីវៀតណាមនោះទេ។ លោកបន្តថា ថ្វីបើវៀតណាមកំពុងមានការលំបាកដោយសាទើបងើបពីសង្គ្រាម ប្រជាជនវៀតណាមបានបង្ហាញនូវការចែករំលែកក្តីលំបាក ដោយ ជួយបណ្តុះបណ្តាល កសាងកម្លាំងស្នូល កម្លាំងបដិវត្តន៍កម្ពុជា ដើម្បីប្រយុទ្ធតតាំងជាមួយ ប៉ុល ពត។

ដោយការខិតខំប្រឹងប្រែងផ្តល់ជំនួយដ៏មានប្រសិទ្ធភាពរបស់វៀតណាម នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធបដិវត្តន៍សង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើង ដោយមានសមមិត្ត **ហ៊ុន សែន** ជាមេបញ្ជាការ ហើយនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ កម្ពុជាបានបង្កើតគណៈកម្មាធិការកណ្តាលនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិ ដែលមានសមមិត្ត **ហេង សំរិន** ជាប្រធាន និងសមមិត្ត **ហ៊ុន សែន** ជាសមាជិក។

សូមបញ្ជាក់បន្ថែមថា តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X16 ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ត្រូវបានរាជរដ្ឋាភិបាលរៀបចំកសាងនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដើម្បីរំលឹកដល់គុណបំណាច់ដ៏ធំធេងមិនអាចកាត់ថ្លៃបានរបស់សម្តេចតេជោ **ហ៊ុន សែន** មានដូចជារូបសំណាកព្រះអង្គគោកធ្លក អគារមិត្តភាព សារមន្ទីរតេជោកោះថ្ម សាលាសំណាក់ វេទិកា ស្រះទឹកស្តេចនាគមហាជ័យ ទីលានចុះចតឧទ្ធម្ភាគចក្រ ទីលានបាល់ទាត់ សួនច្បារ និងផ្លូវអ៊ុតកៅស៊ូជាដើម។

សម្តេចតេជោ **ហ៊ុន សែន** ក៏បានប្រកាសពីគម្រោងរៀបចំតំបន់នេះទៅជាមាត់ច្រកព្រំដែនអន្តរជាតិ ដោយបានបង្កកដីចំនួនជាង ១ហិកតា សម្រាប់កសាងតំបន់សេដ្ឋកិច្ចពិសេស និងពង្រីកផ្លូវថ្នល់ចូលទៅកាន់តំបន់នោះផងដែរ៕

# ប្រធានរដ្ឋសភាកម្ពុជា-ឥណ្ឌាប្តេជ្ញារួមគ្នាពង្រឹងពង្រីកកិច្ចសហប្រតិបត្តិសភានៃប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយ

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ វង្គសភា*




កិច្ចប្រជុំលក្ខណៈទ្វេភាគីរវាងប្រធានរដ្ឋសភាកម្ពុជា-ឥណ្ឌា

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **អំ ប៊ីរឡា** (OM BIRLA) ប្រធានរដ្ឋសភានៃសាធារណរដ្ឋឥណ្ឌា បានប្តេជ្ញារួមគ្នានៅក្នុងការពង្រឹងពង្រីកចំណងមិត្តភាពនិងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋសភាប្រទេសទាំងពីរ ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងអន្តរជាតិ ។ប្រធានរដ្ឋសភាកម្ពុជា និងឥណ្ឌា បានប្តេជ្ញាផងដែរ ក្នុងការជំរុញដល់កិច្ចសហប្រតិបត្តិការខាងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងវប្បធម៌ នៃប្រទេសទាំងពីរឱ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត។ ការប្តេជ្ញាចិត្តខាងលើបានធ្វើឡើងក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម **អំ ប៊ីរឡា** ប្រធានរដ្ឋសភានៃសាធារណរដ្ឋឥណ្ឌានៅព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២២ កន្លងមក ។

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានរៀបចំពិធីទទួលបដិសណ្ឋារកិច្ច ស្វាគមន៍ដំណើរទស្សនកិច្ចរបស់ឯកឧត្តម **អំ ប៊ីរឡា** ជាផ្លូវការ និងមិត្តភាពយ៉ាងអធិកអធ័មជាទីបំផុត នៅវិមានរដ្ឋសភា ព្រឹកថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២២ ក្រោយពីពិធីទទួលបដិសណ្ឋារកិច្ចជាផ្លូវការ និងការជួបសំដែងការគួរ



សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

សមជាមួយគ្នារួចមក សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** និងឯកឧត្តម **អំ ប៊ីរឡា** បានពិភាក្សាការងារទ្វេភាគីនៅក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ រដ្ឋសភាប្រទេសទាំងពីរ ក្នុងបរិយាកាសស្និទ្ធស្នាលជាទីបំផុត ។ ថ្នាក់ដឹកនាំរដ្ឋសភាកម្ពុជា និងឥណ្ឌា បានសម្តែងក្តីសប្បាយរីករាយ ជាទីបំផុត ចំពោះសមិទ្ធផលជាច្រើន ដែលកើតចេញពីទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរជាប្រវត្តិសាស្រ្តនៅក្នុងរយៈពេល ៧០ឆ្នាំមកនេះ។ ប្រជាជនកម្ពុជា -ឥណ្ឌា មានទំនាក់ទំនងជាប្រវត្តិសាស្រ្ត ដែលមានវប្បធម៌ជំនឿសាសនាស្រដៀងគ្នា ។



ឯកឧត្តម អំ បឹរឡា ប្រធានរដ្ឋសភានៃសាធារណរដ្ឋសភាឥណ្ឌា

សម្តេចអគ្គមហាពញាចក្រី បានលើកឡើងថា ចាប់តាំងពីនីតិកាលទី១មករដ្ឋសភាកម្ពុជា បាននិងកំពុងបន្តពង្រឹងពង្រីកទំនាក់ទំនងការទូតសភា តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយបណ្តាសភានានានៅក្នុងតំបន់និងសកលលោក សំដៅរួមចំណែកលើកកម្ពស់ថែរក្សាសន្តិភាពស្ថិរភាពនិងការអភិវឌ្ឍនៅក្នុងក្របខ័ណ្ឌតំបន់និងសកលលោក ។ រដ្ឋសភាកម្ពុជា បានបង្កើតក្រុមមិត្តភាពសភាកម្ពុជា ជាមួយសភាជាង១០០ប្រទេសនៅលើសកលលោក ក្នុងនោះ ក៏មានរដ្ឋសភាឥណ្ឌាផងដែរ ក្នុងបំណងជំរុញលើកកម្ពស់ ទំនាក់ទំនង មិត្តភាពនិងសហប្រតិបត្តិការ ជាលក្ខណៈទ្វេភាគី ដើម្បីផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ។

ឯកឧត្តម **អំ បឺរឡា** បានសម្តែងការគាំទ្រចំពោះប្រសាសន៍លើកឡើង របស់សម្តេចប្រធានរដ្ឋសភា និងបានគូសបញ្ជាក់ថា តាមរយៈការជួបសន្ទនា ជាទៀងទាត់របស់ថ្នាក់ដឹកនាំប្រទេសទាំងពីរ បានធ្វើឱ្យទំនាក់ទំនង ជាប្រវត្តិសាស្ត្រកម្ពុជានិងឥណ្ឌាកាន់តែស៊ីជម្រៅ ។

ឯកឧត្តមបានគូសបញ្ជាក់ថា ប្រទេសឥណ្ឌា បានឱ្យតម្លៃជាសំខាន់ ចំពោះទំនាក់ទំនងប្រទេសទាំងពីរ នឹងមានគម្រោងអភិវឌ្ឍន៍ជាច្រើនរបស់ឥណ្ឌានៅកម្ពុជា ដូចជាវិស័យសុខាភិបាល កសិកម្ម និងបច្ចេកវិទ្យា ដែលគម្រោងទាំងអស់នោះ បានផ្តល់ផលប្រយោជន៍ជាច្រើន ដល់ប្រជាជនកម្ពុជា ។

នៅក្នុងឱកាសនោះ ឯកឧត្តមប្រធានរដ្ឋសភាឥណ្ឌា បានគោរពអញ្ជើញសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បំពេញទស្សនកិច្ចនៅប្រទេសឥណ្ឌានាពេលខាងមុខ ។វត្តមានសម្តេចនៅប្រទេសឥណ្ឌាមានសារៈសំខាន់ ដើម្បីចូលរួមក្នុងវេទិកាអាស៊ាន-ឥណ្ឌា និងក្នុងឱកាសប្រទេសទាំងពីរ ប្រារព្ធខួបលើកទី ៧០នៃចំណងការទូត និងចំពេលដែលឥណ្ឌា ប្រារព្ធខួបលើកទី៧៥នៃទិវាឯករាជ្យជាតិ ក៏ដូចជា ឱកាសសម្ពោធអគាររដ្ឋសភាថ្មីផងដែរ ។

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានទទួលសំណើរបស់គណៈប្រតិភូសភាឥណ្ឌា ។ ជាមួយគ្នានេះ សម្តេចបានគោរពអញ្ជើញ គណៈប្រតិភូសភាឥណ្ឌា មកចូលរួមមហាសន្និបាត AIPA លើកទី ៤៣ដែលសភាកម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះនៅខែវិច្ឆិកាខាងមុខ ក្នុងនាមជាសភាសង្កេតការណ៍ ។

សម្តេចបានស្នើសូមភាគីឥណ្ឌាពន្លឿនដល់ការបង្កើតឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរបន្តគាំទ្រការបណ្តុះបណ្តាល ធនធានមនុស្ស នៅកម្ពុជា និងជួយកិច្ចសហការ ក្នុងការអភិរក្សនិងស្តារបេតិកភណ្ឌវប្បធម៌ និងជំរុញដល់រដ្ឋាភិបាលឥណ្ឌាអនុវត្តការស្តារបេតិកភណ្ឌប្រាសាទបាយ័នព្រះវិហារ ដែលឥណ្ឌាជាសហប្រធាន ICC ព្រះវិហារនោះ ។

ឯកឧត្តម **អំ បឺរឡា**បានទទួលសំណើរបស់សម្តេចប្រធានរដ្ឋសភានឹងសន្យាថានិងផ្តល់ចម្លើយជាវិជ្ជមានជូនសម្តេចតាមរយៈឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជានាពេលក្រោយទៀត៕



សមាសភាព សមភាគី សភាឥណ្ឌា





សមាសភាព សមភាគី សភាកម្ពុជា

# សម្ដេចតេជោ ហ៊ុន សែន ៖ អាស៊ាន មិនត្រូវការជ្រើសរើសមហាអំណាចណាមួយនោះឡើយ

*អត្ថបទ ៖ សាត សុផល , រូបថត ៖ ទទក*




សម្ដេចតេជោ ហ៊ុន សែន និងវាគ្មិនបរទេសក្នុងវេទិកាជជែកពីយុទ្ធសាស្ត្ររបស់អាស៊ានឆ្លើយតបនឹងវិបត្តិតំបន់ និងពិភពលោក




សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមវេទិកាជជែកពិភាក្សា



សម្ដេចតេជោ ហ៊ុន សែន ជួបជាមួយលោក Klaus Schwab ស្ថាបនិក និងជាប្រធានវេទិកាសេដ្ឋកិច្ចពិភពលោក

សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងនាមជាប្រធានអាស៊ាន បានគូសបញ្ជាក់ថាអាស៊ានមានគោលការណ៍ច្បាស់ គឺមិនត្រូវការជ្រើសរើសមហាអំណាចណាមួយនោះឡើយ ។ សម្ដេចតេជោបានថ្លែងដូច្នេះនៅក្នុងវេទិកាជជែកពីយុទ្ធសាស្ត្ររបស់អាស៊ានឆ្លើយតបនឹងវិបត្តិតំបន់ និងពិភពលោកនៃវេទិកាសេដ្ឋកិច្ចពិភពលោក ។

វេទិកាសេដ្ឋកិច្ចពិភពលោក បានរៀបចំឡើងនៅទីក្រុងដាវ៉ូស-ក្លូស្ទើរ ប្រទេសស្វីស កាលពីថ្ងៃទី២៤ខែឧសភា ឆ្នាំ២០២២ នេះ បានបើកកិច្ចពិភាក្សាដ៏ពិសេសមួយលើប្រធានបទ «ទិដ្ឋភាពយុទ្ធសាស្ត្រស្ដីពីអាស៊ាន និងតួនាទីជាប្រធានអាស៊ានរបស់




វេទិកាជជែកពីយុទ្ធសាស្ត្ររបស់អាស៊ានឆ្លើយតបនឹងវិបត្តិតំបន់ និងពិភពលោក

កម្ពុជាក្នុងឆ្នាំ២០២២»។ ក្នុងកិច្ចពិភាក្សាធ្វើឡើងដោយមានវាគ្មិនសំខាន់ៗ៥រូប រួមមាន៖

សម្តេចតេជោ **ហ៊ុន សែន** ក្នុងនាមជាប្រធានអាស៊ាន និងវាគ្មិនជាអ្នកជំនាញសេដ្ឋកិច្ច៤រូបផ្សេងទៀត មកពីសឹង្ហបុរី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងអឺរ៉ុប ។

កិច្ចពិភាក្សាបានផ្តោតជាសំខាន់ពីភាពប្រឈមរបស់អាស៊ាន ចំពោះមុខវិបត្តិនៃការប្រកួតប្រជែងរបស់ប្រទេសមហាអំណាច ជាពិសេសរវាងចិន និងអាមេរិក បញ្ហាជម្លោះដែនសមុទ្រ វិបត្តិស្បៀងអាហារ សន្តិសុខថាមពល បម្រែបម្រួលអាកាសធាតុ និងវិបត្តិនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនផងដែរ។ វាគ្មិនសេដ្ឋកិច្ចនីមួយៗ បានលើកបង្ហាញពីបញ្ហាប្រឈម និងផលលំបាករបស់អាស៊ាន ហើយក៏បានបង្ហាញនូវគន្លឹះមួយចំនួនដើម្បីឈានទៅដោះស្រាយបញ្ហានេះដែរ ។

សម្តេចតេជោ **ហ៊ុន សែន** វាគ្មិនថ្នាក់ខ្ពស់លើវេទិកានៃកិច្ចពិភាក្សានេះ ត្រូវបានផ្តល់អាទិភាពឱ្យធ្វើសេចក្តីសន្និដ្ឋានរួមចុងក្រោយទៅលើប្រធានបទដែលបានលើកមកជជែក ក៏ដូចជាបង្ហាញអាទិភាពមួយចំនួនដែលកម្ពុជានឹងប្រកាន់យកក្នុងនាមជាប្រធានអាស៊ាន ។

សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ក្តោបទៅលើទិដ្ឋភាពប្រឈមសំខាន់ៗមួយចំនួនមានដូចជា ការប្រឈមនឹងការប្រកួតប្រជែងរបស់មហាអំណាច គំនិតផ្តួចផ្តើមឥណ្ឌូ-ប៉ាស៊ីហ្វិក ជម្លោះដែនសមុទ្ររវាងចិន និងប្រទេសសមាជិកអាស៊ាន និងវិបត្តិសង្គ្រាមឈ្លានពានរបស់រុស្ស៊ី ទៅលើអ៊ុយក្រែន។ សម្តេចតេជោបានគូសបញ្ជាក់ថាអាស៊ានគឺជាសហគមន៍មួយកំពុងស្ថិតនៅក្នុងស្ថានភាពដែលមានផលប៉ះពាល់មកលើខ្លួន។ ពាក់ព័ន្ធការប្រកួតប្រជែងរវាងមហាអំណាចចិន និងអាមេរិក សម្តេចតេជោ បានគូសបញ្ជាក់ថា អាស៊ាន មិនត្រូវជ្រើសរើសនរណានោះទេ។ សម្តេចតេជោ បានគូសបញ្ជាក់ដូច្នេះ «ខ្ញុំក៏បានកត់សម្គាល់ថា មិត្តភ័ក្តិរបស់យើងជាមហាអំណាចក៏បានប្រាប់មកយើងថា មិនមានភាពចាំបាច់ឱ្យជ្រើសរើសនរណានោះទេ ហើយយើងបានបញ្ជាក់ទៅវិញថា បើអស់លោកឱ្យខ្ញុំជ្រើសរើស ក៏យើងខ្ញុំអត់ជ្រើសរើសដែរ» ។

សម្តេចតេជោ បានលើកឡើងទៀតថា «ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ បានធ្វើឱ្យអាស៊ានរបស់យើងជួបការលំបាកយ៉ាងច្រើន»។ សម្តេចតេជោ ក៏បានរំលឹកដល់គំនិតផ្តួចផ្តើមឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលជាគំនិតផ្តួចផ្តើម ដើម្បីទប់ទល់នឹងឥទ្ធិពលរបស់ចិននៅអាស៊ីអាគ្នេយ៍។ តែសម្តេចតេជោ បានសង្កត់ធ្ងន់ថា គំនិតផ្តួចផ្តើមណាក៏ដោយដែលទាក់ទងជាមួយ




វាគ្មិនសំខាន់ៗ៥រូប និងសម្តេចតេជោក្នុងវេទិកាជជែក




សម្តេចតេជោក្នុងឱកាសនិវត្តមកដល់មាតុភូមិវិញ



មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា និងតំណាងបរទេសចូលរួមក្នុងវេទិកាជជែក




សម្តេចតេជោ និងវាគ្មិនបរទេស

ឥណ្ឌូ-ប៉ាស៊ីហ្វិក គឺត្រូវបម្រើដល់គោលបំណង៣យ៉ាង រួមមាន៖

ទី១-បម្រើដល់សន្តិភាព និងការអភិវឌ្ឍ

ទី២-មិនប្រឆាំងនឹងប្រទេសណា និង

ទី៣-បម្រើដល់មជ្ឈភាពរបស់អាស៊ាន ។

សម្តេចតេជោ បានលើកឡើងដែរថា អាស៊ាន ក៏មានគំនិតផ្តួចផ្តើមរបស់ខ្លួនពាក់ព័ន្ធនឹងឥណ្ឌូ-ប៉ាស៊ីហ្វិកនេះផងដែរ។ សម្តេចស្នើដល់ប្រទេសពាក់ព័ន្ធគំនិតផ្តួចផ្តើមនេះ គាំទ្រដល់គំនិតផ្តួចផ្តើមបង្កើតដោយអាស៊ាន ។

ពាក់ព័ន្ធបញ្ហាជម្លោះដែនសមុទ្ររវាងចិន និងប្រទេសសមាជិកអាស៊ាន សម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាក់ថា អាស៊ាន នៅតែបន្តជំរុញអនុវត្តន៍ឱ្យបានខ្ជាប់នូវក្រមប្រតិបត្តិ DOC ដែលដាក់ចេញពេលកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០០២ ហើយឈានទៅសម្រេចឱ្យបាននូវក្រមប្រតិបត្តិ COC។ ជាពិសេសការជំរុញឱ្យមានកិច្ចពិភាក្សារវាងភាគីមានជម្លោះ ។

សម្តេចតេជោ **ហ៊ុន សែន** ក៏បានលើកឡើងដែរថា បញ្ហាដែលប្រឈមខ្លាំងសម្រាប់ពិភពលោក និងអាស៊ាន គឺសង្គ្រាមឈ្លានរបស់រុស្ស៊ីទៅលើប្រទេសអ៊ុយក្រែន។ សម្តេចតេជោ **ហ៊ុន សែន** បានលើកឡើងបច្ចុប្បន្នសង្គ្រាមនេះ បង្កើតត្រឹមវិបត្តិថាមពល តែទៅពេលខាងមុខនឹងមានវិបត្តិស្បៀងអាហារថែមទៀតផង ។

ពាក់ព័ន្ធនឹងសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែននេះ សម្តេចតេជោ **ហ៊ុន សែន** ក៏បានលើកឡើងដែរថា ការប្រើវិធានដាក់ទណ្ឌកម្មគួរតែបញ្ឈប់ ព្រោះមិនមានប្រយោជន៍នោះឡើយ ហើយបង្កផលប៉ះពាល់ទាំងប្រទេសដាក់ទណ្ឌកម្ម និងប្រទេសដែលគេដាក់ទណ្ឌកម្ម ។

ក្នុងបទអន្តរាគមន៍នោះ សម្តេចតេជោ បានគូសបញ្ជាក់ថា ដើម្បីដោះស្រាយវិបត្តិដែលកំពុងប្រឈមចំពោះអាស៊ានគឺអាស៊ាននឹងខិតខំជំរុញការធ្វើសមាហរណកម្មអាស៊ានឱ្យបានឆាប់តាមរយៈកិច្ចព្រមព្រៀងនានា ជាពិសេសកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ៕

# ការទទួលរៀបចំធ្វើម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេម លើកទី៣២ ជា ប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា

*អត្ថបទ៖ ស៊ីម មង្គល , រូបថត៖ AKP*




សម្តេចពិជ័យសេនា ទៀ បាញ់ មានប្រសាសន៍

« មោទនភាពដ៏ឧត្តុងឧត្តម នៃការទទួលរៀបចំធ្វើម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើទី១២ ឆ្នាំ២០២៣ ជាប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា »។ នេះជាប្រសាសន៍របស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានគណៈកម្មាធិការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ (CAMSOC) ក្នុងឱកាសដឹកនាំគណៈប្រតិភូ និង





ពិធីដង្ហែទង់ស៊ីហ្គេមមកកាន់ប្រទេសកម្ពុជា



ការដង្ហែទង់ស៊ីហ្គេមពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

អត្តពលិកកម្ពុជាសរុប១៨០នាក់វិលត្រឡប់មកមាតុប្រទេសនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ថ្ងៃទី២៤ខែឧសភា ឆ្នាំ២០២២ ដែលជាក្រុមចុងក្រោយបំផុតបន្ទាប់ពីបានបំពេញបេសកកម្មជាប្រវត្តិសាស្ត្រនៅព្រឹត្តិការណ៍ស៊ីហ្គេមលើទី៣១ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

សម្តេចពិជ័យសេនា **ទៀ បាញ់** បានមានប្រសាសន៍បន្ថែមទៀតថា អបអរសាទរ អរគុណសន្តិភាព អរគុណនយោបាយឈ្នះ-ឈ្នះ អរគុណស្ថាបនិកប្រតិបត្តិករនយោបាយឈ្នះ-ឈ្នះ



ការវិលត្រឡប់របស់កីឡាករ កីឡាការិនី និងពិធីដង្ហែទង់ស៊ីហ្គេមនៅកម្ពុជា




ឯកឧត្តម ថោង ខុន ទទួលទង់សម្រាប់ការរៀបចំធ្វើម្ចាស់ផ្ទះកីឡាស៊ីហ្គេម



ពិធីប្រគល់ - ទទួលទង់ស៊ីហ្គេម

ដែលនាំនូវសន្តិភាព និងឯកភាព នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយ ទៀត នៃការទទួលធ្វើម្ចាស់ផ្ទះស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ជាប្រវត្តិសាស្ត្រដំបូងរបស់កម្ពុជា។ ប្រជាពលរដ្ឋខ្មែរក្នុង និងក្រៅប្រទេសសូមត្រៀមលក្ខណៈសម្បត្តិទទួលស្វាគមន៍ប្រតិភូកីឡា នៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ និងភ្ញៀវអន្តរជាតិមកពីគ្រប់ទិសទីជុំវិញពិភពលោកមកទទួលយកនូវស្នាមញញឹមរួសរាយ រាក់ទាក់ ស្លូតបូត សុភាពរាបសា ថ្លៃថ្នូររបស់ប្រជាជនកម្ពុជា ដែលកំពុងរស់នៅក្នុងសុខសន្តិភាពពេញលេញ និងការអភិវឌ្ឍលើគ្រប់វិស័យ។ សម្តេចពិជ័យសេនា បានថ្លែងកោតសរសើរដល់អត្តពលិកកម្ពុជា ដែលបានខិតខំអស់ពីសមត្ថភាពដណ្តើមបានមេដាយមាស ប្រាក់ និងសំរិទ្ធ សរុបចំនួន៦៣គ្រឿងជូនជាតិ ដែលជាកំណត់ត្រាប្រវត្តិសាស្ត្រថ្មីមួយរបស់កម្ពុជា។ កម្ពុជាដណ្តើមបានមេដាយមាស៩គ្រឿង ប្រាក់១៣គ្រឿង និងសំរិទ្ធ៤១គ្រឿង សរុប៦៣គ្រឿង។

សម្តេចតេជោ **ហ៊ុន សែន** បានគូសបញ្ជាក់ថា « ក្រៅពីជោគជ័យ នៃការគ្រប់គ្រងកូវីដ យើងក៏ទើបទទួលបាននូវទង់សម្រាប់ការរៀបចំធ្វើជាម្ចាស់ផ្ទះ នៃការប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣ ខាងមុខនេះ ដែលសម្តេចពិជ័យសេនា **ទៀ បាញ់** រួមជាមួយឯកឧត្តមរដ្ឋមន្ត្រី **ថោង ខុន** បានរួមគ្នាដង្ហែមកមាតុប្រទេសជាមួយនឹងគ្រឿងឥស្សរិយយសយ៉ាងច្រើន ជាមេដៃមាស មេដៃប្រាក់ មេដាយសំរិទ្ធ ដែលកើនឡើងទ្វេដង បើប្រៀបធៀបទៅនឹងស៊ីហ្គេមមុនៗ។ នេះ គឺជាចំណុចរបត់នៃប្រវត្តិសាស្ត្រ ដែលកម្ពុជាយើងបានឆ្លងកាត់នៅដំណាក់កាលដ៏ល្អ ដែលពង្រឹងវិស័យកីឡា។ សម្តេចតេជោក៏បានអរគុណចំពោះជនរួមជាតិ ក៏ដូចជាកីឡាករ កីឡាការិនី និងថ្នាក់ដឹកនាំ ដែលបានធ្វើពិធីដង្ហែទង់ស៊ីហ្គេម ហើយក៏ដូចជាដង្ហែចំពោះគ្រឿងឥស្សរិយយសទាំងឡាយសម្រាប់ក្រោយការប្រកួត មកកាន់មាតុប្រទេសវិញ និងចូលទៅទីស្នាក់ការគណៈកម្មាធិការអូឡាំពិកកម្ពុជា។ ស៊ីហ្គេមនឹងត្រូវប្រព្រឹត្តទៅនៅឆ្នាំ២០២៣ ខាងមុខដែលជាការរៀបចំគ្រោងទុករបស់យើងអស់ជាច្រើនឆ្នាំមកហើយ។»

សូមបញ្ជាក់ថា ម្ចាស់ផ្ទះស៊ីហ្គេមលើកទី៣១ វៀតណាម



ការប្រារព្ធពិធីបិទការប្រកួតស៊ីហ្គេមលើកទី៣១ជាផ្លូវការនៅប្រទេសវៀតណាម

បានប្រារព្ធពិធីបិទការប្រកួតជាផ្លូវការ កាលពីយប់ថ្ងៃ៨រោច ខែពិសាខ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃច័ន្ទទី ២៣ ខែឧសភា ឆ្នាំ២០២២ ហើយបានផ្ទេរទង់ស៊ីហ្គេមជូនដល់កម្ពុជា ដែលជាម្ចាស់ផ្ទះបន្តវេនស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣។ ពិធីប្រគល់-ទទួលទង់ស៊ីហ្គេមនេះបានធ្វើឡើងក្នុងពិធីបិទព្រឹត្តិការណ៍ស៊ីហ្គេមយ៉ាងអធឹកអធម ដោយមានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់របស់ សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងជាប្រធានគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣។

សម្រាប់ថ្ងៃពិសេសក្នុងដំណើរឆ្ពោះទៅព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៅកម្ពុជាឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ក្នុងនាមប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងជាប្រធានក្រុមប្រឹក្សាសហព័ន្ធកីឡា អាស៊ីអាគ្នេយ៍ បានអញ្ជើញទទួលទង់ស៊ីហ្គេមផ្ទាល់ពីភាគីវៀតណាម ដើម្បីបន្តវេនធ្វើម្ចាស់ផ្ទះនាឆ្នាំក្រោយ។ ជាមួយនឹងការទទួលទង់ស៊ីហ្គេមជាផ្លូវការនេះ កម្ពុជាបានត្រៀមខ្លួន រួចជាស្រេចប្រកបដោយភាពជឿជាក់ និងក្តីសង្ឃឹមខ្ពស់ក្នុងការរៀបចំទទួលធ្វើម្ចាស់ផ្ទះស៊ីហ្គេមឆ្នាំ២០២៣ ជាប្រវត្តិសាស្ត្រដំបូងរបស់ខ្លួនក្រោយពីព្រឹត្តិការណ៍កីឡាថ្នាក់តំបន់អាស៊ីអាគ្នេយ៍រៀងរាល់២ឆ្នាំម្តង ចំនួន៣១លើក ស្មើនឹង៦៤ឆ្នាំ។ ក្រោយទទួលបានទង់ស៊ីហ្គេមជាផ្លូវការនៅល្ងាចថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២។ CAMSOC និង NOCC បានរៀបចំពិធីដង្ហែទង់ស៊ីហ្គេមពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមមហាវិថីសំខាន់ៗ មួយចំនួនក្នុងរាជធានីភ្នំពេញ ឆ្ពោះទៅវិមានឯករាជ្យ ហើយបន្តដង្ហែទៅបញ្ចប់នៅទីស្នាក់ការ NOCC។ តាមរយៈនេះ NOCC បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួមអបអរសាទរពិធីដង្ហែទង់ស៊ីហ្គេម និងអត្តពលិកកម្ពុជា ដែលដណ្តើមបានមេដាយជូនជាតិសរុបចំនួន៦៣គ្រឿង។ ការវិលត្រឡប់របស់ក្រុមប្រតិភូកីឡាកម្ពុជាចុងក្រោយបំផុតចំនួន១៨០នាក់ ក្រោយការដឹកនាំរបស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាអនុប្រធានអចិន្ត្រៃ CAMSOC និងជាប្រធានក្រុមប្រឹក្សាកីឡាអាស៊ីអាគ្នេយ៍រួមទាំងប្រតិភូលើប្រភេទកីឡាមួយចំនួន អ្នកសម្តែងសិល្បៈវប្បធម៌ គុនល្បុក្កតោ ក្រោយបញ្ចប់បេសកកម្មនៅក្នុងពិធីបិទផ្លូវការស៊ីហ្គេមនៅទីក្រុងហាណូយ៕



# សម្តេចពិជ័យសេនា ទៀ បាញ់ អញ្ជើញបញ្ចុះបឋមសិលាបើកការដ្ឋាន សាងសង់រោងជាងជួសជុលនាវា ផែសំចត និងស្តារឃ្លង នៅមូលដ្ឋានសមុទ្រ

*អត្ថបទ៖ ង្វី សុមុនី , ប្រភព៖ មន្ទីរព័ត៌មានព្រះសីហនុ*




សម្តេចពិជ័យ សេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

កាលពីព្រឹកថ្ងៃពុធ៩កើត ខែជេស្ឋ ឆ្នាំខាលចត្វាស័កព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **វ៉ាង វិនធាន** (Wang Wentian) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិត ចិនប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់រោងជាងជួសជុលនាវាផែសំចតនិងស្តារឃ្លង នៅមូលដ្ឋានសមុទ្រ ដោយមានការចូលរួមពីឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងអនុព័ន្ធយោធា



នាយ នាយរង និងពលនាវិកកងទ័ពជើងទឹកអញ្ជើញចូលរួម



ឯកឧត្តម វ៉ាង វិនធាន ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន

ប្រចាំព្រះរាជាណាចក្រកម្ពុជា និងអភិបាលខេត្តដែលនៅជាប់នឹងសមុទ្រផងដែរ។

ឯកឧត្តម **គួច ចំរើន** អភិបាលខេត្ត ព្រះសីហនុមានប្រសាសន៍ស្វាគមន៍ពិធីបើកការដ្ឋានសាងសង់រោងជាងជួសជុលនាវាផែសំចត និងស្តារឃ្លងនៅមជ្ឈមណ្ឌលទំនើបកម្មមូលដ្ឋានសមុទ្រសម្រាប់កងទ័ពជើងទឹកមូលដ្ឋានសមុទ្រដើម្បីលើកកម្ពស់កម្រិតវិស័យការពារជាតិក្នុងស្មារតីកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងការកសាងសហគមន៍វាសនារួម ដែលជាគុណប្រយោជន៍ដល់សន្តិភាព ស្ថិរភាព និងវិបុលភាព នៅក្នុងនិងក្រៅតំបន់។

ឯកឧត្តម **វ៉ាង វិនធាន** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា បានមានប្រសាសន៍ក្នុងការចូល



ឯកឧត្តម គួច ចំរើន អភិបាលខេត្ត ព្រះសីហនុ






នាយ នាយរង និងពលនាវិកកងទ័ពជើងទឹកអញ្ជើញចូលរួម



សម្តេចពិជ័យសេនា ទៀ បាញ់ អញ្ជើញបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់រោងជាងជួសជុលនាវា ផែសំចត និងស្តារឃ្លង់ នៅមូលដ្ឋានសមុទ្រ



សម្តេចពិជ័យសេនា ទៀ បាញ់

រួមបើកការដ្ឋាន ដោយអបអរសាទរ ថ្នាក់ដឹកនាំប្រទេសទាំងពីរ ដាក់ចេញនូវគ្រប់វិស័យទទួលបានផ្លែផ្កា ជំរុញទំ នាក់ទំនងទ្វេភាគីជាបងប្អូនដែកថែបជាដៃគូយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការដែកថែបរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅ លើកស្ទួយកងទ័ពជើងទឹកកម្ពុជា ការផ្តល់ជំនួយដល់កងទ័ពកម្ពុជា សំដៅពង្រឹងសមត្ថភាពលើវិស័យការពារជាតិ ដើម្បីបុព្វហេតុអធិបតេយ្យភាព បូរណភាពទឹកដី សន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។

សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានមានប្រសាសន៍ថា ការដ្ឋានសាងសង់




សម្តេចពិជ័យសេនា ទៀ បាញ់ អញ្ជើញបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់រោងជាងជួសជុលនាវា ផែសំចត និងស្តារឃ្លង់ នៅមូលដ្ឋានសមុទ្រ




ពិធីបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់រោងជាងជួសជុលនាវា ផែសំចត

រោងជាងជួសជុលនាវាផែសំចត និងស្ពានឃ្លង នៅមជ្ឈមណ្ឌលទំនើបកម្មមូលដ្ឋានសមុទ្រនេះ ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនស្របពេលដែលព្រះរាជាណាចក្រកម្ពុជារៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ប្រកបដោយប្រជាធិបតេយ្យបរិយាកាសសេរី តម្លាភាព មានភាពសុខសាន្ត គ្មានអំពើហិង្សា គោរពអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួននូវច្បាប់នីតិវិធី និងបទបញ្ជាទាំងឡាយរបស់គណៈកម្មធិការជាតិរៀបចំការបោះឆ្នោត។ សម្តេចសេនាពិជ័យ **ទៀ បាញ់** បានបន្តថា « ខ្ញុំមានជំនឿយ៉ាងមុតមាំ បន្ទាប់ពីសំណង់អគារជួសជុលនាវាផែសំចត និងស្ពានឃ្លង ដែលបំពាក់ដោយឧបករណ៍សម្ភារបច្ចេកទេសទំនើបសាងសង់រួចផ្តល់ការងាយស្រួលដល់នាយ នាយរង និងពលនាវិកកងទ័ពជើងទឹកកាន់តែមានសមត្ថភាព ចំណេះដឹងប្រកបដោយជំនាញបច្ចេកទេសវិជ្ជាជីវៈ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន និងអនាគតយូរអង្វែង រួមចំណែកយ៉ាងសំខាន់ក្នុងការការពារឯករាជ្យ សន្តិភាព អធិបតេយ្យ បូរណភាពទឹកដី និងរាល់សមិទ្ធផល នៃសង្គម ជាតិកាន់តែរឹងមាំ និងលើកតម្កើងកេរ្តិ៍ឈ្មោះកងយោធពលខេមរភូមិន្ទនៅ ក្នុងកិច្ចការតំបន់ និងអន្តរជាតិ»។ សម្តេចពិជ័យសេនា **ទៀ បាញ់** បានបន្តទៀតថា តាមរយៈនយោបាយ ឈ្នះ-ឈ្នះរបស់សម្តេចតេជោ **ហ៊ុន សែន** ធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍរីក ចម្រើនលើគ្រប់វិស័យក្នុងនោះកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកម្ពុជា-ចិន មានការវិវត្តឥតឈប់ឈរធ្វើឱ្យមានទំនាក់ ទំនងមិត្តភាពជាប្រពៃណីកម្ពុជា-ចិន មានការរីកចម្រើន គួរឱ្យកត់សម្គាល់ កិច្ចសហប្រតិបត្តិការយោធាទាំងពីរបានបន្ត ពង្រឹងពង្រីកកាន់តែស៊ីជម្រៅលើគ្រប់វិស័យរហូតឈានដល់កិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដោយឈរលើគោលការណ៍ជឿជាក់ និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកតាមរយៈថ្នាក់ដឹកនាំប្រទេសទាំងពីរមិត្តភាពជាប្រពៃណី និងជាប្រវត្តិសាស្ត្រដ៏យូរអង្វែងកម្ពុជា-ចិន គឺជាសម្បត្តិដ៏មានតម្លៃរួមរវាងប្រជាជនយើងទាំងពីរកម្ពុជា-ចិន ផងដែរ៕



# ព្រឹទ្ធសភាទទួលជំនួយសម្ភារៈពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ព្រឹទ្ធសភា*



ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រអង្គការចែករំលែកសង្គ្រោះជីវិតសកលកូរ៉េ

សម្ភារៈវេជ្ជសាស្ត្រចំនួន ២៣មុខ ក្នុងនោះរួមមាន៖ 1-Varucefa injection 1g, 10V 2-Selnium plus Ing, 10V 3-Shinpoong Spuramon Inj, 30amp. 4-Clecan injection 300mg ,15ml 5-Hemo-jade Powder 125mg 6-BC Telmi tab. 40mg, 30T 7-BC Telmi Tab. 80mg, 30T 8-Fluna Cap, 30C 9-Starova Tab 20mg, 30T 10-



ថ្នាក់ដឹកនាំ ភ្ញៀវកិត្តិយសចូលរួម




ឯកឧត្តម Park Heung-Kyeong

Starova Tab 5mg, 30T 11-BC Loxoprofen sodium Hydrate Tab, 30T 12-Valoin-A Sofl Cap. 500mg 30C 13-Amoxidal Duo Syrup, 50mL 14-Contrave ER Tab. 15-Rabapi-Q Tab. 30T 16-Tialbutin Tab. 30T 17-Javona Tab. 30T 18-Lacopat Syrup 100mL 19-Yurect Tab.1mg 30T 20-Montidin Tab. 25mg 100T 21-Yuyu Cefaclor

Cap, 30C **22**-Doumax Tab, 100T **23**-Dexidil Syrup, 500mL ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់អង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ត្រូវបានប្រគល់ជូនព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០



ថ្នាក់ដឹកនាំ ភ្ញៀវកិត្តិយសចូលរួម

ជាអ្នកនាំពាក្យព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **ផាក ហឺខខ្យឺខ**(H.E Park Heung-Kyeong) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃ



ពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ



ឯកឧត្តម ម៉ម ប៊ុននាង

សាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យវិមានព្រឹទ្ធសភា ។

បន្ទាប់ពីការថ្លែងអំណរគុណ និងចំណាប់អារម្មណ៍របស់ក្រុមសម្របសម្រួលមូលនិធិចែករំលែកសង្គ្រោះជីវិតសកល និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងចំណាប់អារម្មណ៍របស់លោក **គីម មីនហ្វូ** តំណាងអង្គការចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េរួចមក ឯកឧត្តម **ផាក ហឺខខ្យឺខ** អគ្គរដ្ឋទូត នៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា បានសំដែងនូវសេចក្តីរីករាយ និងចូលរួមអបអរសាទរចំពោះការប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់អង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ជូនដល់ព្រឹទ្ធសភាកម្ពុជា នាពេលនេះ ពិតជាសក្ខីភាពបញ្ជាក់នៅទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសាធារណរដ្ឋកូរ៉េ និងព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តមអគ្គរដ្ឋទូតបានរំលឹកថា ក្នុងរយៈពេល២៥ឆ្នាំកន្លងទៅនេះ ទំនាក់ទំនងទ្វេភាគីនៃប្រទេសទាំងពីរមានការកើនឡើងជាលំដាប់ ជាពិសេសវិស័យអភិវឌ្ឍន៍ ក៏ដូចជាការផ្លាស់ប្តូរ





ការបង្ហាញសម្ភារៈវេជ្ជសាស្ត្រដែលត្រូវប្រគល់



រូបថតអនុស្សាវរីយ៍

វប្បធម៌ នៃប្រទេសទាំងពីរ ហើយអ្វីដែលពិសេសជាងនេះទៅទៀត គឺប្រទេសកម្ពុជាជាដៃគូដ៏សំខាន់ក្នុងការបានទទួលជំនួយ ODA ដែលក្នុងឆ្នាំនេះ ប្រទេសកម្ពុជាបានទទួលជំនួយ ១៥០លាន ដុល្លារ ពីសាធារណរដ្ឋកូរ៉េ ។ ក្នុងនោះមានអង្គការសង្គមស៊ីវិល ចំនួន១៧របស់កូរ៉េ ដែលកំពុងធ្វើសកម្មភាពលើវិស័យជាច្រើន នៅប្រទេសកម្ពុជា ជាពិសេសអង្គការសង្គមស៊ីវិលក្នុងវិស័យ អប់រំជាវិស័យមួយដ៏សំខាន់ ក្នុងការជួយលើកកម្ពស់ទំនាក់ទំនង មិត្តភាព និងកិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ ។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានជម្រាបជូនអង្គពិធីថា ប្រទេស កូរ៉េជាប្រទេសដែលបានផ្តល់ជំនួយដល់ប្រទេសជាច្រើនលើ ពិភពលោក ក្នុងនោះមានប្រទេសកម្ពុជាផងដែរ ។ ជំនួយទាំង អស់នោះមានគោលដៅសម្រាប់កាត់បន្ថយភាពក្រីក្ររួមចំណែក ជាមួយរដ្ឋាភិបាលនៃប្រទេសជាមិត្ត ដើម្បីឆ្ពោះទៅរកវឌ្ឍនភាព វិបុលភាពទាំងអស់គ្នា ។ នាពេលបច្ចុប្បន្ននេះ បញ្ហាប្រទេសមួយ និងក្លាយទៅជាបញ្ហាពិភពលោកទាំងមូល ហើយអ្វីដែលសំខាន់ អង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋ កូរ៉េ និងចូលរួមចំណែកផ្តល់ជំនួយមនុស្សធម៌ដើម្បីឆ្លើយតប និងដំណោះស្រាយបញ្ហា និងជីវិតរបស់ប្រជាពលរដ្ឋ ដែលកំពុង ជួបប្រទះនូវបញ្ហាសុខភាព ។

ឯកឧត្តមអគ្គរដ្ឋទូត បានថ្លែងអំណរគុណអង្គការចែក រំលែកសង្គ្រោះអាយុជីវិតសកល និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានចែករំលែកនូវកិច្ចការរួមគ្នាចំពោះបញ្ហាទាំងអស់នេះនិង សម្តែងនូវសេចក្តីរីករាយ ដោយបានមើលឃើញនូវទំនាក់ទំនង មិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ នៃប្រទេសទាំងពីរ មានការរីកចម្រើន កាន់តែស៊ីជម្រៅបន្ថែមទៀត ។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ុម ប៊ុននាង** បានមាន ប្រសាសន៍ថា ថ្ងៃនេះព្រឹទ្ធសភាកម្ពុជាពិតជាមានសេចក្តីសោមនស្ស រីករាយ ដោយបានទទួលជំនួយមនុស្សធម៌ជាសម្ភារៈ ឧបករណ៍ វេជ្ជសាស្ត្រ ពីអង្គការចែករំលែកជួយសង្គ្រោះជីវិតសាកល ( Global Life Sharing ) នៃសាធារណរដ្ឋកូរ៉េ ។ ជំនួយមនុស្សធម៌ដ៏ថ្លៃថ្លា នេះ គឺជាសក្ខីភាពដ៏ពិតប្រាកដ នៃចំណងមិត្តភាព សាមគ្គីភាព រវាងកម្ពុជា-កូរ៉េ ជាពិសេសរវាងព្រឹទ្ធសភាកម្ពុជាជាមួយអង្គការ ចែករំលែកសង្គ្រោះអាយុជីវិតសកល ពិតជាឆ្លើយតបនិងតម្រូវ ការជាក់ស្តែងរបស់ព្រឹទ្ធសភាក៏ដូចជារាជរដ្ឋាភិបាលនៃព្រះរាជា ណាចក្រកម្ពុជា ក្នុងការលើកកម្ពស់សេវាសុខភាពសាធារណៈ ការបង្ការទប់ស្កាត់និងប្រយុទ្ធប្រឆាំងជំងឺកាចសាហាវនានាជា អាទិ៍ ៖ ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺកូវីដ-១៩ ជាដើម...។ល ។ ដើម្បីធានាបាននូវការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសកម្មភាព សង្គមសេដ្ឋកិច្ច ។

ឯកឧត្តម **ម៉ម ប៊ុននាង** បានគូសបញ្ជាក់ថាជំនួយ មនុស្សធម៌ ដូចដែលយើងទាំងអស់គ្នាបានឃើញជាក់ស្តែងនេះ នឹងត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំព្រឹទ្ធសភា ហើយប្រើប្រាស់ តាមរយៈយន្តការនានានៃព្រឹទ្ធសភា សម្រាប់ចែកជូនដល់មន្ទីរ ពេទ្យរដ្ឋ មន្ទីរពេទ្យបង្អែកមណ្ឌលសុខភាពនានា ព្រមទាំងប្រជាជន នៅក្នុងបណ្តាភូមិភាគទាំង ៨ ។ ជាមួយគ្នានេះព្រឹទ្ធសភាកម្ពុជា មានសេចក្តីរីករាយ និងសូមស្វាគមន៍នូវរាល់កិច្ចសហការមនុស្ស ធម៌ ជាមួយអង្គការចែករំលែកសង្គ្រោះជីវិតសកលជាបន្តបន្ទាប់ ទៀត ។

ក្នុងនាមថ្នាក់ដឹកនាំព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធ សភា និងសហការីទាំងអស់ ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែង នូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការចែករំលែកសង្គ្រោះ ជីវិតសកល ដែលបានផ្តល់នូវជំនួយមនុស្សធម៌ ដើម្បីលើកកម្ពស់ គុណភាពជីវិត និងជួយសង្គ្រោះជីវិតប្រជាជនកម្ពុជា៕

# អាល្លឺម៉ង់ សន្យាផ្តល់ឥណទានសម្បទានមួយថ្មីទៀត ចំនួន ៣០លានអឺរ៉ូ សម្រាប់គម្រោងប្រសិទ្ធភាព ថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ II

*អត្ថបទ ៖ សាត សុផល, រូបថត៖ កូ តុន*




ឯកឧត្តម អគ្គសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ប្តូរឯកសារកិច្ចព្រមព្រៀងជាមួយស្ថានទូតអាល្លឺម៉ង់

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** និង ឯកឧត្តម Christian Berger បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ ជាកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់សន្យាផ្តល់ឥណទានសម្បទានមួយថ្មីទៀត ចំនួន ៣០លានអឺរ៉ូ សម្រាប់គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ II (Energy Efficienty in Rural Power Supply II Project) កាលពីព្រឹកថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន ជាមួយ



បណ្តាញអគ្គិសនីដែលត្រូវបានតភ្ជាប់នៅតាមទីជនបទ



ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន ជួបពិភាក្សាជាមួយឯកអគ្គរដ្ឋទូតអាល្លឺម៉ង់




ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) នៅពេលក្រោយ បន្ទាប់ពីសិក្សាលម្អិតត្រូវបានធ្វើរួចរាល់។

មុនពេលចុះកិច្ចព្រមព្រៀងនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទទួលជួបជាមួយ ឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅកម្ពុជា ដើម្បីសម្តែងការគួរសម និង




ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ឥណទានពីរដ្ឋាភិបាលអាល្លឺម៉ង់



ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន
និងឯកអគ្គរដ្ឋទូតអាល្លឺម៉ង់

ជម្រាបលា ក្នុងឱកាសឯកឧត្តមត្រូវបញ្ចប់អាណត្តិបេសកកម្មការទូតនៅចុងខែមិថុនា ឆ្នាំ២០២២ ។

គួររំលឹកថា ឥណទានសម្បទានពីរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) លើកទី១ កម្ពុជាទទួលបាននៅឆ្នាំ២០១៩ ចំនួន ៣០លានអឺរ៉ូ សម្រាប់គាំទ្រការអនុវត្តគម្រោងប្រសិទ្ធភាព ថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ និងបន្ទាប់មកនៅឆ្នាំ២០២០ ដែលមានចំនួន ៣០លានអឺរ៉ូ ដូចគ្នា សម្រាប់ហិរញ្ញប្បទានដល់កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់កម្ពុជា ។

ការបន្តគាំទ្រផ្តល់ឥណទានសម្បទានបន្ថែមសម្រាប់គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ II នេះជាការបំពេញបន្ថែមទៅដល់កិច្ចខិតខំប្រឹងប្រែង និងការផ្តល់កិច្ចសហប្រតិបត្តិការល្អប្រសើរជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើន និងគាំទ្រឱ្យបានទូលំទូលាយនូវប្រសិទ្ធភាពថាមពល និងការផ្គត់ផ្គង់ថាមពលនៅតាមទីជនបទនៅក្នុងប្រទេស។

ជារួម ក្នុងរយៈពេលប្រមាណ ៣០ឆ្នាំនេះ ប្រទេសអាល្លឺម៉ង់ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយ ដែលបានសន្យាផ្តល់ហិរញ្ញប្បទានឥតសំណងច្រើនជាងគេ បើប្រៀបធៀបនឹងបណ្តាប្រទេសជាសមាជិកសហភាពអឺរ៉ុបដទៃទៀត។ គិតចាប់ពីឆ្នាំ១៩៩២ ដល់ដំណាច់ឆ្នាំ២០២១ រដ្ឋាភិបាលសាធារណសហព័ន្ធអាល្លឺម៉ង់បានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់កម្ពុជាសរុបប្រមាណ ៧២០លានដុល្លារអាមេរិក (ក្នុងនោះ ឥណទានសម្បទានមានចំនួនប្រមាណ ៧០ លានដុល្លារអាមេរិក និងហិរញ្ញប្បទានឥតសំណងចំនួនប្រមាណ ៦៥០លានដុល្លារអាមេរិក)។







ខ្សែបណ្តាញអគ្គិសនីតង់ស្យុងខ្ពស់

ក្នុងឱកាសនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូនព័ន្ធ មុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះ ឯកឧត្តម Christian Berger អំពីការងារសម្រេចបានគួរឱ្យកត់សម្គាល់ក្នុងក្របខ័ណ្ឌនៃ កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ ក្នុងរយៈពេល ៣ឆ្នាំ (ឆ្នាំ២០១៩-ឆ្នាំ២០២២) នៃការបំពេញបេសកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា។ ជាក់ស្តែងសមិទ្ធផលជាច្រើនក្នុងអាណត្តិរបស់ឯកឧត្តម ក្នុងនោះរួមមាន ការចូលរួមអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព និងការចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នៅកម្ពុជា តាមរយៈកម្មវិធីគាំពារសុខភាពសង្គម (Social Health Protection Program) និងកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (Identification of Poor Households-ID Poor) តាមរយៈទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស (GIZ)។ លើសពីនេះក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានបើកច្រកប្រភពហិរញ្ញប្បទានថ្មីសម្រាប់កម្ពុជា គឺជាការផ្តល់ឥណទានសម្បទានតាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតវិសាមញ្ញ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រជាជនអាល្លឺម៉ង់ ដែលបាននិងបន្តគាំទ្រ ទាំងជំនាញបច្ចេកទេស និងទាំងហិរញ្ញវត្ថុ ក្នុងការរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា និងបានជូនពរឯកឧត្តមឯកអគ្គរដ្ឋទូតឱ្យបានទទួលជោគជ័យថ្មីៗ ជាបន្តបន្ទាប់ទៀត នៅក្នុងភារកិច្ចដ៏ឧត្តុងឧត្តមរបស់ឯកឧត្តម ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋអាល្លឺម៉ង់ប្រគល់ជូន ។



ការតភ្ជាប់ចរន្តអគ្គិសនីចូលលំនៅដ្ឋាន



# គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ សម្រេចបានជាង ៩០% ហើយគ្រោងដាក់ឱ្យប្រើប្រាស់សាកល្បង នៅខែកក្កដាខាងមុខ



*អត្ថបទ ៖ សាត សុផល, រូបថត ៖ ក្រសួងសាធារណការ*



គម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ សម្រេចវឌ្ឍនភាពការងារបានជាង ៩០% ហើយគ្រោងនឹងដាក់ឱ្យប្រើប្រាស់សាកល្បងនៅខែកក្កដា ឆ្នាំ២០២២ ខាងមុខៗ នេះបើតាមការអះអាងរបស់ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងឱកាសចុះទស្សនកិច្ចសិក្សាស្វែងយល់ពីការងារសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ របស់ក្រុមយុវជនក្រសួងសាធារណការ និងដឹកជញ្ជូន និងនិស្សិត នៃវិទ្យាស្ថានតេជោសែន

សាធារណការ និងដឹកជញ្ជូន កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។

ឯកឧត្តម **ស៊ុន ចាន់ថុល** បានបញ្ជាក់ថា "គម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុនេះ សម្រេចវឌ្ឍនភាពការងារបាន៩០,៩៥% ហើយគិតត្រឹមថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ ត្រៀមនឹងបញ្ចប់ ដាក់ឱ្យប្រើប្រាស់សាកល្បងនៅខែកក្កដា ឆ្នាំ២០២២ ខាងមុខ និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្នុងពេលវេលាសមស្រប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា"។




ឯកឧត្តមទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល ផ្តល់កិច្ចសម្ភាសដល់បណ្តាញព័ត៌មានពេលចុះពិនិត្យការដ្ឋានផ្លូវល្បឿនលឿន



ឯកឧត្តមទេសរដ្ឋមន្ត្រី បានសម្តែងនូវជំនឿយ៉ាងមុតមាំថា ផ្លូវនេះនឹងចូលរួមចំណែក ក្នុងការជំរុញឱ្យប៉ូលសេដ្ឋកិច្ចភ្នំពេញ និងប៉ូលសេដ្ឋកិច្ចក្រុងព្រះសីហនុ មានការរីកចម្រើនលឿន ជាងធម្មតា ដោយសារការធ្វើដំណើរឆាប់រហ័ស កាត់បន្ថយចំណាយ កាត់បន្ថយពេលវេលា និងកាត់បន្ថយគ្រោះថ្នាក់ ចរាចរណ៍នៅលើផ្លូវជាតិលេខ៤។ឯកឧត្តមបានបន្ថែមថា រាជរដ្ឋាភិបាលកំពុងសិក្សាធ្វើផែនការមេ ដើម្បីឱ្យខេត្តព្រះសីហនុ ក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង ហើយផ្លូវល្បឿនលឿននេះនឹងចូលរួមបម្រើផែនការមេនេះ ក្នុងការទាក់ទាញវិនិយោគិនជាតិ



ឯកឧត្តម ស៊ុន ចាន់ថុល ពិនិត្យសំណាកគុណភាពផ្លូវ









ទិដ្ឋភាពផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ

និងអន្តរជាតិបន្ថែមទៀត ។

សូមបញ្ជាក់ថា គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ មានប្រវែង ១៨៧,០៥គីឡូម៉ែត្រ ដែលបានបើកការដ្ឋានសាងសង់កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ដែលគិតមកត្រឹមថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ដំណើរការនៃការដ្ឋានសាងសង់ គឺស្ថិតក្នុងដំណាក់កាល នៃការសាងសង់បញ្ចប់ ហើយគ្រោងនឹងបញ្ចប់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ដែលគ្រោងដាក់ឱ្យដំណើរការសាកល្បង នៅក្នុងខែកក្កដា ឆ្នាំ២០២២ ខាងមុខ។ ផ្លូវនេះតភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ តាមក្រសួងសាធារណការ និងដឹកជញ្ជូន បានឱ្យដឹងថាគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ( Phnom Penh-Si_hanoukville Expressway ) ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ជាខ្សែផ្លូវថ្មីទាំងស្រុង។ ផ្លូវនេះត្រូវសាងសង់ជា ៤គន្លង តួផ្លូវមានទទឹង ២៤ម៉ែត្រ ក្រាលកៅស៊ូ AC មានសួនច្បារខណ្ឌកណ្ដាល ចេញពីភ្នំពេញនៅចំណុចផ្លូវខ្សែក្រវ៉ាត់ក្រុងទី៣ មានផ្លូវបំបែកប្តូរទិស (Inter-Change) ភ្ជាប់មកផ្លូវជាតិលេខ៤ ចំនួន ៧កន្លែង មានស្ពានវែង-មធ្យម ៥៦កន្លែង ប្រវែង ៤ ៤១៧ ម៉ែត្រ ស្ពានខ្លី ៣៣កន្លែង ប្រវែង ៧៥០ម៉ែត្រ ស្ពានរំលង ៣២១ កន្លែង កន្លែងឈប់សម្រាក ៣កន្លែង និងហេដ្ឋារចនាសម្ព័ន្ធសំណង់សេវាគាំទ្រជាច្រើនទៀត ។ ការវិនិយោគលើគម្រោងផ្លូវល្បឿនលឿននេះ ត្រូវអនុវត្តន៍តាមទម្រង់សាងសង់-ប្រតិបត្តិ-



កំណាត់ផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ អាចបើកបរបានបណ្ដោះអាសន្ន

ផ្ទេរ (BOT) ដោយប្រើប្រាស់រយៈពេលសាងសង់ចំនួន ៤៨ខែ។ គួររំលឹកថា គម្រោងសាងសង់ផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទាន កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **លី ខឺឈាំង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតចិន។ ទាក់ទងនឹងតម្លៃសេវាឆ្លងកាត់ផ្លូវនេះ ឯកឧត្តម **ស៊ុន ចាន់ថុល** បានថ្លែងថា ក្រុមហ៊ុនសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ កំពុងពិចារណាលើតម្លៃ ធ្វើដំណើរតាមផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុដោយក្នុង១គីឡូម៉ែត្រក្រោម១0សេនដុល្លារ។ គម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ មានប្រវែងសរុបជាង១៩0គីឡូម៉ែត្រ ត្រូវចំណាយថវិកា សាងសង់ប្រមាណ ២ 000លានដុល្លារ ជាទុនវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC) តាមរយៈក្រុមហ៊ុន Cambodian PPSHV Expressway Co.,Ltd ។ ឯកឧត្តម **ស៊ុន ចាន់ថុល** បានឱ្យដឹងថា តាមបណ្ដាប្រទេសនានាលើពិភពលោកធ្វើដំណើរតាមផ្លូវល្បឿនលឿន ១0សេន ឬ១២សេនដុល្លារ ក្នុង១គីឡូម៉ែត្រ។ លោកបញ្ជាក់ថា «ប៉ុន្តែចំពោះប្រទេសកម្ពុជាវិញ ខ្ញុំបានស្នើសុំឱ្យយកក្រោម ១0សេន ក្នុង១គីឡូម៉ែត្រ។



ដូច្នេះក្រុមហ៊ុនកំពុងពិចារណាលើតម្លៃជិះលើផ្លូវនេះ។ ខ្ញុំបានពិភាក្សាដែរថា គួរអនុញ្ញាតពេលគាត់បើកផ្លូវនេះ អនុញ្ញាតឱ្យប្រើប្រាស់មួយរយៈសិន ដើម្បីប្រជាពលរដ្ឋ លោកស្គាល់ពីការប្រើប្រាស់ផ្លូវល្បឿនលឿន ហើយកុំយកថវិកាពីគាត់ ក្រុមហ៊ុនកំពុងតែពិចារណា»។

ឯកឧត្តមបន្ថែមថា ក្រសួងកំពុងផលិតវីដេអូ ដើម្បីចាក់ផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីការប្រើប្រាស់ផ្លូវល្បឿនលឿន ដូច្នេះប្រជាពលរដ្ឋត្រូវតែស្គាល់ និងយល់អំពីការប្រើប្រាស់ផ្លូវល្បឿនលឿន។ ចំពោះការប្រើប្រើល្បឿនវិញ ក្រសួងនឹងពិភាក្សាជាមួយក្រុមហ៊ុនដើម្បីអនុញ្ញាតឱ្យអ្នកបើកបរក្នុងល្បឿន ១២០ គីឡូម៉ែត្រ ក្នុង ១ម៉ោង៕

# សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញចូលរួមក្នុងពិធីដាំដើមឈើ នៅក្នុងបរិវេណ នៃមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជាខេត្តកំពង់ស្ពឺ

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ កាកបាទក្រហមកម្ពុជា*

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា អមដំណើរដោយលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ព្រមទាំងថ្នាក់ដឹកនាំឥស្សរជន ជាភរិយាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក យុវជនកាកបាទក្រហមកម្ពុជា និងពុទ្ធសាសនិកជាច្រើននាក់ បានអញ្ជើញចូលរួមក្នុងពិធីដាំដើមឈើនៅក្នុងបរិវេណមជ្ឈ-មណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា ស្ថិតនៅឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគីរីរម្យ ភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ដើម្បីចូលរួមការពារ និងការដាំដើមឈើឡើងវិញ។

ព្រឹត្តិការណ៍នេះរៀបចំឡើងដើម្បីអបអរសាទរពិធីដាំដើមឈើ និងការបង្ហាញពីសមិទ្ធផលដែលបាននិងកំពុងកសាងមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជាមួយកន្លែងស្ថិតនៅខេត្តកំពង់ស្ពឺដែលជាក្តីមោទនភាពមួយ ដែលបង្ហាញពីព្រះរាជាណាចក្រកម្ពុជាយើងមានសុខសន្តិភាពស្ថិរភាព និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យរួមទាំងការលើកកម្ពស់វប្បធម៌ សីលធម៌ និងវិស័យព្រះពុទ្ធសាសនាផងដែរ ។

ទន្ទឹមជាមួយគ្នានេះដែរ ក៏បានឆ្លុះបញ្ចាំងពីសកម្មភាពការងាររបស់កាកបាទក្រហមកម្ពុជាដែលក្រៅពីការផ្តល់អំណោយ



សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រគេនទេយ្យវត្ថុថ្វាយសម្តេចព្រះសង្ឃ





សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អមដំណើរដោយថ្នាក់ដឹកនាំអញ្ជើញចូលរួមដាំដើមឈើ នៅមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា ខេត្តកំពង់ស្ពឺ





សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញចូលរួមដាំដើមឈើ



មនុស្សធម៌ជួយសម្រាលការលំបាកជូនប្រជាពលរដ្ឋ ហើយក៏មានសកម្មភាពផ្សេងៗទៀតជាច្រើនទៅតាមវិស័យអាទិភាពទាំងបួន ហើយដែលក្នុងនោះគឺមានការបន្តពង្រឹងភាពធន់សហគមន៍ ការដោះស្រាយបញ្ហាប្រឈមនានាដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុតាមរយៈសកម្មភាពចូលរួមការពារ និងលើកកម្ពស់ និងថែរក្សាបរិស្ថាន ។

សូមបញ្ជាក់ថា សមិទ្ធផលនានាដែលបាននិងកំពុងកសាងនៅក្នុងមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា គឺបានមកពីព្រះរាជឧបត្ថម្ភនូវព្រះរាជទ្រព្យដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងហ្លួងម៉ែ **នរោត្តម មុនិនាថ សីហនុ**





រូបថតអនុស្សាវរីយ៍

មហាប្រាសាទតម្កល់គម្ពីរព្រះត្រៃបិដក ដែលជាកន្លែងទ្រទ្រង់ពុទ្ធវចនៈ នៅលើថ្មក្រានីត ហើយដែលអាចរក្សាទុកបានរាប់ពាន់ឆ្នាំ ទុកជាសម្បត្តិបុណ្យក៏ដូចជាសម្បត្តិជាតិសម្រាប់គោរពបូជាយូរអង្វែង ។

ទន្ទឹមនឹងនោះ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** និងគណៈប្រតិភូក៏បានអញ្ជើញបូជាគ្រឿងសក្ការៈថ្វាយព្រះរតនត្រ័យ និងប្រគេនទេយ្យវត្ថុ បច្ច័យ ដល់សម្តេចសង្ឃ និងព្រះសង្ឃ ១២អង្គ ដែលនិមន្តមកពីវត្តចំនួន១២ (ក្នុងនោះសម្តេចសង្ឃ ៣អង្គ និមន្តមកពីវត្តចំនួន៣ នៃរាជធានីភ្នំពេញ និងព្រះសង្ឃ ៩អង្គ ជាព្រះមេគណខេត្ត ជាព្រះគ្រូចៅអធិការជាតំណាងឱ្យវត្តចំនួន៩ នៅក្នុងខេត្តកំពង់ស្ពឺ)។ បច្ច័យប្រគេនវត្តនីមួយៗចំនួន ៥លានរៀល។ ដោយឡែក ចំពោះវត្តនៅមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា ប្រគេនបន្ថែមនៅ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ព្រមទាំងមានការចូលរួមពីអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកាធម្មញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** និងថ្នាក់ដឹកនាំ សប្បុរសជនគ្រប់មជ្ឈដ្ឋានផងដែរ ។

ក្នុងឱកាសនោះ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** និងគណៈប្រតិភូក៏បានបន្តដំណើរអញ្ជើញទស្សនា



សកម្មភាពសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ក្នុងថ្ងៃដាំដើមឈើ



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន កាប់រណ្តៅដាំដើមឈើ



ថ្នាក់ដឹកនាំចូលរួមដាំដើមឈើ









រូបថតអនុស្សាវរីយ៍

អង្ករ ២០០គីឡូក្រាម មី ១០កេស ត្រីខ ៣កេស សាច់ក្រក ១០គីឡូក្រាម ត្រីងៀត ១០គីឡូក្រាម ស្ករស ១០គីឡូក្រាម ទឹកដោះគោខាប់ ២កេស អូវ៉ាន់ទីន ២កេស តែ ៥គីឡូក្រាម ទឹកក្រូច ១០កេស ទឹកបរិសុទ្ធ ១០កេស និងផ្លែឈើស្រស់មួយកន្ត្រក ប្រគេនសម្តេចសង្ឃ ៣អង្គ ក្នុងមួយអង្គៗ សាដក១ និងបច្ច័យ ១លានរៀល ប្រគេនព្រះសង្ឃ ៩អង្គ ក្នុងមួយអង្គៗ សាដក១ និងបច្ច័យ ៥០ម៉ឺនរៀល៕



សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងប្រតិភូអមដំណើរបូជាគ្រឿងសក្ការៈថ្វាយព្រះរតនត្រ័យ



រូបថតអនុស្សាវរីយ៍

# ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ជំរុញឱ្យអាជ្ញាធរស្រុក ឃុំត្រូវផ្តល់ទំនុកចិត្ត និងបម្រើសេវាឱ្យបានល្អជូនប្រជាពលរដ្ឋនៅមូលដ្ឋាន

*អត្ថបទ និងរូបថត៖ សៅ សុវណ្ណ*



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា អញ្ជើញសំណេះសំណាលសួរសុខទុក្ខ
លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជាពលរដ្ឋភូមិព្រៃជ្រូវ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ



ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ទីប្រឹក្សារាជរដ្ឋាភិបាល បានជំរុញឱ្យអាជ្ញាធរ ស្រុក ឃុំ ត្រូវផ្តល់ទំនុកចិត្តនិងបម្រើសេវាឱ្យបានល្អជូនប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន កុំមើលស្រាលសភាពការណ៍ឱ្យសោះ ព្រោះសម័យបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្ននេះ អ្នកណាចេះតែថា អ្នកណាធ្វើពិត អ្នកណាដើរតែស្រែកមិនធ្វើនោះ ប្រជាពលរដ្ឋគាត់ចេះវិនិច្ឆ័យបានហើយ ។

ការថ្លែងបែបនេះរបស់ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** បានធ្វើឡើងក្នុងឱកាសដែលឯកឧត្តមអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ នៅក្នុងបរិវេណអនុវិទ្យាល័យសម្តេច នន្ទ ង៉ែត ព្រៃជ្រូវ ភូមិព្រៃជ្រូវ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **យិន ឃុនផយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធនានា អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២។

ក្នុងពិធីនេះដែរ ឯកឧត្តមក៏បានសម្តែងនូវការសរសើរចំពោះលោកគ្រូ អ្នកគ្រូនៃសាលាអនុវិទ្យាល័យសម្តេច នន្ទ ង៉ែត ព្រៃជ្រូវ ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនសិស្ស ព្រមទាំងបានជំរុញដល់សិស្សានុសិស្សទាំងអស់ឱ្យខិតខំសិក្សារៀនសូត្រ ហើយដោយឡែកចំពោះបងប្អូនប្រជាពលរដ្ឋវិញ ឯកឧត្តមក៏បានជំរុញឱ្យបងប្អូនយកចិត្តទុកដាក់ក្នុងការបង្កបង្កើនផល ពិសេស




ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ត្រូវបានស្វាគមន៍ពីសំណាក់លោកគ្រូ អ្នកគ្រូ បងប្អូនប្រជាពលរដ្ឋ

ការធ្វើស្រែនារដូវវស្សាឆ្នាំនេះឱ្យបានទាន់ពេលវេលា ។

ទន្ទឹមនោះ ឯកឧត្តមបានក្រើនរំលឹកទៅដល់អាជ្ញាធរ ស្រុក ឃុំ ត្រូវបន្តខិតខំធ្វើយ៉ាងណាដើម្បីទាក់ទាញបាននូវទំនុកចិត្តពីប្រជាពលរដ្ឋ លុះត្រាតែអាជ្ញាធរជួយសម្របសម្រួលដោះស្រាយបញ្ហានិងតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋ ព្រោះអាជ្ញាធរ ស្រុក ឃុំ នៅថ្នាក់មូលដ្ឋាន ជាសេនាធិការឱ្យរដ្ឋបាលខេត្ត និងត្រូវបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋ ។

បន្ថែមពីនេះ ឯកឧត្តមក៏បានជំរុញឱ្យអាជ្ញាធរបន្តការយកចិត្តទុកដាក់ការងារចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នា និងត្រូវបន្តចុះជួយមូលដ្ឋានឱ្យបានសកម្មបន្ថែមទៀត ក្នុងនោះត្រូវបន្តចុះអប់រំផ្សព្វផ្សាយនូវវិធានការសុខាភិបាល និងជំរុញឱ្យប្រជាពលរដ្ឋត្រូវពាក់ម៉ាស់ឱ្យបានជាប្រចាំថែមទៀតផង។

ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ក៏បានបញ្ជាក់បន្ថែមទៀតថា សន្តិភាពគឺមានតម្លៃជាងអ្វីៗទាំងអស់ សន្តិភាព គឺជាអ្វីដែលស្រស់ស្អាតបំផុត សន្តិភាពផ្តល់នូវក្តីសង្ឃឹម និងស្នាមញញឹមដល់មនុស្សគ្រប់រូប។ បទពិសោធន៍របស់ប្រទេសមួយ




ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា មានមតិសំណេះសំណាលថ្លែងទៅកាន់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ក្នុងអនុវិទ្យាល័យសម្តេច នន្ទ ង៉ែត ព្រៃជួរ








ទិដ្ឋភាពរួមនៃពិធីសំណេះសំណាល





រូបថតអនុស្សាវរីយ៍

ចំនួនដែលកំពុងកើតសង្គ្រាម គឺជាមេរៀនសម្រាប់ការយល់ដឹងរបស់យើងថា គោលនយោបាយផ្តោតលើការថែរក្សាសន្តិភាព គឺមានសារៈសំខាន់ ហើយការរក្សាអាយុជីវិតរបស់ប្រជាជន និងប្រទេសជាតិក៏រឹតតែជារឿងសំខាន់ និងត្រូវការចាំបាច់នូវថ្នាក់ដឹកនាំដែលមានទស្សនទាននយោបាយសន្តិភាព មានចក្ខុវិស័យវែងឆ្ងាយ និងមានបទពិសោធន៍គ្រប់គ្រាន់ដើម្បីធ្វើការសម្រេចជាយុទ្ធសាស្ត្រសមស្របទៅនិងកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ និងការប្រែប្រួលដ៏ឆាប់រហ័សរបស់ពិភពលោក ដើម្បីការពារសន្តិភាព ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ។

ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** បានបញ្ជាក់ច្បាស់ថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាថែរក្សាសន្តិភាព ដែលរកមកបានដោយលំបាកនេះឱ្យនៅស្ថិតស្ថេរគង់វង្សជូនប្រជាពលរដ្ឋបានយូរអង្វែងច្រើនជំនាន់ ទន្ទឹមនឹងនេះក៏នឹងបន្តពង្រីកឱកាសធ្វើឱ្យជីវភាពប្រជាជនកាន់តែប្រសើរឡើងថែមទៀត៕



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ចែកនំចំណី ផ្លែឈើ ជូនប្រជាពលរដ្ឋបានចូលរួមក្នុងពិធី



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ចុះជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងលក់ដូរ

# ឯកឧត្តម សុខ ប្រសិទ្ធិ និង ឯកឧត្តម សាម៉ន បណ្ឌិត្យ រដ្ឋលេខាធិការក្រសួងព័ត៌មាន ប្រគល់ថវិកា ចូលរួមចំណែកការងារមនុស្សធម៌ ជាមួយឯកឧត្តម ខៀវ កាញារីទ្ធ

*អត្ថបទ ៖ សាត សុផល, រូបថត ៖ ឌី ណារិន*









ឯកឧត្តមរដ្ឋមន្ត្រីជួបសំណេះសំណាល និងទទួលថវិកាពីឯកឧត្តមបណ្ឌិត សុខ ប្រសិទ្ធិ និង ឯកឧត្តម សាម៉ន បណ្ឌិត្យ

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រី ក្រសួងព័ត៌មាន បានទទួលជួបពិភាក្សាការងារ ជាមួយឯកឧត្តមបណ្ឌិត **សុខ ប្រសិទ្ធិ** និងឯកឧត្តម **សាម៉ន បណ្ឌិត្យ** រដ្ឋលេខាធិកការ ក្រសួងព័ត៌មាន កាលពីព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ នៅទីស្តីការក្រសួង ក្នុងឱកាសដែលឯកឧត្តមទាំងពីរបាននាំយកថវិកាសប្បុរសធម៌ ជូនឯកឧត្តមរដ្ឋមន្ត្រីសម្រាប់ចូលរួមចំណែកក្នុងសកម្មភាពការងារមនុស្សធម៌ ក្នុងនោះ ឯកឧត្តមបណ្ឌិត **សុខ ប្រសិទ្ធិ** ចំនួន ៤លានរៀល និងឯកឧត្តម











ឯកឧត្តមរដ្ឋមន្ត្រីសំណេះសំណាលជាមួយ
ឯកឧត្តមបណ្ឌិត សុខ ប្រសិទ្ធិ

**សាម៉ន បណ្ឌិត្យ** ចំនួន ៥លានរៀល ។

នៅក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **សុខ ប្រសិទ្ធិ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការសម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងព័ត៌មាន និងឯកឧត្តម **សាម៉ន បណ្ឌិត្យ** បានលើកឡើងថា ថវិកាផ្ទាល់ខ្លួនដែលបាននាំយកមកជូនឯកឧត្តមរដ្ឋមន្ត្រីនាឱកាសនេះ គឺដើម្បីចូលរួមចំណែកក្នុងសកម្មភាពការងារមនុស្សធម៌របស់ឯកឧត្តម **ខៀវ កាញារីទ្ធ** និងលោកជំទាវ ដែលជានិច្ចកាល លោក តែងតែ បានធ្វើ សកម្មភាព មនុស្សធម៌ជួយដល់ជនងាយរងគ្រោះ មានជីវភាពខ្វះខាត និងកុមារកំព្រា កុមារក្រីក្រ កុមារពិការ គ ថ្លង់ និងខ្សោយសតិបញ្ញា នៅតាមតំបន់មូលដ្ឋាននានាជាច្រើន នាពេលកន្លងមក និងបន្តទៅពេលខាងមុខទៀត។

ឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** បានថ្លែងអំណរគុណចំពោះទឹកចិត្តសប្បុរសធម៌របស់ឯកឧត្តមបណ្ឌិត **សុខ ប្រសិទ្ធិ** និងលោកជំទាវ និងឯកឧត្តម **សាម៉ន បណ្ឌិត្យ** និងលោកជំទាវដែលបានផ្តល់នូវថវិកាផ្ទាល់ខ្លួនសម្រាប់ចូលរួមបន្តក្នុងកិច្ចការងារមនុស្សធម៌ នៅកន្លែងនានា តាមតំបន់មូលដ្ឋានបន្តទៅមុខទៀត និងបាន ជូនលិខិតថ្លែងអំណរគុណដល់ឯកឧត្តមទាំងពីរផងដែរ ៕



ឯកឧត្តមរដ្ឋមន្ត្រីសំណេះសំណាលជាមួយ
ឯកឧត្តម សាម៉ន បណ្ឌិត្យ

# ឯកឧត្តម លឹម គានហោះ ប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន ក្នុងខេត្តបាត់ដំបង សម្រេចការសាងសង់បានប្រមាណ ៩៧ភាគរយ

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ក្រសួងធនធានទឹក*



ប្លង់រូបភាពប្រព័ន្ធធារាសាស្ត្រទំនប់សាលាតាអន



ឯកឧត្តម លឹម គានហោ ចង្អុលបង្ហាញនិងពិនិត្យមើលស្តីពីការងារប្រព័ន្ធធារាសាស្ត្រ

ប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍**ទំនប់សាលាតាអន** ស្ថិតនៅក្នុងស្រុកឯកភ្នំនិងស្រុកសង្កែខេត្តបាត់ដំបង ដែលបានចាប់ផ្តើមដំណើរការសាងសង់កាលពី ខែមករា ឆ្នាំ២០១៩ ជាគម្រោងមួយក្រោមហិរញ្ញប្បទានសម្បទានរបស់សាធារណរដ្ឋកូរ៉េនោះ រហូតមកដល់ពេលនេះសម្រេចការងារបានប្រមាណ ៩៧ភាគរយ ហើយគ្រោងបញ្ចប់ការងារសាងសង់ជាស្ថាពរក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។

ការលើកឡើងខាងលើ គឺក្នុងឱកាស ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម អម



សំណង់ប្រព័ន្ធធារាសាស្ត្រទំនប់សាលាតាអនកំពុងដំណើរការសាងសង់







ឯកឧត្តម លឹម គានហោ ចុះពិនិត្យផ្ទាល់នៃការសាងសង់ប្រព័ន្ធធារាសាស្ត្រទំនប់សាលាតាអន

ដំណើរដោយថ្នាក់ដឹកនាំក្រសួង ក្រុមមន្ត្រីបច្ចេកទេស ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបង បានអញ្ជើញចុះពិនិត្យផ្ទាល់ កាលពីថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០២២ នៃការសាងសង់ប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន ដោយឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៍ថា ប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន មានអត្ថប្រយោជន៍សំខាន់ធំៗ ចំនួន ៣ ដែលក្នុងនោះរួមមាន **ទី១**-ជាប្រព័ន្ធធារាសាស្ត្របញ្ជាដោយស្វ័យប្រវត្តិតាមរយៈកុំព្យូទ័រក្នុងការបិទទ្វារទឹកសំណង់មេស្ទាក់ទឹកស្ទឹងមានទទឹង ៧៥ម៉ែត្រ ដើម្បីស្ទាក់ថែរក្សាទឹកទុកនៅលើស្ទឹងសង្កែ ដែលចាត់ទុកជាដំណាក់កាលទី៣ ផ្នែកខាងក្រោមស្ទឹងសង្កែ បន្ទាប់ពីនៅផ្នែកខាងលើមានអាងទឹកពហុបំណងសេកសក និងទំនប់កង្ហត មុននឹងធ្លាក់ចូលទៅបឹងទន្លេសាប ។ គម្រោងនេះមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រូវវស្សាចំនួន ១១ ០០០ហិកតា និងស្រូវប្រាំងចំនួន ៤ ៧០០ហិកតា ។ **ទី២**-ជាប្រភពទឹកដើម្បីបម្រើដល់ការផ្គត់ផ្គង់ទឹកស្អាតដល់ស្រុកឯកភ្នំ ស្រុកសង្កែ ស្រុកថ្មគោល និងក្រុង









ទិដ្ឋភាពប្រព័ន្ធធារាសាស្ត្រទំនប់សាលាតាអន



ឯកឧត្តម លឹម គានហោ ណែនាំបច្ចេកទេសក្នុងការកែលម្អចំណុចខ្វះខាតប្រព័ន្ធធារាសាស្ត្រអាងកំពីងពួយ

បាត់ដំបងផ្ទាល់និង**ទី៣**-ជាសោភ័ណភាព និងទាក់ទាញសក្តានុពលទេសចរណ៍ដល់ខេត្តបាត់ដំបង ។

ក្នុងឱកាសអញ្ជើញចុះពិនិត្យផ្ទាល់នូវប្រព័ន្ធធារាសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន ឯកឧត្តមរដ្ឋមន្ត្រីបានរំលឹកអនុស្សាវរីយ៍ដោយមានប្រសាសន៍ថា៖ គម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន គឺជាក្តីស្រមៃរបស់ខ្ញុំអស់រយៈពេលជាង៤០ឆ្នាំមកហើយ ដែលចង់បាននូវសំណង់បែបនេះ ពេលនេះបានក្លាយជាការពិតហើយនៅក្នុងសម័យតេជោសែនសន្តិភាព ។ គម្រោងនេះពិតជាមានសារៈសំខាន់និងអត្ថប្រយោជន៍ខ្លាំងណាស់ក្នុងការបម្រើដល់ជីវភាពប្រជាពលរដ្ឋនិងសោភ័ណភាពក្រុងបាត់ដំបងផងដែរ ។

ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើការកោតសរសើរដល់ក្រុមការងារសាងសង់ដែលបានខិតខំធ្វើការទោះជួបឧបសគ្គនិងបញ្ហាប្រឈមខ្លះៗមួយចំនួននិងណែនាំដល់មន្ទីរ ត្រូវបន្តតាមដាននិងសហការជាមួយអាជ្ញាធរដែនដីបន្ថែម ធ្វើយ៉ាងណាឱ្យសំណង់នេះមានគុណភាពរឹងមាំយូរអង្វែង ដើម្បីបម្រើជាប្រយោជន៍ដល់ការងារបង្កបង្កើនផល ផ្គត់ផ្គង់ទឹកប្រើប្រាស់ ជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋក្នុងតំបន់ ។

ដោយឡែកនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម បានបន្តបេសកកម្មការងារ ដោយបានចុះពិនិត្យមើលស្ថានភាពប្រព័ន្ធធារាសាស្ត្រមួយចំនួននៅភូមិភាគពាយព្យ ក្នុងនោះមានខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យក្នុងគោលបំណងសំខាន់ចំនួន៣មានជាអាទិ៍៖ គឺ**ទី១**-វាយតម្លៃស្ថានភាពទឹកនាដើមរដូវវស្សាឆ្នាំ២០២២ ដែលឆ្នាំនេះភ្លៀងបានធ្លាក់ឆាប់ជាងនិងបរិមាណច្រើនជាងបណ្តាឆ្នាំកន្លងទៅ ។ ( ជាក់ស្តែងបច្ចុប្បន្នទំនប់អាងកំពីងពួយបានមានបរិមាណទឹក ៦០លានម៉ែត្រគូបស្មើនិង ៤០ភាគរយ នៃកម្រិតស្តុកទឹកអតិបរមា ១៥០លានម៉ែត្រគូប ) ។ **ទី ២**-ណែនាំបច្ចេកទេស កែលម្អនូវចំណុចខ្វះខាតក្នុងការកសាងគម្រោងការធ្វើទំនើបកម្មលើប្រព័ន្ធធារាសាស្ត្រអាងកំពីងពួយក្នុងស្រុកបាណន់ខេត្តបាត់ដំបងដែលកំពុងជំរុញការងារសាងសង់យ៉ាងសកម្ម រហូតមកដល់ពេលនេះសម្រេចបានប្រមាណ



៨០ភាគរយ នៃផែនការ និង**ទី ៣** -ចុះពិនិត្យជាក់ស្តែងអំពីស្ថានភាពដោះទឹក លិចដីស្រែបងប្អូនប្រជាកសិករ នៅឃុំរហាត់ទឹក ស្រុកមង្គលបុរីខេត្តបន្ទាយមានជ័យ ដែលទើបជនលិចដោយបរិមាណទឹកភ្លៀងធ្លាក់លើសលប់មានប្រភពមកពីស្រុកម៉ាឡៃ ។ ទន្ទឹមនោះឯកឧត្តមរដ្ឋមន្ត្រីបានចាត់បញ្ជាភ្លាមៗ ឱ្យប្រើប្រាស់គ្រឿងចក្រធុនធ្ងន់កាយកាត់ផ្តាច់ប្រឡាយចារ ដែលបាននិងកំពុងស្តារពង្រីកមុខកាត់ឱ្យធំជាងមុនតែមិនទាន់បានកាត់ផ្តាច់នៅឡើយ ដោយសភាពការណ៍ជាក់ស្តែងចំពោះមុខមានភ្លៀងធ្លាក់ខ្លាំង គឺចាំបាច់ត្រូវកាត់ផ្តាច់ជាបន្ទាន់ បើកមុខទឹកដើម្បីបន្ធូរឱ្យទឹកធ្លាក់ទៅក្រោមតម្រង់ឆ្ពោះទៅបឹងទន្លេសាបសិន ៕





សកម្មភាពគ្រឿងចក្រកាយកាត់ផ្តាច់ប្រឡាយចារ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ



ជំនន់ទឹកភ្លៀងលិចដីស្រែប្រជាកសិករនៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

# ឯកឧត្តម ជា ច័ន្ទបរិបូរណ៍ ៖ គណបក្សប្រជាជនកម្ពុជា បម្រើប្រជាជន ដើម្បីប្រជាជន និងនាំមកនូវការអភិវឌ្ឍ

*អត្ថបទ និង រូបថត ៖ យូរ វង្ស*




ឯកឧត្តម ជា ច័ន្ទបរិបូណ៌ សំណេះសំណាលជាមួយសមាជិកគណបក្សប្រជាជននៅតាមបណ្តាភូមិក្នុងស្រុកក្រឡាញ់





ពិធីជួបជុំសំណេះសំណាលជាមួយសមាជិកគណបក្សប្រជាជននៅតាមបណ្តាលភូមិក្នុងស្រុកក្រឡាញ់

ថ្លែងក្នុងពិធីសំណេះសំណាលជាមួយសមាជិក សមជិកាសកម្មជននិងក្រុមការងារយុវជននៅក្នុងភូមិមួយចំនួកាលពីចុងខែឧសភា ឯកឧត្តម **ជា ច័ន្ទបរិបូរណ៍** អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកក្រឡាញ់ ខេត្តសៀមរាប មានប្រសាសន៍ថាគណបក្សប្រជាជនកម្ពុជាគឺជាគណបក្សចាស់ទុំបំផុត ព្រមទាំងជាគណបក្សដែលបានកសាងសមិទ្ធផលជូនជាតិ និងប្រជាជនយ៉ាងច្រើនអនេក ។ និយាយជារួម គណបក្សប្រជាជនកម្ពុជា នៅជិតស្និទ្ធគ្រប់ពេលវេលាគ្រប់ទីកន្លែងដើម្បីបំម្រើសេក្តីត្រូវការនិងដោះស្រាយបញ្ហាការលំបាកនានាជូនប្រជាពលរដ្ឋ ដើម្បីបម្រើប្រជាជនយើងទាំងអស់គ្នា ហេតុនេះដើម្បីឱ្យគណបក្សអាចបន្តបេសកកម្មការពារ និងអភិវឌ្ឍជាតិ ព្រមទាំងបម្រើប្រជាពលរដ្ឋ បានជាបន្តទៅទៀត យើងត្រូវនាំគ្នា







ពិធីសំណេះសំណាល និងការបញ្ចេញមតិយោបល់របស់សមាជិក

គាំទ្រនិងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ជាបន្តទៅទៀត ដើម្បីរក្សាបាននូវ សន្តិភាពសង្គម ស្ថិរភាពនយោបាយ កំណើន សេដ្ឋកិច្ចជាតិ ។

ឯកឧត្តម បន្តថា គណបក្សប្រជាជនកម្ពុជាបានធ្វើការ ស្តារសេដ្ឋកិច្ច និងសង្គមជាតិឡើងវិញពីស្ថានភាពខ្ទេចខ្ទីសល់ពី របបប្រល័យពូជសាសន៍ខ្មែរក្រហម ឱ្យមានការអភិវឌ្ឍរីកចម្រើន លើគ្រប់វិស័យ ហើយកម្ពុជាបាន ស្ថិតក្នុងចំណោមប្រទេសដែល សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចបានវឌ្ឍនភាពល្អ ប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រជាមួយគ្នា ក្នុងដំណាក់ កាលកូវីដ-១៩ ជាសកល គណបក្សយើងក៏មានជោគជ័យផងដែរ ក្នុងការប្រយុទ្ធនឹងជំងឺនេះ ដោយបានចាក់វ៉ាក់សាំងជូនប្រជាពល រដ្ឋដណ្តប់បានទូទាំងប្រទេស ថែមទាំងការពារបានយ៉ាងគត់ មត់នូវឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដី ព្រមទាំង ការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់ សាធារណៈជូនប្រជាជនគ្រប់ទីកន្លែងគ្រប់ពេលវេលាផងដែរ។

ឯកឧត្តម **ជា ច័ន្ទបរិបូរណ៍** បញ្ជាក់ថា គណបក្សប្រជា ជនកម្ពុជា មានយន្តការនិងគោលនយោបាយច្បាស់លាស់ ដើម្បីការពារ កសាងជាតិ និងបម្រើប្រជាជនគ្មានទីបញ្ចប់ឡើយ ។ ហេតុនេះ ការដណ្តើមយកជ័យជម្នះក្នុងការបោះឆ្នោតជ្រើស រើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែ មិថុនានេះ ជាការចាំបាច់ណាស់ ព្រោះគណបក្សប្រជាជន កម្ពុជាយើងជាទំនុកចិត្តរបស់ប្រជាពលរដ្ឋឱ្យបន្តបម្រើក្នុងនាម ជារដ្ឋបាលឃុំ-សង្កាត់។ យើងមានឱកាសអនុវត្តន៍នូវកិច្ចការដ៏ សំខាន់ៗជាច្រើនដើម្បីបម្រើសេវាសាធារណៈនានា និងបន្ត ការកសាងហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ក្នុងមូលដ្ឋានប្រកប ដោយស្មារតីទទួលខុសត្រូវតម្លាភាពគណនេយ្យភាពឈរលើ ជំហរសហការរួមគ្នា លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ លើកស្ទួយ សិទ្ធិសេរីភាពរបស់ពលរដ្ឋតាមគន្លងនីតិរដ្ឋធ្វើឱ្យមានវឌ្ឍនភាព ដល់មូលដ្ឋាន ផ្តល់សុខដុមជូនប្រជាពលរដ្ឋនិងលើកកម្ពស់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ឱ្យកាន់ តែប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

យោងតាមរបាយការណ៍របស់ លោកស្រី **ម៉ននី រទ្សី** ប្រធានគណៈកម្មាធិការគណបក្សស្រុកក្រឡាញ់ បានឱ្យដឹងថា ក្នុងស្រុកទាំងមូលមានគណ បក្សនយោបាយបានធ្វើសកម្មភាព ដោយបានលើកផ្ទាំងស្លាកសញ្ញាគណបក្ស និងផ្ទាំងប៉ាណូ ចំនួន១០ រាប់ទាំងគណបក្សប្រជាជនកម្ពុជា។ ក្នុងចំនួននេះ មានគណបក្សចំនួន៥ បានចុះបញ្ជីបេក្ខជនចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជា បានចុះបញ្ជី បេក្ខជនក្នុងឃុំទាំង១០ ដោយមានបេក្ខជនសរុប១៤០នាក់(ស្រី ២៩នាក់) និង ត្រូវបានសម្រិតសម្រាំងយកសុទ្ធតែអ្នកមាន មនសិការខ្ពស់ក្នុងការបម្រើប្រជាពលរដ្ឋក្នុងពេលកន្លងមក និង អ្នកដែលមានសមត្ថភាព និងថាមពលសម្រាប់ការបំពេញភារ កិច្ចក្នុងពេលខាងមុខ ហើយអ្នកទាំងអស់ សុទ្ធតែជាអ្នកដែល បានទទួលបានការគាំទ្រពីមជ្ឈដ្ឋានសមាជិកគណបក្ស ៕

# អគ្គនាយករដ្ឋាករទឹក៖ ផែនការមេផ្គត់ផ្គង់ទឹកស្អាតគ្រប់ដណ្តប់លើផ្ទៃដី ៦៧០គីឡូម៉ែត្រការ៉េ ដោយបូកបញ្ចូលតំបន់ព្រលានយន្តហោះថ្មី និងតំបន់អរិយក្សត្រ

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ឯកសារ*



ឯកឧត្តម ឡុង ណារ៉ូ អមដោយថ្នាក់ដឹកនាំរដ្ឋាករទឹក



ឯកឧត្តម ឡុង ណារ៉ូ អគ្គនាយករដ្ឋាករទឹកភ្នំពេញ



ឯកឧត្តម ផៃ ស៊ីផាន អញ្ជើញឡើងមានមតិ

ឯកឧត្តម **ឡុង ណារ៉ូ** អគ្គនាយករដ្ឋាករទឹកភ្នំពេញបានមានប្រសាសន៍ថា ផែនការមេរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺធ្វើយ៉ាងណាពីមួយឆ្នាំទៅមួយឆ្នាំមិនឱ្យមានការខ្វះខាតទឹកសម្រាប់ផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋ។ ផែនការមេនេះ គ្រប់ដណ្តប់ដល់ផ្ទៃដី ៦៧០គីឡូម៉ែត្រការ៉េ ហើយក៏បានបូកបញ្ចូលតំបន់ព្រលានយន្តហោះថ្មី និងតំបន់អរិយក្សត្រផងដែរ ខណៈបច្ចុប្បន្ន



ឯកឧត្តម ផៃ ស៊ីផាន

ការថ្លែងបែបនេះរបស់ឯកឧត្តម **ឡុង ណារ៉ូ** អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានធ្វើឡើងក្នុងឱកាសឯកឧត្តមបានអញ្ជើញធ្វើសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាព និងចក្ខុវិស័យផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ២០២៣-២០៣០ " នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ ។

ឯកឧត្តម **ឡុង ណារ៉ូ** បានបញ្ជាក់ថា ផ្ទៃសេវាផ្គត់ផ្គង់របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់រាជធានីភ្នំពេញ



អ្នកសារព័ត៌មាន

ផ្ទៃសេវាដែលអាចផ្គត់ផ្គង់បានប្រមាណ ៨៣ទៅ ៨៥ភាគរយ ។



ឯកឧត្តម ឡុង ណារ៉ូ អមដំណើរដោយមន្ត្រីបច្ចេកទេសអញ្ជើញចុះត្រួតពិនិត្យការងារចាក់បេតុងបាតក្រោមស្ថានីយ៍បូមទឹកកោះនរា កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២២



នៅក្នុងឆ្នាំ២០២៥ ខាងមុខ នឹងអាចឈានដល់ ៩៥ភាគរយ ឬ ១០០ភាគរយនៃផ្ទៃដី ៦៧០គីឡូម៉ែត្រការ៉េ លើកលែងតំបន់មួយចំនួនដែលមិនមានបំពង់មេនាំទឹកទៅដល់។ ដើម្បីអាចមានលទ្ធភាពផ្គត់ផ្គង់ទឹក ជូនគ្រប់តម្រូវការរបស់អតិថិជនរហូតដល់ឆ្នាំ២០៣០ រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតភូមិព្រែកត្រូវបង្កើនសមត្ថភាពផលិតដល់ ១៩៥ ០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ ពីឆ្នាំ២០២១ ទៅឆ្នាំ២០៣០ ត្រូវបានបែងចែកជា៣ដំណាក់កាល និងទៅតាមជំហាននីមួយៗ។ បើផ្អែកលើការព្យាករ តម្រូវការទឹកប្រើប្រាស់ក្នុងឆ្នាំ២០៣០ ដែលនឹងអាចកើនដល់ប្រមាណ ១លាន ៨សែនម៉ែត្រគូប ក្នុងមួយថ្ងៃ ដែលទាំងអស់នេះហើយបានជារដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញដាក់នូវគោលដៅដើម្បី






មន្ត្រីជំនាញរដ្ឋាករទឹកកំពុងជួសជុលតបណ្តាញទឹកជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ

ពង្រីកសមត្ថភាពផលិត និងចែកចាយទឹកស្អាតបម្រើដល់ការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅរហូតដល់ឆ្នាំ២០៣០ តែម្តង ។

ឯកឧត្តមអគ្គនាយក ក៏បានមានប្រសាសន៍ឱ្យដឹងផងដែរថា សម្រាប់អ្នកលក់ទឹកបន្តនៅតាមតំបន់នានា នៅក្នុងនិងជាយរាជធានីភ្នំពេញប្រមាណ ១ឆ្នាំទៀត នឹងមិនមានទៀតនោះទេ ខណៈបច្ចុប្បន្ននេះអ្នកលក់ទឹកបន្តនៅរាជធានីមានប្រមាណជាង ៥ពាន់នាក់ នៅតាមបណ្តារោងចក្រទាំងអស់ និងទីតាំងអាជីវកម្មផ្សេងៗ ។

ឯកឧត្តមបន្តថា ការកាត់បន្ថយអ្នកលក់ទឹកបន្តនេះ ដោយសារតែសម្ពាធទឹករបស់រដ្ឋាករទឹកអាចផ្គត់ផ្គង់បានគ្រប់គ្រាន់នៅតាមតំបន់នានា ខណៈរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបាក់ខែងគ្រោងបញ្ចប់ការសាងសង់នៅក្នុងឆ្នាំ២០២៣។ កន្លងមកសម្តេចតេជោ **ហ៊ុន សែន** បានកំណត់ឱ្យលក់ទឹកក្នុងតម្លៃ ៧០០ទៅ ៨០០រៀលក្នុងមួយម៉ែត្រគូប សម្រាប់កម្មករ កម្មការិនី សិស្ស និងនិស្សិត ហេតុនេះរដ្ឋាករទឹកបានចេញជំនួស ៦៥០រៀលក្នុងមួយម៉ែត្រគូប ។ ចាប់ពីខែមិថុនា ឆ្នាំ២០២២នេះតទៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងចាប់ផ្តើមចុះរៀបចំសាឡើងវិញចំពោះការលក់បន្តនៅតាមតំបន់នានា នៅក្នុងនិងជាយក្រុងភ្នំពេញ ដោយចាប់ផ្តើមពីតំបន់ផ្លូវវែងស្រែងមុនគេ និងតាមតំបន់រោងចក្រនៅជាយក្រុង ដើម្បីឱ្យពួកគេលក់ទឹកក្នុងតម្លៃមួយសមស្រប គឺ ៨០០រៀលក្នុងមួយម៉ែត្រគូប មិនមែន ២ ៥០០ទៅ ៣ ០០០រៀល ដូចមុននោះទេ។

ឯកឧត្តម **ឡុង ណារ៉ូ** បានបញ្ជាក់ថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងខិតខំប្រឹងបន្តវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាតដើម្បីធ្វើណាឱ្យការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងដោយមិនមានការរអាក់រអួល និងគ្រប់គ្រាន់តាមតម្រូវការរបស់អ្នកប្រើប្រាស់។ ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលកំពុងប្រើប្រាស់បណ្តាញទឹកពីរដ្ឋាករស្វយ័តក្រុងភ្នំពេញប្រមាណ ៩៩ភាគរយ ក្នុងនោះអ្នកដែលបង់ថ្លៃប្រើប្រាស់ទាន់ពេលវេលាកំណត់ មិនយឺតយ៉ាវមានប្រមាណ ៩០ភាគរយ និងប្រមាណ ៩ភាគរយទៀតប្រើពេលតែមួយខែក្នុងការបង់ យឺតយ៉ាវដោយសារបញ្ហាផ្សេងៗ។ ពោល គឺអ្នកប្រើប្រាស់ភាគច្រើន មិនខ្វល់ពីបញ្ហាបង់ថ្លៃទឹកនោះទេ តែធ្វើយ៉ាងណាឱ្យតែផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់តាមតម្រូវការ។

ឯកឧត្តមបានសង្កត់ធ្ងន់ថា " ការងាររបស់ខ្ញុំ ទិសដៅរបស់ខ្ញុំ គឺទឹកត្រូវតែមានទៅដល់គ្រប់អតិថិជនទាំងអស់គ្នានៅក្នុងគោលដៅមានសម្ពាធប្រើប្រាស់គ្រប់គ្រាន់ ផ្គត់ផ្គង់គ្រប់គ្រាន់ មិនមានអ្នកណាមួយទិញទឹកបន្តទេ "។ ចំពោះប្រជាពលរដ្ឋដែលគ្មានលទ្ធភាពបង់ថ្លៃច្បាប់ជាវទឹកប្រមាណជាង ១០០ដុល្លារ ដើម្បីតបណ្តាញទឹកស្អាតប្រើប្រាស់ រដ្ឋាករស្វយ័តក្រុងភ្នំពេញមានមូលនិធិពិសេសមួយជួយដល់ពលរដ្ឋក្រីក្រទាំងនោះឱ្យមានលទ្ធភាពតបណ្តាញទឹកស្អាតប្រើប្រាស់។ ក្រុមការងាររបស់រដ្ឋាករទឹកនឹងចុះទៅវាយតម្លៃចំពោះពលរដ្ឋណាដែលគ្មានលទ្ធភាពបង់ប្រាក់ជាវទឹកទៅតាមកម្រិតខ្វះខាតរបស់អតិថិជន។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញរំពឹងថា ចាប់ពីដើមឆ្នាំ២០២៣តទៅ ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ នឹងមិនប្រឈមនឹងការខ្វះខាតទឹកប្រើប្រាស់ទៀតឡើយ បន្ទាប់ពីរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបាក់ខែងបញ្ចប់ការសាងសង់នៅក្នុងឆ្នាំ២០២៣។ គិតមកទល់ពេលនេះ រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបាក់ខែងជំហានទី១ សម្រេចការសាងសង់បានជិត ៧០ភាគរយហើយ ៕

# ផ្លូវក្រវាត់ក្រុងទី៣ គ្រោងនឹងបញ្ចប់ការងារស្ថាបនាជាស្ថាពរ នាខែកញ្ញា ឆ្នាំ២០២៣

*អត្ថបទ ៖ នូ ប៊ុនធឿន ,រូបថត ៖ ក្រសួងសាធារណការ*

នៅខណៈពេលដែលរាជធានីភ្នំពេញ កំពុងត្រូវបានពង្រីកកាន់តែធំទៅៗ ស្របពេល កំណើនប្រជាជន និងការអភិវឌ្ឍ ឃើញថាការធ្វើចរាចរណ៍យានយន្តគ្រប់ប្រភេទទៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញជួបប្រទះការកកស្ទះជារឿយៗ បញ្ហានេះគឺជាចំណុចដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជា តែងតែបានគិតគូរ និងផ្តល់អនុសាសន៍ណែនាំដល់ក្រសួងស្ថាប័នពាក់ព័ន្ធធ្វើការសិក្សាលទ្ធភាពសាងសង់ផ្លូវក្រវាត់ក្រុង ដើម្បីជួយកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ដែលធ្លាប់មានកន្លងមក






ឯកឧត្តម លឹម ស៊ីដេនីន ដឹកនាំក្រុមការងារបច្ចេកទេសត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់ផ្លូវក្រវាត់ក្រុងទី៣





គ្រឿងចក្រកំពុងដំណើរការស្ថាបនាផ្លូវ និងបុកគ្រឹះចាក់សសរស្ពាន នៃគម្រោងស្ថាបនាផ្លូវក្រវាត់ក្រុងទី៣

និងដើម្បីសម្រួលដល់ការធ្វើដំណើរ និងចរាចរណ៍ក្នុងរាជធានីភ្នំពេញ ។

ជាលទ្ធផលកន្លងមករាជរដ្ឋាភិបាលកម្ពុជាយើងបានកសាងសាងផ្លូវក្រវាត់ក្រុងទី១ និងទី២រួចរាល់ និងដាក់ឱ្យដំណើរការចរាចរបានរួចរាល់ ដោយឡែកផ្លូវក្រវាត់ក្រុងទី៣ កំពុងតែដំណើរការសាងសង់។ ការសាងសង់ផ្លូវក្រវាត់ក្រុងទី៣ នេះគឺជាការតភ្ជាប់ផ្ទៃក្រុង និងសមាហរណកម្មតំបន់ពិសេសតភ្ជាប់ផ្លូវអាស៊ានហាយវេ និងផ្លូវរបៀងសេដ្ឋកិច្ចសំខាន់របស់អនុតំបន់មេគង្គ រួមចំណែកក្នុងការសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែនជំរុញពាណិជ្ជកម្មអន្តរជាតិ និងភស្តុភារកម្មតំបន់ និងប្រែក្លាយទឹកដីដែលនៅសងខាងផ្លូវក្រវាត់ក្រុងទាំងនេះទៅជាតំបន់អភិវឌ្ឍន៍បុរីលំនៅដ្ឋាន តំបន់ភស្តុភាកម្ម និងឧស្សាហកម្មដ៏មានសក្តានុពល និងប្រសិទ្ធភាពសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

គួររំលឹកដែរថា ផ្លូវក្រវាត់ក្រុងទី៣ ត្រូវបានធ្វើពិធីបើកការដ្ឋានស្ថាបនាកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។ ផ្លូវក្រវាត់ក្រុងទី៣ ចាប់ផ្តើមពីផ្លូវជាតិលេខ៤ ដល់ផ្លូវជាតិលេខ



អ្នកបច្ចេកទេសកំពុងចាក់អ៊ុតផ្លូវបន្ថែម





ទិដ្ឋភាពផ្លូវកំពុងដំណើរស្ថាបនាសាងសង់

១ ឆ្លងកាត់ក្រុងភ្នំពេញ ខេត្តកណ្តាល ចំណុចចាប់ផ្តើមពីគីឡូម៉ែត្រលេខ១៤+១០៥ នៃផ្លូវជាតិលេខ៤ ទៅចំណុចបញ្ចប់នៅគីឡូម៉ែត្រលេខ២៤+៨៤០ នៃផ្លូវជាតិលេខ១ ដែលសរុបរួមមានប្រវែង ៥២,៩៨៣គីឡូម៉ែត្រ ក្នុងនោះផ្លូវមេមានប្រវែង ៤៧,៦០៨គីឡូម៉ែត្រ ផ្លូវខ្នែងប្រវែង ៥,៣៧៥គីឡូម៉ែត្រ មានស្ពានអាកាស ៤កន្លែង ឆ្លងកាត់ផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៤ និងមានស្ពានឆ្លងកាត់ទន្លេពីរកន្លែងទៀត គឺស្ពានបាសាក់ខាងកើត មានប្រវែង ៦៣០ម៉ែត្រ ស្ពានបាសាក់ខាងលិច មានប្រវែង ៣៦៦ម៉ែត្រ ប្រើរយៈពេលសាងសង់ ៤២ខែ ដោយចំណាយថវិកាអស់ ២៦៧,៦៧ លានដុល្លារ សាងសង់ដោយក្រុមហ៊ុនសៀងហៃ គ្រុបខូអិលធីឌី ក្រោមការត្រួតពិនិត្យបច្ចេកទេសរបស់ក្រុមហ៊ុនក្វាងចូវ៉ាន់អាន។

ការស្ថាបនាផ្លូវក្រវាត់ក្រុងទី៣ មានភាពយឺតយ៉ាវជាងគម្រោងដែលបានគ្រោងបញ្ចប់នៅខែធ្នូឆ្នាំ២០២១ ដោយសារមានកត្តារាំងស្ទះជាច្រើន ដូចជា ករណីផ្ទុះករណីជំងឺកូវីដ-១៩ រួមទាំង ការដោះស្រាយផលប៉ះពាល់ជាដើម។ គិតមកដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ កន្លងទៅនេះ ជាលទ្ធផលផ្លូវក្រវាត់ក្រុងទី៣ នេះគឺសម្រេចបាន៧៣,៧០ភាគរយហើយ។

នេះជាតួលេខដែលបានបញ្ជាក់ដោយក្រុមការងារបច្ចេកទេសចម្រុះ ដែលដឹកនាំដោយឯកឧត្តម **លឹម ស៊ីដេនីន** រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលបានដឹកនាំក្រុមការងារចម្រុះចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងតាមដានវឌ្ឍនភាពការងារសាងសង់។

ផ្អែកតាមរបាយការណ៍របស់អគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសាធារណៈការ និងដឹកជញ្ជូនបានឱ្យដឹងថា វឌ្ឍនភាពការងារនៃគម្រោងស្ថាបនាផ្លូវក្រវាត់ក្រុងខ្សែទី៣ គ្រោងនឹងបញ្ចប់ជាស្ថាពរនៅមុនខែកញ្ញា ឆ្នាំ២០២៣ ខាងមុខ៕


ការស្ថាបនាផ្លូវឆ្លងកាត់ទន្លេ


ទិដ្ឋភាពផ្លូវកំពុងស្ថាបនាសាងសង់

# អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣មានសមត្ថភាពចម្រោះទឹកកខ្វក់បាន ២ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ

*អត្ថបទ៖ ឡាយ សារ៉ុម , រូបថត៖ មន្ទីរព័ត៌មានខេត្តព្រះសីហនុ*



*ឯកឧត្តម គួច ចំរើន អញ្ជើញចុះពិនិត្យសកម្មភាពការងារសាងសង់អាងប្រព្រឹត្តិកម្មចម្រោះទឹកកខ្វក់*

ឯកឧត្តម **គួច ចំរើន** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញចុះពិនិត្យការដ្ឋានសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣ ស្ថិតនៅក្នុងសង្កាត់លេខ៤ ក្រុងព្រះសីហនុ នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២។

អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣មានសមត្ថភាពចម្រោះទឹកកខ្វក់បាន២ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ គិតមកដល់បច្ចុប្បន្ននេះ ការសាងសង់សម្រេចបានប្រមាណជា៥០ភាគរយហើយ។



*ឯកឧត្តម គួច ចំរើន អញ្ជើញចុះពិនិត្យសកម្មភាពការងារសាងសង់អាងប្រព្រឹត្តិកម្មចម្រោះទឹកកខ្វក់*



*ឯកឧត្តម គួច ចំរើន អញ្ជើញចុះពិនិត្យសកម្មភាពការងារសាងសង់អាងប្រព្រឹត្តិកម្មចម្រោះទឹកកខ្វក់*

លោក **សេខ ទិមុល** ប្រធានការដ្ឋានសាងសង់របស់ក្រុមហ៊ុន X-water មានប្រសាសនថា ទាក់ទងការដ្ឋានសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣នេះមកដល់បច្ចុប្បន្នសម្រេចការសាងសង់បានប្រមាណជា៥០ភាគរយ ហើយទឹកដែលប្រព្រឹត្តិកម្មរួចបង្ហូរទៅសមុទ្រមានអត្ថប្រយោជន៍ជួយការពារបរិស្ថានសមុទ្ររបស់យើងជាចម្បង ដោយសារតែកន្លងមកទឹកសមុទ្ររបស់យើងបានហូរលាយឡំទៅដោយទឹកកខ្វក់គ្រប់ប្រភេទ ហូរមកពីតាមគេហដ្ឋាន ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ។ល។ ធ្វើឱ្យប៉ះពាល់បរិស្ថានសមុទ្រ បើយើងប្រើអាងប្រព្រឹត្តិកម្មទឹកកខ្វក់នេះ យើងអាចធ្វើឱ្យទឹកសមុទ្រក៏ដូចជាឆ្នេរសមុទ្ររបស់យើងស្អាត លែងមានជាតិពុលប៉ះពាល់ជីវៈចម្រុះក្នុងសមុទ្រ។ តាមបទពិសោធន៍អាងប្រព្រឹត្តិកម្មទី១ និងទី២ ដែលសាងសង់ និងដាក់ឱ្យដំណើរការក្រោមស្តង់ដារក្រសួងបរិស្ថាន ដែលបានអនុញ្ញាតទឹកហូរចូលសមុទ្រកាន់តែមានសុវត្ថិភាពសម្រាប់ជីវៈចម្រុះ។ អាងប្រព្រឹត្តិកម្មទី៣នេះមានសមត្ថភាពផលិតទឹកបាន២ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃសាងសង់លើផ្ទៃដីមួយហិកតា។ ការដ្ឋានបានបែងចែកជាពីរតំណាក់កាល ទី១ សំណង់ទីវាល អាចបញ្ចប់មុនចូលឆ្នាំខ្មែរនាឆ្នាំ២០២៣ខាងមុខ។ ទី២ ពាក់ព័ន្ធប្រព័ន្ធមេកានិកបន្តប្រហែលពី ៣ ទៅ ៤ខែទៀត ដោយចាប់ផ្តើមតេស្តលើប្រព័ន្ធបច្ចេកទេសរបស់យើងរួចរាល់ទើបប្រគល់ការងារឱ្យមកខេត្តគ្រប់គ្រងដូចអាងប្រព្រឹត្តិកម្មទី១ និងទី២ដែរ។

ក្នុងឱកាសចុះពិនិត្យសកម្មភាពការងារសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣ឯកឧត្តមអភិបាលខេត្តបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារបច្ចេកទេស ទោះបីមានភ្លៀងយ៉ាងណាក៏ដោយ ក៏ក្រុមការងារនៅតែបំពេញការងារយ៉ាងមមាញឹក។ ជាមួយគ្នានេះដែរ ឯកឧត្តមបានធ្វើការណែនាំឱ្យក្រុមការងារបច្ចេកទេសត្រូវបង្កើនសកម្មភាពការងារឱ្យកាន់តែលឿនបន្ថែមទៀត ដើម្បីឱ្យការដ្ឋានអាងប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣របស់យើងបានឆាប់រួចរាល់តាមផែនការគ្រោងទុកប្រកបដោយគុណភាពតាមស្តង់ដារបច្ចេកទេស និងធានាបានការប្រើប្រាស់យូរអង្វែងសម្រាប់ជាផលប្រយោជន៍រួមរបស់យើងទាំងអស់គ្នា៕



# ឯកឧត្តម ឡុង សេង និងលោកជំទាវ ចែកអំណោយជូនប្រជាពលរដ្ឋ ជាង ១០០គ្រួសារ នៅក្នុងភូមិពោធិតាប៉ាង និងភូមិ ព្រែកតាសៅ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល

*អត្ថបទ និងរូបថត ៖ ឌី ណារិន*



ឯកឧត្តម ឡុង សេង និងលោកជំទាវ ចែកអំណោយជូនប្រជាពលរដ្ឋនៅក្នុងភូមិផងរបងជាមួយ





នៅក្នុងឱកាសនៃពិធីចម្រើន ព្រះបរិត្តពុទ្ធជ័យមង្គលខួប អាពាហ៍ពិពាហ៍គម្រប់ ៤០ ឆ្នាំ ឯកឧត្តម **ឡុង សេង** អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន និងលោកជំទាវ **លី ប៊ុនសៃ** និងក្រុមគ្រួសារ បានរៀបចំជាអំណោយនិងថវិកាចែកជូនដល់បងប្អូនប្រជាពលរដ្ឋជួបការលំបាកផ្នែកជីវភាពរស់នៅប្រចាំថ្ងៃដោយសារបញ្ហាជំងឺកូវីដ១៩-នាពេលកន្លងមកនេះ ស្ថិតនៅភូមិពោធិតាប៉ាង

ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ។

ពីធីចែកអំណោយសប្បុរសធម៌នេះធ្វើឡើងនៅព្រឹកថ្ងៃទី២៨ខែមេសា ឆ្នាំ២០២២ នាគេហដ្ឋាន ឯកឧត្តម **ឡុង សេង** ជូនប្រជាពលរដ្ឋ ដែលរស់នៅភូមិផងរបងជិតគ្នា ។អំណោយរបស់ឯកឧត្តម **ឡុង សេង** និង លោកជំទាវ **លី ប៊ុនសៃ** និងលោកយាយ **ពិន ស៊ីវឡាំង** នាឱកាសនោះបានរៀបចំជូនប្រជាពលរដ្ឋចំនួនជាង ១០០គ្រួសារ ដោយក្នុង ១គ្រួសារទទួលបានអង្ករ ១៥គីឡូក្រាម ប៊ីចេង ស្ករស អំបិល ទឹកត្រី ទឹកស៊ីអ៊ីវ មី ១កេស និង ថវិកា ២ម៉ឺនរៀល ។

ជាការចូលរួមចំណែកក្នុងកិច្ចការងារសប្បុរសធម៌ នាឱកាសនោះ ឯកឧត្តម **លី វ៉ាន់ហុង** ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន បានចូលរួមជាថវិកាចំនួន ២លានរៀលផងដែរ ។

ឯកឧត្តម **ឡុង សេង** មានប្រសាសន៍សំណេះសំណាលជាមួយប្រជាពលរដ្ឋនាឱកាសនោះថ្លែងថាដោយសារស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩មានការថយចុះច្រើន និងការលើកលែងវិធានការសុខាភិបាលពិសេសប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ **ហ៊ុន សែន** បានលើកលែងកាតព្វកិច្ចពាក់ម៉ាស នៅទូទាំងប្រទេសទើបយើងមានឱកាសបានជួបជុំគ្នាច្រើនឡើងវិញបង្កភាពសប្បាយរីករាយ តែទោះជាយ៉ាងណាសូមបងប្អូនប្រជាពលរដ្ឋ បន្តរក្សាអនាម័យដើម្បីសុខភាពល្អទាំងអស់គ្នា ។ អ្វីដែលសំខាន់ដែរនោះគឺ សូមឱ្យបងប្អូនប្រជាពលរដ្ឋដែលនៅមិនបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញទី៣ និងទី៤ ត្រូវទៅចាក់ឱ្យបានគ្រប់គ្នា ដើម្បីធ្វើមានភាពធូរ៉ាក្នុងសហគមន៍ កាត់បន្ថយការឆ្លងរីករាលដាលឱ្យនៅតិចបំផុត ។

ឯកឧត្តម **ឡុង សេង** បានបញ្ជាក់ថា អំណោយទាំងនេះគឺជាការចូលរួមចំណែកចែករំលែកនូវការលំបាកខ្វះខាតដោយសាររងគ្រោះផលប៉ះពាល់នៃជំងឺកូវីដ-១៩។ដូច្នេះអ្វីដែលសំខាន់ចំពោះមុខ គឺបងប្អូន ត្រូវបន្ត ប្រឹងប្រែងប្រកបរបររកស៊ីនិងធ្វើស្រែចំការ បង្កបង្កើនផលដាំដំណាំរួមផ្សំផ្សេងៗ ដើម្បីធ្វើឱ្យស្ថានភាពជីវភាពរស់នៅបានល្អប្រសើរឡើងវិញបន្ទាប់ពីរាជរដ្ឋាភិបាលបើកឱ្យដំណើរការអាជីវកម្ម និងប្រកបរបររកស៊ីឡើងវិញលើគ្រប់វិស័យទូទាំងប្រទេស ៕









ប្រជាពលរដ្ឋ ទទួលអំនោយពីក្រុមគ្រួសារឯកឧត្តម ឡុង សេង

# កម្ពុជារៀបចំព្រឹត្តិការណ៍ មហោស្រពភាពយន្ត អន្តរជាតិលើកទី១១

## ដោយមានចាក់បញ្ចាំងខ្សែភាពយន្ត ចំនួន ១៤៤ចំណងជើង មកពី ២៦ប្រទេស

*អត្ថបទ និងរូបថត ៖ វ៉ាន់ ច័ន្ទភិរុណា*




ព្រឹត្តិការណ៍មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១ (CIFF) មានរៀបចំចាក់បញ្ចាំងខ្សែភាពយន្តមកពី២៦ប្រទេស និងមានរឿងចំនួន១៤៤ចំណងជើង ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២២ នៅតាមបណ្តារោងភាពយន្តធំៗ និងទីកន្លែងល្អៗជាច្រើនទៀតនៅក្នុងរាជធានីភ្នំពេញ ដោយឥតគិតថ្លៃ ក្នុងគោលបំណងបង្ហាញពីការអប់រំទាក់ទងនឹងទន្លេ វប្បធម៌ ភាសារបស់ជនជាតិដើមភាគតិចទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស។ ការបញ្ចាំងជាង ១៦០លើក និងកម្មវិធីជួបជុំផ្សេងៗ រួមមាន៖ ភាពយន្តខ្នាតខ្លី ភាពយន្តខ្នាតវែង ភាពយន្តឯកសារ និងគំនូរជីវចល នៅតាមបណ្តារោងភាពយន្តធំៗ និងទីកន្លែងល្អៗជាច្រើនទៀតនៅក្នុងទីក្រុងភ្នំពេញ ដូចជា៖ រោងភាពយន្ត Legend Cinema , Major Cineplex , Prime Cineplex , **វិទ្យាស្ថានបារាំង** , **មជ្ឈមណ្ឌលបុប្ផាណាសាលចតុម្មុខ**, Rosewood



ក្នុងអង្គពិធីមានការចូលរួមពីផលិតករ អ្នកសារព័ត៌មាន ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ

Hotel , Java Creative Cafe **និង** Factory Phnom Penh ។

លោក Cedric Eloy ប្រធានមហោស្រពភាពយន្តអន្តរជាតិកម្ពុជា បានលើកឡើងក្នុងសន្និសីទសារព័ត៌មានថា មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១ នេះ អាចប្រព្រឹត្តទៅបានគឺដោយសាររាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានធ្វើការងារដោយមិនគិតពីការនឿយហត់ ដើម្បីស្តារឡើងវិញនូវសុវត្ថិភាពនិងទីកន្លែងសម្រាប់សិល្បៈ។ សម្រាប់ខ្សែភាពយន្តកម្ពុជា ខ្សែភាពយន្តដែលផលិតនៅកម្ពុជា និងនិយាយអំពីកម្ពុជារួមមាន៖




លោក Cedric Eloy ប្រធានមហោស្រពភាពយន្តអន្តរជាតិកម្ពុជា ឡើងមានមតិស្វាគមន៍



ការបញ្ចាំងជាលើកដំបូង ខ្សែភាពយន្តកម្ពុជាល្បីៗ ដូចជា រឿង «**គ្រប់យ៉ាងនឹងប្រសើរ**» របស់លោក **ប៉ាន់ រិទ្ធី** (ដែលទទួលពានរង្វាន់ខ្លាឃ្មុំប្រាក់ នៅមហោស្រពភាពយន្តទីក្រុងប៊ែរឡាំង ២០២២) រឿង «**គ្រួសារ**» (ដែលបានចាក់បញ្ចាំងនៅមហោស្រពកាន ផ្នែកភាពយន្តឯករាជ្យ) រឿង «**ប៊ូឌីញូស**» របស់លោក **នាង កាវិច** (ដែលទទួលពានរង្វាន់នៅមហោស្រពភាពយន្តទីក្រុងវ៉ឺនីស) និងរឿងថ្មីៗរបស់ផលិតកម្ម LD Pictures «**លោកប៉ាមហាភូរ**» និងរឿង «**នាឡិកា** (Remastered)» ។





លោក ឯក ប៊ុនថា អគ្គនាយករង
នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ក្នុងសន្និសីទសារព័ត៌មានក៏មានការចូលរួមពីលោក Cedric Eloy ប្រធានមហោស្រពភាពយន្តអន្តរជាតិកម្ពុជា លោក **ជា សុភាព** នាយកប្រតិបត្តិមជ្ឈមណ្ឌល ធនធានសោតទស្សន៍បុប្ផាណា និងលោក **ឯក ប៊ុនថា** អគ្គនាយករងនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងមានការចូលរួមពីផលិតករ អ្នកសារព័ត៌មាន ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិផងដែរ។

មហោស្រព CIFF ក៏មានគម្រោងតភ្ជាប់ទំនាក់ទំនងជាមួយសមិទ្ធិករភាពយន្តខ្មែរនៅបរទេសផងដែរ ហើយនៅក្នុងឆ្នាំនេះ CIFF មានក្ដីសោមនស្សរីករាយនាំយក កញ្ញា **អាលី សុនឆន** ដែលជាសិល្បការនីកម្ពុជា-អូស្ត្រាលី និងជាសមិទ្ធិករភាពយន្ត ដែលមកបង្ហាញស្នាដៃរបស់នាងជាលើកទី ១នៅកម្ពុជា ក្នុងនោះក៏មានខ្សែភាពយន្តដែល នាងបានទទួលពានរង្វាន់ផងដែរគឺរឿង «**ផ្ទះកៅស៊ូ**»។ មហោស្រព CIFF នឹង បង្ហាញស្នាដៃរបស់សមិទ្ធិករភាពយន្តខ្មែរវ័យក្មេងជាង ៥០នាក់ដែលបានទទួលការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌល



លោក ជា សុភាព នាយកប្រតិបត្តិ
មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា



ផលិតករ អ្នកសារព័ត៌មាន ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញចូលរួមក្នុងអង្គពិធី

បុប្ផាណាផងដែរ។ចំណែកឯខ្សែភាពយន្តឯកសារខ្នាតវែងឆ្នាំនេះ រួមមានការចាក់បញ្ចាំងលើកដំបូងដ៏ពិសេសរបស់ ANGKOR: THE LOST EMPIRE ( Australia ) នៅក្នុង IMAX 3D, រឿង «**វិទ្យុសកម្ម**» របស់លោក **ប៉ាន់ រិទ្ធី** ដែលទទួលបានពានរង្វាន់ IDFA នៅវៀតណាមទៀតផង និងរឿង «**កុមារនៅក្នុងអ័ព្ទ**» របស់កញ្ញា Hâ Le Diem មកពីវៀតណាម។ មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១ក៏បានបង្ហាញខ្សែភាពយន្តដំបូងៗរបស់លោក **ដែម ឌីវ៉ាន់** គឺរឿង «**ទន្លេមេគង្គក្រោម**» និងរឿង «**ខ្មែរ ! ខ្មែរ**» ដែលឆ្លុះបញ្ចាំងរូបភាពដ៏កម្រអំពីប្រទេសឡាវ និងកម្ពុជានៅដើមឆ្នាំ១៩៧០។

សូមបញ្ជាក់ដែរថា មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១ ស្របនឹងការប្រារព្ធខួបលើកទី៧០ នៃទំនាក់ទំនងការទូតរវាងកម្ពុជា-អូស្ត្រាលី ដោយផ្តោតលើប្រទេសអូស្ត្រាលីក្នុងឆ្នាំនេះ ។ ភាពយន្តដ៏កម្រមកពីអូស្ត្រាលីចំនួន ១៦រឿង ដែលផលិតពីឆ្នាំ១៩៥៣ ដល់ឆ្នាំ២០២២ ត្រូវបានចាក់បញ្ចាំងនៅមហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១នេះផងដែរ។

គួររំលឹកផងដែរថា មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១១ គឺជាព្រឹត្តិការណ៍ភាពយន្តនិងវប្បធម៌ធំជាងគេបំផុតនៅកម្ពុជា ដោយបានចាប់ផ្តើមនៅឆ្នាំ២០១០។ មហោស្រពនេះ គឺជាកត្តាលីករមួយសម្រាប់វិស័យភាពយន្តដោយបានប្រមូលផ្តុំទស្សនិកជនជាង ២០ ០០០នាក់ ជារៀងរាល់ឆ្នាំ។ មហោស្រព CIFF ក៏ជាស្ពានមួយភ្ជាប់កម្ពុជាទៅកាន់ពិភពលោកតាមរយៈលក្ខណៈសាកលនៃភាសារបស់ភាពយន្ត និងវប្បធម៌ដើម្បីលើកស្ទួយចរាចរណ៍ភាពយន្តនៅក្នុងតំបន់ និងផ្សព្វផ្សាយពីផលិតកម្មភាពយន្តកម្ពុជា៕



ផលិតករ ភ្ញៀវកិត្តិយសជាតិ អញ្ជើញចូលរួមក្នុងអង្គពិធី



# រយៈពេល ៤ ខែ ដើមឆ្នាំ ២០២២ កម្ពុជានាំចេញអង្ករ និងស្រូវ គិតជាទឹកប្រាក់ជាង ៥០០ លានដុល្លារ

*អត្ថបទ ៖ សាត សុផល, រូបថត ៖ ឯកសារ*



អង្ករកម្ពុជាដែលបានសម្រិតសម្រាំងទុកដាក់ក្នុងឃ្លាំង និងរៀបចំការនាំចេញទៅក្រៅប្រទេស

ក្នុងរយៈពេល៤ខែ ដើមឆ្នាំ២០២២ កម្ពុជាបានសម្រេចការនាំចេញអង្ករបាន ចំនួន ២២១ ១៣៨ តោន និងនាំចេញស្រូវបានចំនួន ១ ៦៤៨ ៤៧៤តោន ដែលគិតជាទឹកប្រាក់សរុបមានចំនួន ៥១៦,២១លានដុល្លារអាមេរិក។






យោងតាមរបាយការណ៍សហព័ន្ធស្រូវអង្ករកម្ពុជា បានឱ្យដឹងថា ក្នុងរយៈពេល ៤ខែ ដើមឆ្នាំ២០២២ នេះ មានក្រុមហ៊ុននាំចេញចំនួន ៤៨ក្រុមហ៊ុន បានធ្វើការនាំចេញទៅកាន់គោលដៅចំនួន៥៤ដែលក្នុងនោះ កម្ពុជាបាននាំទៅ ប្រទេសចិន និងតំបន់ស្វយ័តហុងកុង ម៉ាកាវ បានចំនួន ១១៥ ២៥៥ តោន ឬស្មើនឹង ៥២,១២% នៃការនាំចេញសរុប ដែលគិតជាទឹកប្រាក់មានចំនួន ៦២,៧៤លានដុល្លារអាមេរិក ការនាំចេញទៅតំបន់អឺរ៉ុបមានបរិមាណសរុបចំនួន ៦៨ ៥៥៥ តោន ឬស្មើនឹង ៣១% គិតជាទឹកប្រាក់មានចំនួន ៥១,០២លានដុល្លារអាមេរិក ការនាំចេញទៅកាន់តំបន់សមាជិកអាស៊ានមានចំនួន ២១ ៨៧៦ តោន ឬស្មើនឹង ៩,៨៩% គិតជាទឹកប្រាក់មានចំនួន ១៣,៩០លាន








ទិន្នន័យនៃការនាំអង្ករចេញក្នុងរយៈពេល ៤ ខែ ដើមឆ្នាំ ២០២២

ដុល្លារសហរដ្ឋអាមេរិក និងបណ្តាប្រទេសផ្សេងៗ ក្រៅពីតំបន់ខាងលើបានចំនួន ១៥ ៤៥២តោន ឬស្មើនឹង ៦,៩៩% គិតជាទឹកប្រាក់មានចំនួន ១១,៧៤លានដុល្លារអាមេរិក។

របាយការណ៍បានឱ្យដឹងទៀតថា បរិមាណនៃការនាំចេញក្នុងរយៈពេល ៤ខែនេះ មានកំណើនចំនួន ១៤,៨៨% ឬស្មើនឹងចំនួន ២៨ ៦៤៣តោន។ កម្ពុជាបាននាំចេញស្រូវគ្រប់ប្រភេទឆ្លងកាត់ព្រំដែនជាមួយប្រទេសវៀតណាមបានចំនួន ១ ៦៤៨ ៤៧៤តោន គិតជាទឹកប្រាក់ប៉ាន់ស្មានប្រមាណជាចំនួន ៣៧៦,៦៤លានដុល្លារអាមេរិក។

ប្រភេទអង្ករក្រអូបគ្រប់ប្រភេទមានបរិមាណចំនួន៦៧,១២% អង្ករស ចំនួន ៣០,១៣%អង្ករចំហុយចំនួន ១,០៧% និងអង្ករសរីរាង្គចំនួន ១,៦៨% ។





# កីឡាជិះសេះកម្ពុជា ត្រៀមខ្លួនដើម្បីសម្រេចគោលដៅ ឆ្ពោះទៅធ្វើម្ចាស់ផ្ទះ ស៊ីហ្គេម ២០២៣



*អត្ថបទ និងរូបថត ៖ ហេង ណាលីន*



ការហាត់ជិះសេះផ្លោះរបារ



លោកស្រី ទេព ម៉ូណា ប្រធានសហព័ន្ធកម្ពុជាបង្ហាត់ជិះសេះ

សហព័ន្ធកម្ពុជាបង្ហាត់ជិះសេះ បានរៀបចំវគ្គបណ្តុះបណ្តាលមន្រ្តីបច្ចេកទេសថ្នាក់ជាតិ កីឡាជិះសេះលោតផ្លោះរបារ កម្រិត១ រយៈពេល ២ថ្ងៃ គឺពីថ្ងៃទី១១-១២ ខែមិថុនា ឆ្នាំ២០២២ នៅក្លិបកីឡា Cambodian County Club រាជធានីភ្នំពេញ ដើម្បីសម្រេចគោលដៅឆ្ពោះ ទៅទទួលរៀបចំធ្វើជាម្ចាស់ផ្ទះ ស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣ នៅកម្ពុជា ដែលវគ្គនេះដំណើរការដោយប្រើប្រាស់ថវិកាគាំទ្ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

លោកស្រី **ទេព ម៉ូណា** ប្រធានសហព័ន្ធកម្ពុជាបង្ហាត់ជិះសេះ មានប្រសាសន៍ថា ដើម្បីសម្រេចគោលដៅឆ្ពោះទៅ




ពិធីបើកវគ្គបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសថ្នាក់ជាតិ កីឡាជិះសេះលោតផ្លោះរបារ

ស្វែងរកមេដាយមាស ក្នុងឋានៈជាម្ចាស់ផ្ទះស៊ីហ្គេមឆ្នាំ២០២៣ នៅកម្ពុជា គឺដាច់ខាតយើងមិនអាចទម្លាក់ដៃបានទេ។ ដូច្នេះ សហព័ន្ធនៅតែខិតខំឱ្យអស់ពីលទ្ធភាព ទាំងលើការហ្វឹកហាត់របស់ក្រុមជម្រើសជាតិ ទាំងការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសឱ្យបានរួចរាល់នៃគោលដៅនេះ។

លោកស្រី **ទេព ម៉ូណា** បន្ថែមថា សហព័ន្ធបានត្រៀមគ្រប់លក្ខណៈសម្បត្តិ ទាំងការសម្រួចគុណភាពបច្ចេកទេសរបស់កីឡាករ កីឡាការិនីជម្រើសជាតិ និងការបណ្តុះបណ្តាលធនធានមន្ត្រីបច្ចេកទេសក្នុងការថែទាំសេះឱ្យបានរួចរាល់ និងទាន់ពេលវេលាសម្រាប់ដំណើរឆ្ពោះទៅទទួលរៀបចំធ្វើម្ចាស់ផ្ទះស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣ ជាប្រវត្តិសាស្ត្រដំបូងរបស់ព្រះរាជាណាចក្រកម្ពុជា និងក្រោយបញ្ចប់ស៊ីហ្គេមឆ្នាំ២០២៣ សហព័ន្ធក៏នៅតែបន្តការខិតខំបន្ថែម សម្រាប់ត្រៀមលក្ខណៈនៃស៊ីហ្គេម នាពេលខាងមុខដែលនឹងចូលមកជាបន្តបន្ទាប់ នៅប្រទេសផ្សេងៗទៀត។ «ដូច្នេះយើងទាំងអស់គ្នា មិនអាចទម្លាក់ដៃបានទេ ពោលគឺត្រូវបន្តដំណើរការអភិវឌ្ឍវិស័យកីឡាជិះសេះ





ក្រុមអ្នកជិះសេះពិនិត្យលក្ខណៈសម្បត្តិ និងសុខភាពសេះរបស់ខ្លួន





ក្រុមអ្នកជិះសេះពិភាក្សាជាក់ស្ដែងអំពីជំនាញជិះសេះ

កម្ពុជា ស្របតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន និងស្របតាមសន្ទស្សន៍មេដាយមាស១គ្រឿង ដែលគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ២០២៣ (CAMSOC) បានដាក់ចេញជាគោលការណ៍»។

ប្រធានសហព័ន្ធកម្ពុជាបង្ហាត់ជិះសេះរូបនេះ បានលើកឡើងទៀតថា នៅក្នុងការប្រកួតតេស្តសមត្ថភាពរបស់កីឡាករ កីឡាការិនី នៃវគ្គបណ្ដុះបណ្ដាលថ្នាក់នេះ លោកស្រីឃើញថា មានកីឡាករ កីឡាការិនី ជម្រើសជាតិ ៤នាក់ ធ្វើបានយ៉ាងល្អ លើការបញ្ជាជិះសេះលោតផ្លោះរបារ។ ជាមួយគ្នានោះ ក៏មាន កីឡាករ កីឡាការិនី មួយចំនួនទៀត កំពុង បង្ហាញនូវភាពល្អប្រសើរ ផងដែរ ប៉ុន្តែ ត្រូវហ្វឹកហាត់ សមនៅលើកម្ពស់ ៦០ សង់ទីម៉ែត្រ សិន ជាមួយនឹងសេះចំនួន ៣ក្បាល ដែលត្រូវបាននាំចូលពីប្រទេសបារាំង ទើបបានជាង ១ខែនេះ ហើយនៅពេលខាងមុខនឹងព្យាយាមលោតឱ្យបានដល់ ១ម៉ែត្រ និង ១,២០ម៉ែត្រ ដែលជាតម្រូវការស្តង់ដារប្រកួត ។

បន្ថែមពីលើនេះ លោកស្រីប្រធាន ក៏បានលើកឡើងទៀតថា ការថែទាំងសេះ គឺជារឿងសំខាន់បំផុត ទាំងមុនពេលប្រកួត ទាំងក្នុងពេលប្រកួត និងក្រោយពេលប្រកួត ដោយត្រូវត្រួត











ក្រុមកីឡាករជិះសេះហាត់ការជិះផ្លោះរបារក្នុងកម្រិត១ មានសេះចំនួន ៣ក្បាល

ពិនិត្យយ៉ាងយកចិត្តទុកដាក់ពីក្រុមពេទ្យសត្វ និងអ្នកថែទាំសេះ ដោយថែទាំទៅលើសុខភាព ដូចជាកម្តៅ ចង្វាក់បេះដូង ការរងរបួសជាដើម។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសថ្នាក់ជាតិ កីឡាជិះសេះលោតផ្លោះរបារ កម្រិត១ ឆ្នាំ២០២២នេះ ផ្តោតសំខាន់លើការសិក្សា អំពីការត្រួតពិនិត្យសុខភាព និងស្ថានភាពសេះ ការព្យាបាលក្នុងពេលប្រកួត និងក្រោយពេលប្រកួត។ ផ្តោតសំខាន់លើការត្រួតពិនិត្យសុខភាពសេះ និងកីឡាករកីឡាការិនីជិះសេះផ្លោះរបារ ការប្រកួតជិះសេះផ្លោះរបារ និងការត្រួតពិនិត្យសេះជាមួយនឹងកីឡាករ កីឡាការិនីជិះសេះ រត់រយៈចម្ងាយឆ្ងាយ។ វគ្គបណ្តុះបណ្តាលកីឡាជិះសេះថ្នាក់ជាតិនេះ ធ្វើឡើងដើម្បីឱ្យមន្ត្រីបច្ចេកទេស កីឡាករ កីឡាការិនី ក៏ដូចជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម បានយល់កាន់តែច្បាស់អំពីការងារបច្ចេកទេស ការមើលថែទាំសេះ តាមរយៈការអនុវត្តជាក់ស្តែងផងដែរ ៕



# ភ្នំណាមលៀវជា ជម្រកដ៏ សំខាន់សម្រាប់ សត្វ និង រុក្ខជាតិគ្រប់ប្រភេទ

អត្ថបទ៖ ឡាយ សារ៉ុម ,ប្រកពក្រសួងនិងមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី



ប្រភេទសត្វល្មូន និងថលជលិក

ក្រោយពីការសិក្សាស្រាវជ្រាវ ក្រុមអ្នកជំនាញមកពីក្រសួង និងមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី បានប្រមូល និងកំណត់អត្តសញ្ញាណប្រភេទសត្វ និងរុក្ខជាតិបានច្រើនប្រភេទ។ ក្នុងនោះ ថនិកសត្វធំចំនួន៧ប្រភេទ ពពួកប្រចៀវចំនួន១៤ប្រភេទ បក្សីចំនួន ៩៧ប្រភេទ ល្មូន និងថលជលិក (សត្វដែលអាចរស់នៅលើគោកក៏បាន ក្នុងទឹកក៏បាន) ចំនួន ៣៨ប្រភេទ សត្វល្អិតក្នុងទឹកបានប្រមូលជាសំណាកចំនួន១៨កែវ និង៥៤បំពង់តូចចំនួន៩៧។

ក្រុមការងារជំនាញនាយកដ្ឋានជីវៈចម្រុះ នៃក្រសួងបរិស្ថាន ជាមួយមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី ដែលបានទទួលការគាំទ្រ



ប្រភេទសត្វល្មូន និងថលជលិក

ថវិកាពីគម្រោងកាំប៉ាស (CAMPAS) បានចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃពីស្ថានភាពជីវៈចម្រុះនៅក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀវ ខេត្តមណ្ឌលគិរីកាលពីពេលថ្មីៗនេះ។ ការសិក្សាស្រាវជ្រាវធ្វើឡើងដើម្បីរៀបចំចងក្រងជាឯកសារដាក់ភ្នំណាមលៀវជាតំបន់ភូគព្ភសាស្ត្រ (Geopark) នៃអង្គការយូណេស្កូ (UNESCO)។ សម្រាប់ការសិក្សានេះគេបានធ្វើការបែងចែកជាក្រុមរួមមាន៖ ក្រុមថនិកសត្វធំ ក្រុមប្រចៀវ និងជ្រើង ក្រុមសត្វស្លាប ក្រុមល្មូន និងថលជលិក ក្រុមសត្វល្អិតក្នុងទឹក ពពួកសិប្បីសត្វ (គ្រំ,លៀស,ខ្ចៅ...) (Mollusc) និងក្រុមរុក្ខជាតិ។ ក្រុមនីមួយៗបានប្រើប្រាស់វិធីសាស្ត្រសិក្សាទៅតាមជំនាញរៀងៗខ្លួន ដូចជាការដាក់កាមេរ៉ាថតរូបស្វ័យប្រវត្តិ ខ្សែបន្ទាត់ត្រង់ស៊ិក, ការដាក់អន្ទាក់មង (Mist nets) និងអន្ទាក់ចាប់តាមផ្លូវ (Harp-traps) នៅពេលយប់ ,ការស្តាប់សំលេង ការមើលដោយកែវឆ្លុះ (Binoculars) ការប្រើប្រាស់សំណាញ់ដួសដោយដៃ ការដាក់ជម្រកសិប្បនិម្មិត (Artificial method) និងការជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាជននៅតំបន់នោះ៕





ប្រភេទសត្វល្មូន និងថលជលិក







ក្រុមរុក្ខជាតិ

# ទទួលទានអាហារ៥មុខនេះនឹងផ្តល់ឱ្យស្បែកមានសុខភាពល្អ និងរក្សាតុល្យភាពនៃអ័រម៉ូន

*អត្ថបទ៖ សំបូរ , រូបថត៖ ឯកសារ*

អ្នកជំនាញជាច្រើនជឿថា ក្នុងចំណោមអ័រម៉ូនទាំងអស់ អ័រម៉ូនដែលឧស្សាហ៍ធ្វើឱ្យស្បែកទទួលរងការបំផ្លាញឆាប់ជ្រីវជ្រួញ ហើយងាយនឹងកើតមុន គឺអ័រម៉ូនបុរសតេស្តូស្តេរ៉ូន ហើយការទទួលទានអាហារត្រូវប្រភេទ គឺមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការរក្សាបាននូវកម្រិតត្រឹមត្រូវ នៃអ័រម៉ូន តេស្តូស្តេរ៉ូន។

ខាងក្រោមនេះនឹងបង្ហាញពីអាហារចំនួន៥ប្រភេទ ដែលអ្នកគួរទទួលទាន ដើម្បីឱ្យអ័រម៉ូន មានតុល្យភាព ហើយផ្តល់សុខភាពល្អដល់ស្បែក៖

*១. គ្រាប់អាល់ម៉ុន ៖* គ្រាប់ធញ្ញជាតិមួយនេះ គឺផ្តល់ផលល្អមែនទែន ចំពោះសុខភាពស្បែក ។ គ្រាប់អាល់ម៉ុនបង្កើនអ័រម៉ូន Adipenetic ដែលរក្សាជាតិស្ករនៅក្នុងឈាមឱ្យស្ថិតនៅកម្រិតអប្បបរិមា។ ស្ថានភាពនេះនាំឱ្យកម្រិត នៃអ័រម៉ូនបុរស អង់ដ្រូហ្សែនថយចុះ។ ការស្រាវជ្រាវជាច្រើនបានរកឃើញផងដែរថា ការទទួលទានគ្រាប់ធញ្ញជាតិ ជួយកាត់បន្ថយកម្រិត នៃអ័រម៉ូនបុរសហើយធ្វើឱ្យស្បែកស្ងួតនិងស្ដើង។ អ្នកជំនាញបានណែនាំឱ្យទទួលទានគ្រាប់អាល់ម៉ុនចំនួន១១គ្រាប់ជាប្រចាំដើម្បីរក្សាបាននូវសុខភាពស្បែកល្អប្រសើរ និងជៀសផុតពីបញ្ហាអតុល្យភាពនៃអ័រម៉ូន។



*គ្រាប់អាល់ម៉ុន*

*២. ផ្លែបឺរ ៖* ផ្លែបឺរ គឺមានផ្ទុកនូវជាតិខ្លាញ់សុខភាពល្អ ដែលអាចជួយក្នុងការផលិតនូវកូឡេស្តេរ៉ូលល្អ ចាំបាច់នៅពេលសំយោគអ័រម៉ូន។ ការសំយោគអ័រម៉ូន គឺនឹងធ្វើឱ្យចរន្តឈាមរត់មានភាពល្អប្រសើរ ហើយបញ្ចេញអ័រម៉ូនផ្សេងៗ និងរក្សាបាននូវស្បែក ដែលមានសុខភាពល្អ ទន់រលោង។ ជាតិខ្លាញ់ដែលមាននៅក្នុងផ្លែបឺរក៏ជួយរក្សាសំណើម នៃស្បែក ពង្រឹងស្រទាប់ស្ដើង នៃស្បែក និងធ្វើឱ្យស្បែកមើលទៅស្រស់ស្អាតមានជីវិត។



*ផ្លែបឺរ*

*៣. ត្រីសាលម៉ុន ៖* ត្រីសាលម៉ុនមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ចំពោះបេះដូង និងខួរក្បាលប៉ុណ្ណោះទេ ប៉ុន្តែក៏មានឥទ្ធិពលល្អប្រសើរជួយគ្រប់គ្រងកម្រិត នៃអ័រម៉ូនផងដែរ។ ត្រីសាលម៉ុនមានផ្ទុកនូវអាស៊ីតខ្លាញ់អូមេហ្គា៣ ដែលចាំបាច់ណាស់ក្នុងដំណើរការសំយោគកូឡេស្តេរ៉ូលនិងអ័រម៉ូន។ លើសពីនេះទៅទៀតនោះគឺការទទួលទានត្រីសាលម៉ុនអាចផ្តល់ភាពធូរស្បើយចំពោះបញ្ហាជំងឺសើរស្បែកមួយចំនួនដូចជារោគមុននិងជំងឺតាអកបាន ដោយត្រីនេះមានឥទ្ធិពលប្រយុទ្ធប្រឆាំងនឹងការរលាក។



*ត្រីសាលម៉ុន*

*៨. ផ្នែកពណ៌លឿងនៃស៊ុត៖* ផ្នែកពណ៌លឿងនៃស៊ុត គឺមានផ្ទុកនូវប្រភេទកូឡេស្តេរ៉ូល ដែលរាងកាយត្រូវការ ដើម្បីផលិតអ័រម៉ូន។ ការផលិតអ័រម៉ូននេះស្បែកនឹងប្រែជាកាន់តែទន់រលោងបែបធម្មជាតិ។ ដូច្នេះចូរព្យាយាមទទួលទានស៊ុតឱ្យបានមួយ គ្រាប់ក្នុងមួយថ្ងៃ។

*៩. ផ្កាខាត់ណាខៀវ៖* ផ្កាខាត់ណាខៀវ គឺមានផ្ទុកនូវសមាសធាតុដែលជួយបង្កើនសមត្ថភាពរបស់ថ្លើម ចំពោះការរំលាយអាហារនៃអរម៉ូនអ៊ីស្ត្រូជែន។ ចំពោះមនុស្សស្រី អ័រម៉ូនអ៊ីស្ត្រូជែន គឺចាំបាច់ណាស់ ព្រោះបង្កើនកម្រិតនៃស្រទាប់កូឡាជែន។ ស្រទាប់កូឡាជែន គឺអនុញ្ញាតឱ្យស្បែករក្សាបាននូវសុខភាពល្អរឹងមាំហើយតឹងណែន៕ *(ប្រភព៖សុខភាពកម្ពុជា)*



ផ្នែកពណ៌លឿងនៃស៊ុត



ផ្កាខាត់ណាខៀវ







អាហារ៥មុខ ផ្តល់ឱ្យស្បែកមានសុខភាពល្អ និងរក្សាតុល្យភាពនៃអ័រម៉ូន

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**

**នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចអគ្គមហាសេនាបតីតេជោ** ជាទីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំមានហឫទ័យសោមនស្សរីករាយ ចំពោះលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកែតម្រូវថ្ងៃ-ខែ-ឆ្នាំកំណើត ពីថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៥១ ទៅជាថ្ងៃ-ខែ-ឆ្នាំកំណើតពិតប្រាកដវិញ គឺថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៥២ ត្រូវនឹងថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ ២៤៩៦ តាមដីកាសម្រេចលេខ ៧៣៨ "ក" ដ.ម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គល បវរមហាប្រសើរ សូម **សម្តេចអគ្គមហាសេនាបតីតេជោ** ទទួលបាននូវមហាជោគជ័យថ្មីៗថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដើម្បីជាឧត្តមប្រយោជន៍ជូនប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា និងសូមបានប្រកបតែនឹងព្រះពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងព័ត៌មាន**
លេខ [illegible] ព.ម

# សារថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**

ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងព័ត៌មាន និងក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់ ព្រមទាំងភរិយា សូមព្រះបរមរាជានុញ្ញាតសម្តែងនូវមនោសញ្ចេតនារំភើបរីករាយ និងភក្តីភាពដ៏ជ្រាលជ្រៅបំផុត ថ្វាយចំពោះសម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរជាទីសក្ការៈ ក្នុងឱកាសដ៏ថ្លៃថ្លាមហាប្រសើរ និងឧត្តុង្គឧត្តម នៃព្រះរាជពិធីបុណ្យចំរើនព្រះជន្មគម្រប់៨៦ យាងចូល ៨៧ ព្រះវស្សារបស់ព្រះអង្គ នៅថ្ងៃសៅរ៍ ៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ ។

**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**

ឆ្លៀតឱកាសដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាទាំងមួយម៉ឺនលោកធាតុ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ព្រះបរមរតនកោដ្ឋ សូមជួយប្រោះព្រំតាមបីបាច់ថែរក្សាសម្តេចម៉ែ និងព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ឈ្នះអស់មារសត្រូវគ្រប់ទិសទី និងសូមបានជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ដល់កូនចៅ ចៅទួត របស់ព្រះអង្គ តរៀងទៅ ។

សូមសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ទ្រង់ប្រោសព្រះរាជទានមេត្តាទទួលនូវគារវភក្តីភាព ប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត អំពីទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នា ៕

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃពុធ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**
**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៦ យាងចូល ៨៧ព្រះវស្សារបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** តាងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា នៃព្រឹទ្ធសភា ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សម្តែងអំណរសាទរ និងសូមគោរពថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមព្រះអង្គបានប្រកបតែនឹងព្រះបរមសុខគ្រប់ប្រការ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួនដើម្បីគង់ប្រថាប់ជា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** នៃព្រះរាជាណាចក្រកម្ពុជា ដរាបតរៀងទៅ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលកន្លងមកទ្រង់បានលះបង់ព្រះរាជកាយពល និងព្រះរាជបញ្ញាញាណ ចំពោះព្រះរាជកិច្ចដ៏មហាប្រពៃថ្លៃថ្លារបស់ទ្រង់ ដែលតែងតែយកព្រះរាជហឫទ័យទុកដាក់ អំពីសុខុមាលភាពរបស់ប្រជារាស្ត្រព្រមទាំងបានបំពេញព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តម ប្រកបដោយគុណធម៌ ក្នុងវិស័យមនុស្សធម៌ សង្គមកិច្ច វប្បធម៌ អប់រំ និងសាសនា ដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជារាស្ត្រខ្មែរគ្រប់រូប។ ព្រះអង្គតែងបានប្រោសប្រទានព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គក្នុងបុព្វហេតុមនុស្សធម៌ដោយព្រះអង្គទ្រង់បានជួយដោះស្រាយទុក្ខលំបាកដល់ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ជនចាស់ជរាគ្មានទីពឹង ក្មេងកំព្រា និងជនពិការ សំដៅលើកកម្ពស់ជីវភាពសុខុមាលភាព ជូនប្រជារាស្ត្រទូទៅ។

ក្នុងវេលាកាសដ៏មហាសិរីមង្គលប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រៃ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសបុណ្យបារមី នៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយថែរក្សាការពារ និងប្រោះព្រំ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈ** ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់បានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ប្រោសព្រះរាជទានទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុត ពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ពុធ ១ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ២៥៦៦
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២២

**ប្រធានព្រឹទ្ធសភា**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥ ២៣) ២១១ ៤៤១, ២១១ ៤៤២, ២១១ ៤៤៣ ទូរសារលេខៈ (៨៥៥ ២៣) ២១១ ៤៤៦, Email: oumsarith.sgsenate@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០៧១៥ សជណទខ

# សេចក្តីជូនដំណឹង
## ស្តីពី ការព្យាករអាកាសធាតុលើកទី ១
## សម្រាប់រដូវប្រាំង (២០២១-២០២២) និងដើមរដូវវស្សា ឆ្នាំ ២០២២

យោងតាមការវិវត្តអាកាសធាតុជាសកល តំបន់ ក៏ដូចជាផ្ទៃក្នុងប្រទេស ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឲ្យបានជ្រាប **អំពីស្ថានភាពអាកាសធាតុសម្រាប់រដូវប្រាំង និងដើមរដូវវស្សា ឆ្នាំ ២០២២** ដូចខាងក្រោម ៖

**១- ធាតុភូតសកល ៖**

ផ្អែកតាមការជូនដំណឹងជាសកល ស្តីពីស្ថានភាពសីតុណ្ហភាពលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិក បានបង្ហាញឲ្យឃើញថា ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ ២០២២ ព្រះរាជាណាចក្រកម្ពុជា នៅបន្តទទួលរងនូវឥទ្ធិពលធាតុភូតឡានីណា La Nina ប្រមាណ ៨៥ ភាគរយ និងថយចុះសន្សឹមៗឆ្ពោះទៅធាតុភូត Neutral ដែលជាធាតុភូតនៅចន្លោះរវាងអែលនីញ៉ូ El Nino (ក្តៅ) និងឡានីណា La Nina (ត្រជាក់) ប្រមាណ ៧០ ភាគរយ វិញ ព្រមជាមួយគ្នានឹងធាតុភូត El Nino មានប្រមាណ ១០ ភាគរយ ។

**២- រដូវប្រាំង ៖**

**២.១- សីតុណ្ហភាព ៖**

- សីតុណ្ហភាពអាចទាបជាងមធ្យមភាគច្រើនឆ្នាំ ។
- **នៅខែកុម្ភៈ ៖** បណ្តាខេត្តនៅតំបន់ទំនាបកណ្តាល សីតុណ្ហភាពអប្បបរមា នឹងអាចស្ថិតនៅក្នុងរង្វង់ពី ២១-២៤ °C ។ នៅតំបន់ខ្ពង់រាប និងតំបន់ជួរភ្នំ សីតុណ្ហភាពអប្បបរមា នឹងអាចស្ថិតនៅក្នុងរង្វង់ពី ១៨-២១ °C ដោយឡែកសម្រាប់តំបន់មាត់សមុទ្រ សីតុណ្ហភាពអប្បបរមានឹងអាចស្ថិតក្នុងរង្វង់ពី ២០-២៣ °C ។
- **ចាប់ពីខែមេសា ដល់ខែឧសភា ៖** ធាតុអាកាសនឹងកើនកម្តៅជាបន្តបន្ទាប់ ។ ក្នុងនោះ បណ្តាខេត្តនៅតំបន់ទំនាបកណ្តាល សីតុណ្ហភាពមធ្យមអតិបរមាអាចនឹងកើនឡើងពី ៣៥-៣៨ °C ។ នៅតំបន់ខ្ពង់រាប និងតំបន់ជួរភ្នំ សីតុណ្ហភាពមធ្យមអតិបរមា អាចនឹងកើនឡើងពី ៣៤-៣៧ °C ដោយឡែកសម្រាប់តំបន់មាត់សមុទ្រ សីតុណ្ហភាពមធ្យមអតិបរមាអាចនឹងកើនឡើងពី ៣២-៣៥ °C ។

• អគារលេខៈ ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខៈ (៨៥៥)២៣ ២១៦ ៦៧០
# 364 Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia. Phone: (855) 23 216 670

- **ក្នុងខែមេសា និងខែឧសភា ៖** កម្រិតសីតុណ្ហភាពអតិបរមាអាចនឹងកើនឡើងខ្ពស់បំផុតក្នុងរង្វង់ពី ៣៧-៣៩ °C ។

**២.២- ទឹកភ្លៀង ៖**

- បរិមាណទឹកភ្លៀង អាចនឹងមានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ និងច្រើនជាងឆ្នាំ ២០២១ ។
- ចាប់ពីខែកុម្ភៈ រហូតដល់ដើមខែឧសភា នឹងអាចមានភ្លៀងកក់ខែពីមធ្យមទៅច្រើន។ ទន្ទឹមនោះក៏មានការកើតឡើងនូវបាតុភូតផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ច្រើនផងដែរ ។

**៣- ដើមរដូវវស្សា ៖**

- រដូវវស្សាឆ្នាំ ២០២២ នៅតំបន់វាលទំនាប និងតំបន់មាត់សមុទ្រ អាចនឹងចាប់ផ្តើមនៅសប្តាហ៍ទី ១ នៃខែឧសភា និងតំបន់ខ្ពង់រាប អាចនឹងចាប់ផ្តើមនៅសប្តាហ៍ទី ២ នៃខែឧសភា ។

បើទោះបីនៅក្នុងរដូវប្រាំង និងដើមរដូវវស្សាអាចនឹងមានភ្លៀងកក់ខែច្រើន តែបរិមាណទឹកភ្លៀងដែលធ្លាក់មក មិនទាន់សមល្មមក្នុងការប្រើប្រាស់ ឆ្លើយតបតាមតម្រូវការភ្លាមៗនោះទេ ។ អាស្រ័យហេតុនេះ សូមបន្តរក្សា និងប្រើប្រាស់ទឹកដោយសន្សំសំចៃ ជាពិសេសបណ្តាតំបន់ជនបទដាច់ស្រយាល ដែលនៅឆ្ងាយពីប្រភពទឹក ។

ថ្ងៃព្រហ ១ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២២

**រដ្ឋមន្ត្រី**

**លឹម_គានហោ**

# គ្រួសារក្រសួងព័ត៌មាន ចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំចំពោះមរណភាពរបស់ ធម្មាចារ្យ សីលវតី ហង្ស ឡុង ត្រូវជាម្ដាយ ឯកឧត្តម ផុស សុវណ្ណ

*អត្ថបទ ៖ សាត សុផល , រូបថត ៖ AKP*



ពិធីតម្កល់សពធម្មាចារ្យ សីលវតី ហង្ស ឡុង



ធម្មាចារ្យ សីលវតី **ហង្ស ឡុង** បានទទួលមរណភាព កាលពីថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័កពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ពីវេលាម៉ោង ៧ និង៤០នាទីព្រឹក ដោយរោគាពាព ក្នុងជន្មាយុ ៧៨ ឆ្នាំ។ មរណៈភាពរបស់ធម្មាចារ្យ សីលវតី **ហង្ស ឡុង** គឺជាការបាត់បង់មាតា ជីដូច ដែលបានចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មាន កូន ចៅ ប្រកបដោយព្រហ្មវិហារធម៌មួយរូប ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ គ្រួសារក្រសួងព័ត៌មានទាំងអស់ សូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រមប្រកបដោយក្ដីស្រណោះអាឡោះអាល័យជាមួយឯកឧត្តម **ផុស សុវណ្ណ** និងក្រុមគ្រួសារដោយក្ដីសង្វេគជាទីបំផុត ។

ពិធីបុណ្យគម្រប់ ៧ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ ធម្មាចារ្យ សីលវត្តី **ហង្ស ឡុង** បានប្រព្រឹត្តិទៅនៅថ្ងៃ





ឯកឧត្តម ខៀវ កាញារីទ្ធ ដឹកនាំប្រតិភូថ្នាក់ដឹកនាំក្រសួងព័ត៌មានគោរពវិញ្ញាណក្ខន្ធសពធម្មាចារ្យ សីលវតី  ហង្ស ឡុង





ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានចូលរួមពិធីបុណ្យសពធម្មាចារ្យ សីលវតី  ហង្ស ឡុង

អង្គារ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៣រសៀល មានពិធីនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្តែងធម៌ទេសនា លុះព្រឹកឡើងថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំខាលចត្វាស័កពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩ ព្រឹក វិធីនិមន្តព្រះសង្ឃរាប់បាត្រ វេរភត្តាហារបង្សុកូល និងដារឆ្លងជាកិច្ចបង្ហើយបុណ្យ ដែលពិធីបុណ្យនេះប្រព្រឹត្តទៅនៅគេហដ្ឋានលេខ២២៦ ផ្លូវលំ ក្រុមទី៤ ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលជាគេហដ្ឋានផ្ទាល់របស់ឯកឧត្តម **ផុស សុវណ្ណ** ។

គួរបញ្ជាក់ថា ក្នុងពិធីបុណ្យតម្កល់សពនោះ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១០:០០នាទីព្រឹក ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានប្រតិភូថ្នាក់ដឹកនាំក្រសួងព័ត៌មានអញ្ជើញគោរពវិញ្ញាណក្ខន្ធ សព ធម្មាចារ្យសីលវតី



**ហង្ស ឡុង** នៅគេហដ្ឋានលេខ២២៦ ផ្លូវលំ ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ ។ ជាមួយគ្នានោះ ក៏មានប្រតិភូថ្នាក់ដឹកនាំ មន្ត្រី នៃអគ្គនាយកដ្ឋានទាំង៥ចំណុះក្រសួងព័ត៌មានបានចូលរួមគោរពវិញ្ញាណក្ខន្ធ សព ធម្មាចារ្យ សីលវតី **ហង្ស ឡុង** ផងដែរ ៕

# ONLINE

IN TOUCH WITH YOUR WORLD

## អ្នកផ្តល់សេវាអ៊ីនធឺណិតឈានមុខគេនៅកម្ពុជា

## THE LEADING INTERNET SERVICE PROVIDER IN CAMBODIA




### BROADBAND INTERNET

ONLINE provides many packages of internet service suitable to the actual needs of the public sectors and private sectors,such as Ministries, NGOs, Banks, MFI Factories, Hotels, Casinos, etc.

### CONNECTIVITY

ONLINE provides a flexibility to transport and route several types of network traffic using latest technology and highly efficient transmit applications such as voice, data and video, etc.

### HOSTING / COLOCATION SERVICES

ONLINE provides a flexibility hosting services to customers by adapting to user's requirements which user can host their crucial date and high security. Our colocation service is fully completed and facilitated.



COGETEL Ltd.

023 / 081 72 72 72 | sales@online.com.kh | www.online.com.kh | /onlineisp





ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវ អញ្ជើញជាអធិបតីពិធីបិទ និង ប្រគល់ពានរង្វាន់ជ័យលាភី ក្នុងកម្មវិធីប្រឡងចម្រៀងបុរាណ-សម័យ ពានរង្វាន់ « អរគុណសន្តិភាព អបអរសាទរខួបទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ » កាលពីយប់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ

*រូបថត : ខឹម សុវណ្ណារ៉ា*

